# របាយការណ៍

# ការផ្តល់អំណាចនយោបាយដល់ស្ត្រី និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣



ខែធ្នូ ឆ្នាំ២០២៣

ខុមហ្វ្រែល COMFREL

SILAKA

GADC
Gender and Development for Cambodia

BANTEAY SREI
Women Empowerment

# ការផ្តល់អំណាចនយោបាយដល់ស្ត្រី
# និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
# នីតិកាលទី៧ ឆ្នាំ២០២៣



ប្រភព ៖ កម្ពុជាថ្មី

ខែធ្នូ ឆ្នាំ២០២៣

# មាតិកា

**បុព្វកថា** ........ i
**ពាក្យអក្សរកាត់** (ACRONYMS) ........ ii
I. **សេចក្តីផ្តើម** ........ 1
ក្របខ័ណ្ឌច្បាប់និងគោលនយោបាយដែលមានសារៈសំខាន់សម្រាប់សមភាពយេនឌ័រ និងសិទ្ធិស្ត្រីនៅកម្ពុជា ........ 1
II. **រាជរដ្ឋាភិបាលថ្មី និងរដ្ឋសភាថ្មី** ........ 8
១. រាជរដ្ឋាភិបាលថ្មី ........ 8
២. រដ្ឋសភាថ្មី ........ 9
III. **ការចូលរួមនយោបាយរបស់ស្ត្រីក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣** ........ 11
១. ការជ្រើសរើសបេក្ខជនស្ត្រី និងការចុះបញ្ជីបេក្ខជនគណបក្សនយោបាយ ........ 11
២. ស្ត្រីជាប់ឆ្នោត ........ 27
៣. ផលប៉ះពាល់ ........ 30
៤. ការប្រឈម ........ 31
**ករណីសិក្សាទី១** ........ 31
**ករណីសិក្សាទី២** ........ 33
៥. កម្មវិធីនយោបាយថ្នាក់ជាតិរបស់គណបក្សអំពីបញ្ហាស្ត្រី កុមារ និងការលើកកម្ពស់សមភាពយេនឌ័រ ........ 36
៦. សមាជិកស្ត្រីរបស់គ.ជ.ប, លធ.ខប, គធ.ខប, គឃ.សប, មន្ត្រីការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ........ 44
ថ្នាក់ជាតិ ........ 44
ថ្នាក់ក្រោមជាតិ ........ 45
ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ........ 45

៧. អ្នកសង្កេតការណ៍ ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសារព័ត៌មានជាស្ត្រី 46
អ្នកសង្កេតការណ៍ជាតិជាស្ត្រី 47
អ្នកសង្កេតការណ៍អន្តរជាតិជាស្ត្រី 48
ភ្ញៀវពិសេសជាស្ត្រី 48
ភ្នាក់ងារគណបក្សនយោបាយជាស្ត្រី 48
អ្នកសារព័ត៌មានជាតិ និងអន្តរជាតិជាស្ត្រី 48
៨. អ្នកបោះឆ្នោតស្ត្រី 49
៨.១ ស្ត្រីក្នុងដំណើរការពិនិត្យបញ្ជីឈ្មោះនិងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ២០២២ 49
៨.២ ថ្ងៃបោះឆ្នោត 51
IV. **សេចក្តីសន្និដ្ឋាន និងសន្និដ្ឋាន** 55
V. **អនុសាសន៍** 58
ឧបសម្ព័ន្ធ

# បុព្វកថា

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា ហៅកាត់ថា « ខុមហ្វ្រែល (COMFREL)» អង្គការសីលការ (SILAKA Cambodia) អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា (GADC) អង្គការបន្ទាយស្រី (Banteay Srei) និងទីប្រឹក្សាឯករាជ្យ ជាសមាជិកនៃ«ក្រុមស្ត្រីដើម្បីទាំងអស់គ្នា» ដែលធ្វើការរួមគ្នាដើម្បីលើកស្ទួយការចូលរួមរបស់ស្ត្រីក្នុងវិស័យនយោបាយ និងការដឹកនាំទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិក្នុងការជំរុញឱ្យមានការផ្លាស់ប្តូរជាវិជ្ជមាន ចំពោះការចូលរួមរបស់ស្ត្រីតាមបែបប្រជាធិបតេយ្យតាមរយៈការអភិវឌ្ឍន៍សមត្ថភាពស្ត្រី ការតស៊ូមតិនិងបញ្ចុះបញ្ចូលថ្នាក់ដឹកនាំគណបក្សនយោបាយ និងរដ្ឋាភិបាលក្នុងការបង្កើតគោលនយោបាយ និងច្បាប់ដើម្បីបង្កើនចំនួនតំណាងស្ត្រីនយោបាយ និងមានសមភាពយេនឌ័រនៅគ្រប់លំដាប់ថ្នាក់។

របាយការណ៍ ស្តីពី ***"ការផ្តល់អំណាចនយោបាយដល់ស្ត្រី និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣"*** គឺជាទំរង់នៃការវិភាគទៅលើទិន្នន័យ និងមតិយោបល់របស់ស្ត្រីកម្ពុជា ដែលបានចូលរួមក្នុងកិច្ចការនយោបាយ ជាពិសេស ក្នុងដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រកន្លងទៅនេះ។ របាយការណ៍នេះ បង្ហាញការវាយតម្លៃលើការផ្តល់អំណាចនយោបាយដល់ស្ត្រី និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ អំពីចំនួនបេក្ខជនស្ត្រី ស្ត្រីជាប់ឆ្នោត គោលនយោបាយរបស់គណបក្សក្នុងការលើកស្ទួយស្ត្រីចូលរួមក្នុងវិស័យនយោបាយ កម្មវិធីនយោបាយរបស់គណបក្ស អំពីបញ្ហាស្ត្រី កុមារ និងការបង្កើនសមភាពយេនឌ័រ ការប្រឈមរបស់ស្ត្រីទាំងអ្នកបោះឆ្នោតនិងបេក្ខជនចូលរួមក្នុងដំណើរការបោះឆ្នោត មតិស្ត្រីនៅក្នុងកិច្ចការបោះឆ្នោត និងសកម្មភាពនានាដែលទាក់ទងទៅនឹងការលើកស្ទួយស្ត្រីឱ្យចូលរួមក្នុងវិស័យនយោបាយជាដើម។ ម្យ៉ាងទៀត របាយការណ៍នេះក៏ផ្តល់នូវលទ្ធផលនៃការសង្កេតឃ្លាំមើលការចូលរួមនយោបាយរបស់ស្ត្រីក្នុងការពិនិត្យបញ្ជីឈ្មោះនិងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ក្នុងយុទ្ធនាការឃោសនាបោះឆ្នោត ថ្ងៃបោះឆ្នោតនិងរាប់សន្លឹកឆ្នោត នៅតំបន់គោលដៅរបស់អង្គការហ្វេតស៊ី និងអង្គការខុមហ្វ្រែល និងលទ្ធផលនៃការស្ទង់មតិរហ័សនៅតំបន់គោលដៅរបស់ខុមហ្វ្រែល បន្ទាប់ពីថ្ងៃបោះឆ្នោតទៅលើ ***«ស្ត្រីដែលបានទៅបោះឆ្នោត ឬមានទឹកខ្មៅនៅម្រាមដៃ និងស្ត្រីដែលមិនបានទៅបោះឆ្នោត ឬមិនមានទឹកខ្មៅនៅម្រាមដៃ»*** និងករណីសិក្សាចំនួន២ ។ ជាចុងក្រោយ របាយការណ៍នេះមានអនុសាសន៍សំខាន់ៗក្នុងការលើកកម្ពស់សមភាពយេនឌរ័ និងការផ្តល់អំណាចនយោបាយដល់ស្ត្រីនៅក្នុងប្រទេសកម្ពុជា ។

យើងខ្ញុំសង្ឃឹមថា របាយការណ៍នេះជាឯកសារដ៏សំខាន់ និងមានប្រយោជន៍សម្រាប់អ្នកអនុវត្តន៍សកម្មភាព ជាពិសេសគណបក្សនយោបាយ សមាជិកសភា (តំណាងរាស្ត្រ) រាជរដ្ឋាភិបាល ស្ថាប័នរៀបចំការបោះឆ្នោត បុគ្គលិកសមាគម អង្គការមិនមែនរដ្ឋាភិបាល តំណាងដៃគូអភិវឌ្ឍន៍ និងអ្នកស្រាវជ្រាវ ដើម្បីជួយលើកស្ទួយស្ត្រីចូលរួមកាន់តែច្រើនក្នុងវិស័យនយោបាយ និងតួនាទីសម្រេចចិត្ត ។

សូមថ្លែងអំណរគុណជាពិសេសចំពោះក្រុមការងាររបស់ខុមហ្វ្រែល ដែលតំណាងដោយ **លោកស្រី សឺនកេត សិរីលក្ខណ៍** ដែលជាអ្នកសរសេររបាយការណ៍នេះ។ លោកស្រីក៏ជាប្រធានកម្មវិធីអប់រំ និងយេនឌ័រនៃខុមហ្វ្រែល និងជាអ្នកដឹកនាំក្រុមការងារ ដូចជា **កញ្ញា នុត ធិ** ជាមន្ត្រីអប់រំ និងយេនឌ័រ នៃខុមហ្វ្រែល **កញ្ញា ប្លឹ និ** និង**កញ្ញា ស្រ៊ី លីដា** ជាបុគ្គលិកស្ម័គ្រចិត្តផ្នែកអប់រំនិងយេនឌ័រខុមហ្វ្រែល លេខាធិការខេត្តខុមហ្វ្រែល

និងអ្នកសង្កេតការណ៍ស្ត្រីខុមហ្វ្រែល ដែលបានខិតខំអនុវត្តតាមផែនការសកម្មភាព ដើម្បីប្រមូលទិន្នន័យ សរសេររបាយការណ៍សង្កេត រចនារបាយការណ៍នេះ ដោយមានការសហការពីប្រធានគ្រប់គ្រងកម្មវិធីនៃអង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា (GADC) គឺកញ្ញា **ណម ស៊ីណា** និងសហការីតាមបណ្តាខេត្តគោលដៅក្នុងការបណ្តុះបណ្តាល និងការដាក់ពង្រាយអ្នកសង្កេតការណ៍ស្ត្រី-បុរសនៃខេត្តគោលដៅទាំង៧របស់ខុមហ្វ្រែល និងអង្គការGADC។

សូមថ្លែងអំណរគុណចំពោះក្រុមការងារ ដូចជា អង្គការសីលការ អង្គការហ្គេតស៊ី អង្គការបន្ទាយស្រី និង**លោកស្រី ប៉ុក ណណ្ដា** ទីប្រឹក្សាឯករាជ្យនៃសមាជិកក្រុមស្ត្រីដើម្បីទាំងអស់គ្នា ដែលបានរួមសហការជាមួយខុមហ្វ្រែលលើកិច្ចការស្វែងរកការគាំទ្រមតិ និងការសង្កេត ឃ្លាំមើលការចូលរួមនយោបាយរបស់ស្ត្រីក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣។ សូមអរគុណជាអនេកប្បការចំពោះ **លោកស្រី អិត ពៅ** ទីប្រឹក្សានៃអង្គការខុមហ្វ្រែល **លោក ព្រីង យុន** បុគ្គលិកជានាគុណភាពកម្មវិធីនៃអង្គការសីលការ **លោកស្រី ជឹម ចាន់នាង** អគ្គលេខាធិការនៃNGO-CEDAW និង**លោក គីម ឈន** នាយកប្រតិបត្តិនៃអង្គការខុមហ្វ្រែល ដែលបានផ្តល់មតិយោបល់ល្អៗ និងគាំទ្រធ្វើឱ្យរបាយការណ៍នេះកាន់តែមានភាពល្អប្រសើរថែមទៀត។ យើងខ្ញុំ សូមអរគុណផងដែរចំពោះ **លោក អ៊ុន សំណាង** ដែលបានជួយបកប្រែរបាយការណ៍នេះពីភាសាខ្មែរទៅជាភាសាអង់គ្លេសបានយ៉ាងល្អ។

ថ្ងៃព្រហស្បតិ៍ ១រោច ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២៣

**តំណាងក្រុមការងារស្ត្រីក្នុងវិស័យនយោបាយ**
**អ្នកសម្របសម្រួលកម្មវិធីអប់រំ និងយេនឌ័រនៃខុមហ្វ្រែល**

**សឺនកេត សិរីលក្ខណ៍**

# ពាក្យអក្សរកាត់ (ACRONYMS)

| | |
|---|---|
| **BSDP** | គណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យ |
| **CEC** | គណៈកម្មការឃុំ សង្កាត់ រៀបចំការបោះឆ្នោត |
| **CEDAW** | អនុសញ្ញាស្ដីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ |
| **CIPDP** | គណបក្សជនជាតិដើមប្រជាធិបតេយ្យកម្ពុជា |
| **CNP** | គណបក្សសញ្ជាតិកម្ពុជា |
| **CMDGs** | គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា |
| **COMFREL** | គណៈកម្មាធិការដើម្បីការបោះឆ្នោត ដោយសេរី និងយុត្តិធម៌ នៅកម្ពុជា |
| **CPP** | គណបក្សប្រជាជនកម្ពុជា |
| **CPWP** | គណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ |
| **CSO** | អង្គការសង្គមស៊ីវិល |
| **CYP** | គណបក្សយុវជនកម្ពុជា |
| **DP** | គណបក្សធម្មាធិបតេយ្យ |
| **DPP** | គណបក្សកម្លាំងប្រជាធិបតេយ្យ |
| **ECP** | គណបក្សឯកភាពជាតិខ្មែរ |
| **FP** | គណបក្សកសិករ |
| **FUNCINPEC/FCP** | រណសិរ្សរួបរួមជាតិដើម្បីឯករាជ្យ អព្យាក្រឹត សន្តិភាព និងសហប្រតិបត្តិការកម្ពុជា |
| **GADC** | អង្គការយេនឌ័រ និងអភិវឌ្ឍដើម្បីកម្ពុជា |
| **GDP** | គណបក្សប្រជាធិបតេយ្យមូលដ្ឋាន |
| **KAPP** | គណបក្សខ្មែរឈប់ក្រ |
| **KCP** | គណបក្សខ្មែរអភិរក្ស |
| **KEDP** | គណបក្សខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច |
| **KNUP** | គណបក្សខ្មែររួបរួមជាតិ |
| **KUP** | គណបក្សខ្មែរតែមួយ |
| **MPs** | សមាជិកសភា |
| **NA** | រដ្ឋសភាជាតិ |
| **NEC** | គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត |
| **NGOs** | អង្គការមិនមែនរដ្ឋាភិបាល |
| **PEC** | គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត |
| **PSC** | គណៈកម្មការការិយាល័យបោះឆ្នោត |
| **PSO** | មន្ត្រីការិយាល័យបោះឆ្នោត |
| **PPP** | គណបក្សបំណងពលរដ្ឋ |
| **RGC** | រាជរដ្ឋាភិបាលកម្ពុជា |
| **SDGs** | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
| **SILAKA** | អង្គការសីលការ |
| **VOA** | សំឡេងអាមេរិក |
| **WPW** | គណបក្សស្ត្រីដើម្បីស្ត្រី |

# I. សេចក្តីផ្តើម

[1]ទឡ្ហីករណ៍សម្រាប់តុល្យភាពយេនឌ័រនៅក្នុងនយោបាយគឺមានច្រើន ហើយបានផ្តល់ផលប្រយោជន៍មិនត្រឹមតែស្ត្រី និងអ្នកនយោបាយស្ត្រីប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ផលប្រយោជន៍ដល់គណបក្សខ្លួនឯង និងសង្គមផងដែរ។ ស្ត្រីមានពាក់កណ្តាលនៃចំនួនប្រជាជន ហើយត្រូវការតំណាងស្ត្រីឱ្យកាន់តែប្រសើរឡើងនៅក្នុងរចនាសម្ព័ន្ធអំណាច។

បទពិសោធន៍និងការស្រាវជ្រាវរបស់ iKnow Politics បានរកឃើញថា ភាពចំរុះយេនឌ័រផ្តល់នូវលទ្ធផលល្អប្រសើរជាងមុននៅក្នុងការធ្វើសេចក្តីសម្រេចចិត្តផ្នែកនយោបាយ ហើយតួនាទីរបស់ស្ត្រីនៅក្នុងដំណើរការនយោបាយទាំងថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានធ្វើឱ្យលទ្ធផលប្រជាធិបតេយ្យមានភាពប្រសើរឡើងយ៉ាងខ្លាំង។ សិទ្ធិរបស់ស្ត្រីក្នុងការបញ្ចេញសំលេងស្មើគ្នា និងការចូលរួមក្នុងឆាកនយោបាយមានមូលដ្ឋានរឹងមាំនៃការប្តេជ្ញាចិត្តរបស់អន្តរជាតិ ពីអនុសញ្ញានៃការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើនារីភេទ (ស៊ីដ/CEDAW) ឆ្ពោះទៅផែនការសកម្មភាពទីក្រុងប៉េកាំង (Beijing Platform for Action), គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ (Millennium Development Goals) និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (Sustainable Development Goals)។ ប៉ុន្តែស្ត្រីនៅតែបន្តមានតំណាងតិចតួចនៅគ្រប់ផ្នែកនៃជីវិតនយោបាយ ដូចជា ស្ត្រីនៅក្នុងគណបក្សនយោបាយ ស្ត្រីក្នុងដំណើរការបង្កើតច្បាប់ ស្ត្រីជាបេក្ខជនឈរឈ្មោះបោះឆ្នោត និងតំណាងស្ត្រីជាប់ឆ្នោត ។ល។ និង។ល។

## ក្របខ័ណ្ឌច្បាប់និងគោលនយោបាយដែលមានសារៈសំខាន់សម្រាប់សមភាពយេនឌ័រនិងសិទ្ធិស្ត្រីនៅកម្ពុជា[2]

## ក្របខ័ណ្ឌច្បាប់

រដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជាដែលបានអនុម័តក្នុងឆ្នាំ១៩៩៣ បានហាមឃាត់យ៉ាងច្បាស់នូវការរើសអើងលើស្ត្រីនៅក្នុងមាត្រា៤៥ ដែលបានចែងថា «គ្រប់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីត្រូវហាមឃាត់។ ការកេងប្រវ័ញ្ចស្ត្រីក្នុងការងារត្រូវហាមឃាត់»។ មាត្រា៣៨ ដែលធានាថា «មិនត្រូវមានការរំលោភបំពានលើរាងកាយណាមួយឡើយ» និងមាត្រា៤៦ ដែលចែងថា «ការជួញដូរមនុស្ស ការកេងប្រវ័ញ្ច ពេស្យាកម្ម និងអំពើអាសអាភាសដែលប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់ស្ត្រីត្រូវហាមឃាត់»។ ឧបករណ៍ច្បាប់ដើម្បីការពារ និងលើកកម្ពស់សិទ្ធិស្ត្រីដែលត្រូវបានបង្កើតឡើង និងអនុម័តតាំងពីឆ្នាំ១៩៩៣ រួមមាន ៖ ច្បាប់ស្តីពី ការងារ (ឆ្នាំ១៩៩៧), ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ (ឆ្នាំ២០០៥) និងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ (ឆ្នាំ២០០៨)។

[1] European Union, 2021 on Women in Politics in the EU

[2] Advance International Training Programme (ITP 307, Statistics Sweden/SIDA) 2020 on Gender Statistics: Cambodia Team Assignment

បន្ថែមពីលើក្របខ័ណ្ឌច្បាប់ជាតិដើម្បីការពារ និងលើកកម្ពស់សិទ្ធិស្ត្រី ព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាមួយចំនួន។ ជាក់ស្តែង ក្នុងឆ្នាំ១៩៩២ ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើនារីភេទ (CEDAW) ហើយក៏បានចូលរួមអនុម័តលើ ផែនការសកម្មភាពទីក្រុងប៉េកាំង (BPfA) នៅក្នុងសន្និសីទពិភពលោកលើកទីបួនស្តីពី ស្ត្រី ក្នុងឆ្នាំ១៩៩៥។ ក្នុងនាមជារដ្ឋសមាជិកនៃអង្គការសហប្រជាជាតិ (UN) ប្រទេសកម្ពុជាត្រូវបានចងភ្ជាប់ជាមួយនឹងការសម្រេចចិត្តទាំងអស់របស់ក្រុមប្រឹក្សាសន្តិសុខ នៃអង្គការសហប្រជាជាតិ ជាពិសេសការសម្រេចចិត្តទាក់ទងនឹងស្ត្រី សន្តិភាព និងសន្តិសុខ។

## ក្របខ័ណ្ឌគោលនយោបាយ និងការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលចំពោះសមភាពយេនឌ័រ

ពីរទសវត្សរ៍ចុងក្រោយនេះ រាជរដ្ឋាភិបាលកម្ពុជាបានចាត់ជាអាទិភាពលើសមភាពយេនឌ័រក្នុងរបៀបវារៈអភិវឌ្ឍន៍របស់រដ្ឋាភិបាលដោយទទួលស្គាល់ថា ការលើកកម្ពស់សមភាពយេនឌ័រ និងកិច្ចការពារសង្គមមានសារៈសំខាន់សម្រាប់ការលើកកម្ពស់ស្ថានភាពសេដ្ឋកិច្ច-សង្គម និងការពង្រឹងតួនាទីស្ត្រីនៅក្នុងសង្គមដែលជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច និងសង្គម[3]។ សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី និងក្មេងស្រីត្រូវបានចាត់ទុកជាសកម្មភាពដាច់ដោយឡែកផង និងបញ្ជ្រាបក្នុងកម្មវិធី ឬគម្រោងនានាផងនៅក្នុងការអនុវត្តផែនការអាទិភាពថ្នាក់ជាតិ ជាពិសេស ត្រូវបានយកចិត្តដាក់ក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាល ទី១, ទី២, ទី៣ និងទី៤ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ដែលជាកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ដូចជា គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (CMDGs), គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់កម្ពុជា (CSDGs), ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ, គោលនយោបាយដើម្បីធានាក្របខណ្ឌពី ២០% ទៅ ៥០% ក្នុងការជ្រើសរើសមន្ត្រីរាជការស្ត្រីថ្មី[4] និងផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី (NAPVAW)។

ទន្ទឹមនឹងនេះ យន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិជាច្រើនត្រូវបានបង្កើតឡើង និងបានអនុវត្តជាបន្តបន្ទាប់។ ទាំងនេះរួមមាន ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី (CNCW), ក្រុមការងារបច្ចេកទេសយេនឌ័រ (TWG-G), ក្រុមការងារបញ្ជ្រាបយេនឌ័រ (GMAGs), គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (WCCC), គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំសង្កាត់ (CCWC) ដើម្បីសម្របសម្រួល និងផ្តល់ដំបូន្មានបច្ចេកទេស ជាពិសេសដល់វិស័យ និងស្ថាប័នរបស់ខ្លួន និងចូលរួមសកម្មភាពលើកកម្ពស់សមភាពយេនឌ័រ និងការពង្រឹងសិទ្ធិអំណាចរបស់ស្ត្រី។

ក្នុងនាមជាយន្តការយេនឌ័រថ្នាក់ជាតិ ក្រសួងកិច្ចការនារីសម្របសម្រួលជាមួយភាគីពាក់ព័ន្ធទាំងអស់បង្កើត និងអនុវត្តផែនការយុទ្ធសាស្ត្រជាតិរយៈពេលប្រាំឆ្នាំ គឺ « នារីរតនៈ(Neary Ratanak-NR) » និងបច្ចុប្បន្នហៅថានារីរតនៈទី៥ (NRV) ពីឆ្នាំ២០១៩-ឆ្នាំ២០២៣ ដើម្បីលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចរបស់ស្ត្រីនៅគ្រប់វិស័យ និងគ្រប់កម្រិតក្នុងប្រទេសកម្ពុជា។ វិស័យយុទ្ធសាស្ត្រនៅក្នុង

---

[3] Royal Government of Cambodia (2018) Rectangular Strategy Growth, Employment, Equity and Efficiency, Phase-IV

[4] Prime Minister’s speech in the national forum on women in public and political leadership in 2015, committed set in policy as special measures.

នារីរតនៈទី៥នេះ រួមមាន *១)ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី។ ២)ការលើកកម្ពស់ការអប់រំរបស់ស្ត្រី និងក្មេងស្រី។ ៣)ការលើកកម្ពស់សុខភាពរបស់ស្ត្រី និងក្មេងស្រី។ ៤)កិច្ចការពារផ្លូវច្បាប់សម្រាប់ស្ត្រី និងក្មេងស្រី។ ៥)ស្ត្រីក្នុងវិស័យសាធារណៈ នយោបាយ និងភាពជាអ្នកដឹកនាំ និង៦) ការបញ្ជ្រាបយេនឌ័រក្នុងកម្មវិធីប្រែប្រួលអាកាសធាតុ*[5]។

លើសពីនេះ ក្រសួងកិច្ចការនារីបានដើរតួនាទីដឹកនាំក្នុងការរៀបចំសេចក្តីព្រាងគោលនយោបាយជាតិស្តីពី «សមភាពយេនឌ័រ» ។ គោលនយោបាយនេះ ផ្តល់នូវក្របខ័ណ្ឌគោលនយោបាយរយៈពេលវែងសម្រាប់និងពង្រឹងបន្ថែមទៀតនូវគោលការណ៍សមភាពយេនឌ័រនៅក្នុងគោលនយោបាយជាតិ ផែនការអភិវឌ្ឍន៍យុទ្ធ-សាស្ត្រជាតិ និងផែនការយុទ្ធសាស្ត្រតាមវិស័យ ដើម្បីសម្រេចបានសមភាពយេនឌ័រដែលស្របតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ក្នុងគោលបំណង **«មិនបោះបង់នរណាម្នាក់ឱ្យនៅឯកោ»** និងគោលការណ៍របស់CEDAW នៅក្នុងរបៀបវារៈនៃការអភិវឌ្ឍន៍ និងដើម្បីរួមចំណែកដល់ការអភិវឌ្ឍន៍ធនធានមនុស្សប្រកបដោយបរិយាបន្ន និងសមធម៌សម្រាប់ការកសាងមូលដ្ឋានគ្រឹះ ដើម្បីសម្រេចបាននូវចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០៥០។

[6]តាមរយៈយុទ្ធសាស្ត្រ**បញ្ចកោណ ដំណាក់កាលទី១** ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព នៅក្នុង**បញ្ចកោណទី៤ ៖ ការអភិវឌ្ឍប្រកបដោយភាពធន់ ចីរភាព និងបរិយាបន្ន** នៅមុំទី១ ស្តីពី **ការធ្វើបរមភាវូបនីយកម្មផលលាភប្រជាសាស្ត្រ ការពង្រឹងភាពធន់ប្រជាសាស្ត្រ និងការលើកកម្ពស់សមភាពយេនឌ័រ**ក្នុងនីតិកាលទី៧នៃរដ្ឋសភា រាជរដ្ឋាភិបាលផ្តោតអាទិភាពលើការបង្កើនការវិនិយោគលើយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី និងក្មេងស្រីនៅក្នុវិស័យសេដ្ឋកិច្ច, អប់រំ, សុខភាព និងការដឹកនាំសាធារណៈ ដើម្បីទាញយកអត្ថប្រយោជន៍ពីភាគលាភយេនឌ័រ, និងកាត់បន្ថយភាពងាយរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រទៅលើស្ត្រី និងក្មេងស្រី។

ទោះបីជាយ៉ាងណា ប្រទេសកម្ពុជាពុំទាន់មាន**គោលនយោបាយសមភាពយេនឌ័រ** និងពុំមានច្បាប់បោះឆ្នោតឆ្លើយតបនឹងយេនឌ័រនៅក្នុងវិស័យនយោបាយនៅឡើយ។ ជាក់ស្តែង ពុំទាន់មាន**គោលនយោបាយសមភាពយេនឌ័រ**ជាក់លាក់ជាលាយលក្ខណ៍អក្សរនៅក្នុងគណបក្សនយោបាយ ដែលជាវិធានការពិសេស និងខ្វះ**នូវមាត្រាមួយចំនួនដែលឆ្លើយតបនឹងតម្រូវការយេនឌ័រនៃច្បាប់បោះឆ្នោត** ដើម្បីគាំទ្រ និងផ្តល់ឱកាសឱ្យស្ត្រី-បុរសដែលមានភាពចម្រុះចូលរួមស្មើគ្នាលើតួនាទីសម្រេចចិត្តក្នុងវិស័យនយោបាយ ស្របតាមអនុសញ្ញាស៊ី-ដ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព(SDGs) ដែលកម្ពុជាបានទទួលយក។ បន្ថែមលើនេះទៀតសកម្មជនស្ត្រីគណបក្សនយោបាយ និងអ្នកនយោបាយស្ត្រីនៅតែប្រឈមនឹង**ការរើសអើង**និងអំពើ**ហិង្សាគ្រប់ទម្រង់** ដែលជាឧបសគ្គរាំងពួកគេក្នុងការចូលរួមក្នុងសកម្មភាពនយោបាយ និងការទទួលបាននូវយុត្តិធម៌យេនឌ័រ និងផលប្រយោជន៍ពីការចូលរួមក្នុងវិស័យនយោបាយ។ អនុសញ្ញាស៊ី-ដរ មាត្រា៣ចែងថា ***«ក្នុងគ្រប់***

[5] Royal Government of Cambodia (2019-2023) Neary Rattanak V, five-year strategic plan for strengthening gender mainstreaming and women's empowerment
[6] យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៧ នៃរដ្ឋសភា ធ្វើនៅរាជធានីភ្នំពេញ, ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ ត្រូវនឹង ខែសីហា គ្រិស្តសករាជ ២០២៣

*វិស័យ ជាពិសេស វិស័យនយោបាយ សង្គមកិច្ច សេដ្ឋកិច្ច និងវប្បធម៌ រដ្ឋត្រូវចាត់វិធានការសមស្របទាំងអស់ រួមមាន ការធ្វើច្បាប់ផង ដើម្បីធានាការអភិវឌ្ឍន៍ និងការរីកចំរើនពេញលេញរបស់ស្ត្រី ដើម្បីធានាឱ្យស្ត្រីប្រើប្រាស់ និងអាស្រ័យផលសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានដោយសមភាពជាមួយបុរស»* ។

លទ្ធផលស្ទង់មតិស្តីពី«ការចូលរួមរបស់សកម្មជននយោបាយស្ត្រីនៅក្នុងវិស័យនយោបាយនៅកម្ពុជា» របស់ខុមហ្វ្រែល ឆ្នាំ២០២០ បានបង្ហាញឱ្យឃើញថា ៖ អ្នកនយោបាយស្ត្រីនៅតែប្រឈមច្រើនទម្រង់នៃការរើសអើង និងអំពើហិង្សាប្រឆាំងនឹងពួកគេក្នុងការចូលរួម និងផលប្រយោជន៍នយោបាយរបស់ពួកគេ ទោះបីជាសិទ្ធិនយោបាយ និងការចូលរួមរបស់ស្ត្រីត្រូវបានធានាយ៉ាងពេញលេញដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងអនុសញ្ញាអន្តរជាតិ CEDAW ក៏ដោយ។ អំពើហិង្សាប្រឆាំងនឹងស្ត្រីក្នុងវិស័យនយោបាយ គឺជាបទពិសោធដែលស្ត្រីបានជួបប្រទះជារៀងរាល់ថ្ងៃ សម្រាប់ស្ត្រីដែលមានបំណងចូលរួមក្នុងឆាកនយោបាយ និងជាអ្នកនយោបាយ។ **៧១%** នៃអ្នកចូលរួមក្នុងការស្ទង់មតិបានជួបប្រទះនូវអំពើហិង្សាប្រឆាំងនឹងស្ត្រី។ **៨២%** បានប្រឈមនឹងការគំរាមកំហែង។ **៧០,៩%** ប្រឈមនឹងអំពើហិង្សាផ្លូវចិត្ត។ **៣៤.៥%** បានទទួលរងនូវការរំលោភបំពានលើរាងកាយ និង ៩,១% ទទួលរងការបៀតបៀនលើផ្លូវភេទ។

ជាលទ្ធផល កម្ពុជានៅបន្តបញ្ហាវិសមភាពនៃតំណាង និងការទទួលបានឱកាសស្មើគ្នារវាងស្ត្រីនិងបុរសនៅក្នុងវិស័យនយោបាយ និងវិស័យសាធារណៈ។ ជាក់ស្តែង ភាគរយសរុបនៃស្ត្រី និងបុរសជាប់ឆ្នោតភ្លាមជាតំណាងរាស្ត្រ សម្រាប់នីតិកាលទី៧ ឆ្នាំ២០២៣ មាន**គម្លាតគ្នាឆ្ងាយ** ដែលក្នុងនោះ ស្ត្រីជាប់ឆ្នោតមានតិច **១២,៨%** និងបុរសជាប់ឆ្នោតដ៏ច្រើនលើសលុប **៨៧,២%**។ ចំណែកភាគរយសរុបនៃស្ត្រី និងបុរសក្នុងតំណែងសាធារណៈជាតំណែងនយោបាយនៅក្នុងរដ្ឋាភិបាលថ្មី សម្រាប់នីតិកាលទី៧ នៃរដ្ឋសភាក៏មាន**គម្លាតគ្នាឆ្ងាយ**ផងដែរ គឺ ស្ត្រីមានចំនួនតែ **១៤,៧%** ឯបុរសមានចំនួន **៨៥,៣%** ខណៈពេលដែលសិទ្ធិអំណាចផ្លូវការពេញលេញរបស់ស្ត្រីក្នុងការបំពេញតួនាទីរបស់ខ្លួន នៅមានការប្រឈមនឹងការរើសអើង និងនៅមានកម្រិត។ នេះយើងមិនទាន់វិភាគទៅដល់ភាពចម្រុះផ្សេងទៀតរបស់ស្ត្រីដែលមានពិការភាព ជនជាតិដើមភាគតិច អ្នកស្រលាញ់ភេទដូចគ្នា ជាដើមផង ដោយសារភាពមិនគ្រប់ជ្រុងជ្រោយនៃទិន្នន័យ។

នៅកម្ពុជា ស្ត្រីបានចូលរួមក្នុងកិច្ចការនយោបាយ ការបោះឆ្នោតយ៉ាងសកម្មទាំងសម្លេងនិងសកម្មភាពពីមួយអាណត្តិទៅមួយអាណត្តិនៅទសវត្សរ៍ចុងក្រោយនេះ ផ្ទុយទៅវិញចំនួនស្ត្រីជាប់ឆ្នោតមានការថយចុះជាបន្តបន្ទាប់រាប់ចាប់តាំងពីនីតិកាលទី៥ រហូតមកដល់នីតិកាលទី៧ ឆ្នាំ២០២៣នេះ។ ចំណែកចំនួនបេក្ខជនស្ត្រីនិងបុរសនៅមានគម្លាតគ្នាឆ្ងាយ បើទោះបីចំនួនបេក្ខជនស្ត្រីមានការកើនឡើងសម្រាប់នីតិកាលទី៧នេះក៏ដោយ។ គណបក្សពីរដែលទទួលបានការគាំទ្រពីអ្នកបោះឆ្នោត និងទទួលបានអាសនៈច្រើនក្នុងនីតិកាលទី៧នេះ គឺ **គណបក្សប្រជាជនកម្ពុជា** និង**គណបក្សហ្វ៊ុនស៊ិនប៉ិច** ប៉ុន្តែអ្នកដឹកនាំគណបក្សទាំងពីរនេះនៅខ្វះការប្តេជ្ញាចិត្តខ្ពស់របស់ខ្លួន និងខ្វះគោលនយោបាយរួមទាំងថវិកាដែលបម្រុងទុកក្នុងការបង្កើនសមភាពយេនឌ័រក្នុងវិស័យនយោបាយ និងតួនាទីសម្រេចចិត្ត ដោយបានដាក់បេក្ខជនស្ត្រីឈរឈ្មោះមានភាគរយ**តិច** ហើយបេក្ខជនស្ត្រីភាគច្រើនឈរឈ្មោះនៅលេខរៀង**ខាងក្រោម**នៅក្នុងបញ្ជីឈរឈ្មោះគណបក្សរបស់ខ្លួន សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣។

លទ្ធផលសម្ភាសន៍បេក្ខជនស្រ្តី និងបេក្ខជនបុរសឬ/និងតំណាងគណបក្សនយោបាយជាបុរស អំពីការចូលរួមរបស់ស្ត្រីនៅក្នុងគណបក្សសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ ឆ្នាំ២០២៣ របស់ខុមហ្វ្រែល ឆ្នាំ២០២៣ បានរកឃើញថា គណបក្សនយោបាយចំនួន៥ក្នុងចំណោម៦គណបក្សដែលបានសម្ភាសន៍ មានសកម្មជនស្ត្រីសរុបចំនួន**៥២%** (ចន្លោះពី៤៥% ដល់ ៨១%) ខណៈដែលសកម្មជនជាបុរសសរុបមាន ចំនួនតែ **៤៨%** ប៉ុណ្ណោះ ។ តួលេខនេះបញ្ជាក់យ៉ាងច្បាស់ថា គណបក្សនយោបាយមានស្ត្រីគ្រប់គ្រាន់ក្នុងការឈរឈ្មោះជាបេក្ខជនបោះឆ្នោត និងធ្វើសកម្មភាពនយោបាយគាំទ្របក្សរបស់ខ្លួន ដែលលទ្ធផលសម្ភាសន៍នេះផ្ទុយនឹងអ្វីដែលគណបក្សនយោបាយភាគច្រើនធ្លាប់បានត្អូញត្អែរ និងលើកឡើងអំពីការខ្វះវត្តមានស្ត្រី និងពិបាករកស្ត្រីសម្រាប់ការឈរឈ្មោះជាបេក្ខជនបោះឆ្នោតនៅក្នុងគណបក្សរបស់ខ្លួន។

លទ្ធផលស្ទង់មតិស្តីពី«ការចូលរួមរបស់សកម្មជននយោបាយស្ត្រីនៅក្នុងវិស័យនយោបាយនៅកម្ពុជា» របស់ខុមហ្វ្រែល ឆ្នាំ២០២០ បានរកឃើញទៀតថា ៖ ទោះបីស្ថានភាពនយោបាយមានការផ្លាស់ប្តូរយ៉ាងខ្លាំង ជាពិសេសក្នុងអំឡុងពេលការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឆ្នាំ២០១៨ រួមទាំងការរួមតូចនៃលំហរប្រជាធិបតេយ្យសម្រាប់ពលរដ្ឋ ការបិទប្រព័ន្ធផ្សព្វផ្សាយមួយចំនួន ការធ្លាក់ចុះនៃការគោរពសិទ្ធិមនុស្ស និងការបំភិតបំភ័យដល់អ្នកការពារសិទ្ធិមនុស្ស និងតួអង្គសង្គមស៊ីវិល និងការរំលាយគណបក្សសង្គ្រោះជាតិ ជាពិសេសការបំភិតបំភ័យ និងការរឹតត្បិតលើអ្នកនយោបាយស្ត្រី និងផលប៉ះពាល់នៃជំងឺកូវីដ១៩ <u>៨៥.៥%</u>នៃអ្នកចូលរួមការសិក្សាបានឆ្លើយថា ពួកគេនៅតែមានចំណាប់អារម្មណ៍ និងចូលរួមក្នុងនយោបាយ/ការបោះឆ្នោតក្នុងរយៈពេល <u>២ឆ្នាំ</u> ឬ <u>៣ឆ្នាំ</u>ខាងមុខ (ឆ្នាំ២០២២ និងឆ្នាំ២០២៣)។ <u>**១៤.៥%**</u> នៃអ្នកចូលរួមការសិក្សាបានបញ្ជាក់ថា ពួកគេមិនប្រាកដថាតើពួកគេនឹងបន្តការចូលរួមនយោបាយរបស់ពួកគេ ឬយ៉ាងណាឡើយ។ អ្នកនយោបាយជាស្ត្រីម្នាក់បានបញ្ជាក់ថា *«ខ្ញុំនៅតែចាប់អារម្មណ៍នឹងនយោបាយ ពីព្រោះខ្ញុំជឿជាក់ថា ការចូលរួមរបស់ខ្ញុំ ក៏ដូចជាការចូលរួមរបស់ស្ត្រីដទៃទៀតអាចធ្វើឱ្យឋានៈរបស់ស្ត្រីមានភាពល្អប្រសើរនៅក្នុងប្រទេសកម្ពុជាទាំងមូល។ ទោះជាយ៉ាងណាក៏ដោយ ការគាបសង្កត់នយោបាយ និងអំពើហិង្សាជាប្រព័ន្ធមានសភាពធ្ងន់ធ្ងរណាស់សព្វថ្ងៃនេះ។ ដូច្នេះ ខ្ញុំចាំបាច់ត្រូវវាយតម្លៃស្ថានភាពឡើងវិញ និងស្វែងរកការគាំទ្របន្ថែមទៀតដើម្បីបន្តការខិតខំប្រឹងប្រែងក្នុងនយោបាយរបស់ខ្ញុំនាពេលអនាគត។»*

យោងតាមលទ្ធផលផ្លូវការនៃការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ដែលបានប្រកាសដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) កាលពីថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២៣ មានការ**កើនឡើង**ចំនួនបេក្ខជនស្ត្រីឈរឈ្មោះបោះឆ្នោត សម្រាប់នីតិកាលទី៧ ដែលជាការប្រែប្រួលវិជ្ជមានគួរឱ្យកោតសរសើរ។ ជាក់ស្តែង បេក្ខជនស្ត្រីឈរឈ្មោះបោះឆ្នោត នីតិកាលទី៧ ឆ្នាំ២០២៣នេះមានចំនួន**សរុប ៥២៣ នាក់** ស្មើនឹង **៣២**,៤% នៃបេក្ខជនស្ត្រី-បុរស សរុប ១.៦១៤នាក់នៃគណបក្សប្រកួតប្រជែងទាំង១៨ គឺ **កើន** ចំនួន **៧**,**២**% ធៀបនឹងនីតិកាលទី៦ ឆ្នាំ២០១៨ មានតែ ២៥,២% ប៉ុណ្ណោះ។ ទោះបីជាយ៉ាងណា ចំនួននិងភាគរយសរុបនៃបេក្ខជនស្ត្រី និងបេក្ខជនបុរស នៅមាន **គម្លាតគ្នាឆ្ងាយ** គឺ បេក្ខជនស្ត្រី មានចំនួន **៥២៣នាក់** ស្មើនឹង **៣២,៤%** ខណៈដែលបេក្ខជនបុរសមានដល់ទៅ **១.០៩១នាក់** ស្មើនឹង **៦៧,៦%**។

បេក្ខជនស្ត្រីឈរឈ្មោះនៅ**លេខរៀងទី១** មានចំនួន**៥៥នាក់** (**១៨**%)ជាភាគរយ**ប្រហាក់ប្រហែល**នឹងឆ្នាំ២០១៨ មានចំនួន ១៧,៨%។ **គណបក្សប្រជាជនកម្ពុជា** និង**គណបក្សហ៊្វុនស៊ិនប៉ិច** បានរៀបចំបញ្ជីបេក្ខជនឈរឈ្មោះនៅទូទាំងប្រទេស ២៥ រាជធានី ខេត្ត ប៉ុន្តែគណបក្សទាំងពីរនេះបានដាក់បេក្ខជនស្ត្រីមាន**ភាគរយតិចជាងគេ** និង**ថយចុះ**បើធៀបនឹងនីតិកាលទី៦។

មានតែ គណបក្សនយោបាយ**ចំនួនពីរ**[7] ប៉ុណ្ណោះ ដែលមានសម្លេងឆ្នោតគាំទ្រច្រើន និងទទួលបានអាសនៈនៅរដ្ឋសភាក្នុងចំណោម១៨គណបក្សនយោបាយដែលបានចូលរួមប្រកួតប្រជែង គឺ **គណបក្សប្រជាជនកម្ពុជា** ចំនួន **១២០អាសនៈ** និង**គណបក្សហ៊្វុនស៊ិនប៉ិច** ចំនួន **៥អាសនៈ** ក្នុងនោះស្ត្រីជាប់ឆ្នោតជាសមាជិកសភាមានចំនួនសរុបតែ **១៦រូប ស្មើនឹង ១២**,**៨**% នៃចំនួនអ្នកជាប់ឆ្នោតស្ត្រី-បុរសសរុប ១២៥រូប ដែលស្ត្រីជាប់ឆ្នោតទាំងនោះមកពីគណបក្សប្រជាជនកម្ពុជាទាំងអស់ ហើយចំនួនស្ត្រីជាប់ឆ្នោតនេះបាន **ថយចុះ ៨**% បើធៀបនឹងចុងនីតិកាលទី៦ មានចំនួន ២៦រូប ស្មើនឹង ២០,៨% ។

ទោះបីជាចំនួនបេក្ខជនស្ត្រីមានការកើនឡើងគួរឱ្យកត់សម្គាល់ក៏ដោយ ក៏ក្រុមស្ត្រីនៃអង្គការសង្គមស៊ីវិលនៅមានកង្វល់ ដោយសារចំនួននេះនៅមានគម្លាតគ្នាឆ្ងាយរវាងបេក្ខជនស្ត្រី និងបេក្ខជនបុរស (បេក្ខជនស្ត្រី៣២,៤% និងបេក្ខជនបុរស ៦៧,៦%) ដែលវិសមភាពយេនឌ័រក្នុងវិស័យនយោបាយនៅតែជាបញ្ហាត្រូវបន្ថែមការយកចិត្តទុកដាក់ និងត្រូវដាក់ចេញនូវវិធានការពិសេសជាក់លាក់ពីអ្នកដឹកនាំគណបក្សនយោបាយ, អ្នកដឹកនាំរដ្ឋាភិបាល និងសភាជាតិ។ ស្ត្រីជាប់ឆ្នោតជាតំណាងរាស្ត្រដែលមានចំនួនតិចនិងថយចុះដោយសារមានកត្តាចម្បង និងការប្រឈមមួយចំនួន ៖ **(១)** កង្វះឆន្ទៈនយោបាយរបស់គណបក្ស និងការប្តេជ្ញាចិត្តខ្ពស់របស់អ្នកដឹកនាំ ជាពិសេសគណបក្សដែលមានការគាំទ្រច្រើនពីអ្នកបោះឆ្នោត (មានអាសនៈក្នុងសភា) ក្នុងការជំរុញឱ្យមានសមភាពយេនឌ័រក្នុងវិស័យនយោបាយ និងថ្នាក់សម្រេចចិត្ត ជាក់ស្តែងគណបក្សប្រជាជនកម្ពុជា និងគណបក្សហ៊្វុនស៊ិនប៉ិច បានដាក់បេក្ខជនស្ត្រីឈរឈ្មោះរបស់ខ្លួនក្នុងចំនួនតិចតួចពេកសម្រាប់ការបោះឆ្នោតនីតិកាលទី៧នេះ។ **(២)** ខ្វះគោលនយោបាយសមភាពយេនឌ័រជាក់លាក់ជាលាយលក្ខណ៍អក្សរនៅក្នុងគណបក្សនយោបាយ រួមទាំងមិនមានចែងជាក់លាក់អំពីវិធានការពិសេសក្នុងមាត្រាមួយចំនួននៃច្បាប់បោះឆ្នោត ដើម្បីគាំទ្រ និងផ្តល់ឱកាសឱ្យស្ត្រីចូលរួមដោយស្មើគ្នានឹងបុរសក្នុងវិស័យនយោបាយ ជាពិសេសការឈរឈ្មោះជាបេក្ខជន និងជាប់ឆ្នោតក្លាយជាអ្នកដឹកនាំ។ **(៣)** រចនាសម្ព័ន្ធនៃការគ្រប់គ្រងភាគច្រើនលើសលុបជាបុរស ហើយបុរសនៅតែបន្តរក្សាតំណែងរបស់ខ្លួន ដែលនេះធ្វើឱ្យឱកាសទទួលបានមុខតំណែងរបស់ស្ត្រីកាន់តែរួមតូច។ **(៤)** បញ្ហាថវិកាក្នុងការឈរឈ្មោះជាបេក្ខជនដែលគណបក្សតម្រូវសម្រាប់ធ្វើការឃោសនាបោះឆ្នោត គឺជាឧបសគ្គដ៏ធំបំផុតមួយ ដែលស្ត្រីបានប្រឈម។ (៥) សកម្មជនស្ត្រីគណបក្សនយោបាយ និងអ្នកនយោបាយស្ត្រីនៅតែប្រឈមនឹង**ការរើសអើង**និងអំពើ**ហិង្សាគ្រប់ទម្រង់** ដែលជាឧបសគ្គរារាំងពួកគេក្នុងការចូលរួមក្នុងសកម្មភាពនយោបាយ និងការទទួលបាននូវយុត្តិធម៌យេនឌ័រនិងផលប្រយោជន៍ពីការចូលរួមក្នុងវិស័យនយោបាយ។ **(៦)** បទដ្ឋានវប្បធម៌ និងសង្គមមួយចំនួនដែលមានផ្នត់គំនិតអវិជ្ជមាន

---

[7] លទ្ធផលបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ផ្លូវការ ចេញផ្សាយដោយ គ.ជ.ប នៅថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៣

ក្នុងការលើកកម្ពស់ភាពជាអ្នកដឹកនាំរបស់ស្ត្រី គឺជាឫសគល់បញ្ហាបង្កជារនាំងរារាំងដល់ការចូលរួមរបស់អ្នកនយោបាយ ស្ត្រីប្រកបដោយគុណភាពនិង ប្រសិទ្ធភាព។

# II. រាជរដ្ឋាភិបាលថ្មី និងរដ្ឋសភាថ្មី

## ១. រាជរដ្ឋាភិបាលថ្មី

ស្ត្រីនៅក្នុងតំណែងសាធារណៈជាតំណែងនយោបាយដឹកនាំនៅថ្នាក់ជាតិ គឺ មាន**ភាគរយតិចតួច** និងមាន**គម្លាតគ្នាយ៉ាងខ្លាំង**រវាងស្ត្រី និងបុរសរាប់ចាប់ពីតំណែងឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការសម្រាប់រាជរដ្ឋាភិបាលថ្មី នីតិកាលទី៧ នៃរដ្ឋសភា គឺជារាជរដ្ឋាភិបាលថ្មី នាយករដ្ឋមន្ត្រីថ្មីវ័យសក្តានុពលដែលមានការសិក្សាខ្ពង់ខ្ពស់ ជារដ្ឋាភិបាលដែលដឹកនាំដោយអ្នកដឹកនាំជំនាន់ថ្មីវ័យក្មេងភាគច្រើន ដែលជាវ័យប្រកបដោយ **សក្តានុពល ថាមពល និងរហ័សរហួន** ។ ជាក់ស្តែង **ស្ត្រី**មានចំនួនតែ **២២២នាក់** ស្មើនឹង **១៤,៧%** ចំណែក**បុរស**មានចំនួនដ៏ច្រើនលើសលុប **១.២៩១នាក់** ស្មើនឹង **៨៥,៣%** នៃចំនួនសរុប ១.៥១៣នាក់ (មិនបូកបញ្ចូលរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន) ក្នុងនោះ **រដ្ឋមន្ត្រីស្ត្រី**ចំនួន **៣នាក់** ស្មើនឹង **១០%** និងបុរសចំនួន **២៧នាក់** ស្មើនឹង **៩០%** នៃចំនួនសរុប ៣០នាក់ (បូកបញ្ចូលរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល និងរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន)។ ក្នុងចំណោម២៨ក្រសួង និងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល **រដ្ឋលេខាធិការស្ត្រី**មានចំនួន *១០៩នាក់* ស្មើនឹង **១៤,៩%** និងបុរសចំនួន **៦២៤នាក់** ស្មើនឹង **៨៥,១%** នៃចំនួនសរុប ៧៣៣នាក់។ **អនុរដ្ឋលេខាធិការស្ត្រី**មានចំនួន **១០៩នាក់** ស្មើនឹង **១៥,៨%** និង**បុរស**ចំនួន **៥៨០នាក់** ស្មើនឹង **៨៤,២%** នៃចំនួនសរុប៦៨៩នាក់។ ផ្ទុយទៅវិញ ពុំឃើញមានស្ត្រីណាម្នាក់បានតែងតាំងក្នុងតំណែងជាឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីឡើយ។

ភាគរយស្ត្រីនៃរាជរដ្ឋាភិបាលថ្មី នីតិកាលទី៧ នៃរដ្ឋសភា បាន**ថយចុះ** បើធៀបនឹងនីតិកាលទី៦ នៃរដ្ឋសភា ស្ត្រីមានប្រមាណ**១៦%**[8] (គិតត្រឹមខែកុម្ភៈ ឆ្នាំ២០២០) និងនីតិកាលទី៥នៃរដ្ឋសភា ស្ត្រីមាន**១៦,៧%**[9] នៃតំណែងជាន់ខ្ពស់របស់រាជរដ្ឋាភិបាល រាប់ចាប់ពីអនុរដ្ឋលេខាធិការ រហូតដល់ ឧបនាយករដ្ឋមន្ត្រី។

អ្វីដែលកត់សម្គាល់ខ្លាំងសម្រាប់រាជរដ្ឋាភិបាលថ្មី នីតិកាលទី៧ នៃរដ្ឋសភា គឺ លោកស្រីបណ្ឌិត ជា សិរី ឥស្សរជនជាស្ត្រីដំបូងគេដែលបានតែងតាំងជាអគ្គទេសាភិបាលថ្មីរបស់ធនាគារជាតិនៃកម្ពុជា កាលពីថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៣ ដោយព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា។ លោកស្រីបណ្ឌិត ជា សិរី គឺជាឥស្សរជនដែលស័ក្តិសមបំផុតសម្រាប់ មុខតំណែងជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា ដោយសារលោកស្រីមានចំណេះដឹងជ្រៅជ្រះ និងចក្ខុវិស័យច្បាស់លាស់វែងឆ្ងាយក្នុងការអនុវត្តការងារ ព្រមទាំងដឹកនាំប្រព័ន្ធធនាគារកម្ពុជាឱ្យសម្រេចបាន លទ្ធផលល្អប្រសើរជាច្រើនលើឆាកអន្តរជាតិ។

---

[8] យោងតាមរបាយការណ៍ដែលចេញដោយអគ្គលេខាធិការដ្ឋានរដ្ឋសភា នៅដើមឆ្នាំ២០២០

[9] របាយការណ៍ខុមហ្វ្រែលសហការជាមួយគ.ស.ន ស្តីពី ការផ្តល់អំណាចនយោបាយដល់ស្ត្រីនិងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣

ការតែងតាំងនេះ កំពុងបង្ហាញពីការរីកចម្រើនកាន់តែប្រសើរផ្នែកធនធានមនុស្សរបស់កម្ពុជាទៅកាន់ពិភពលោក ដែលមានស្ត្រីឆ្នើម និងមានសមត្ថភាពខ្ពស់កាន់តំណែងជាអ្នកដឹកនាំធនាគារកណ្ដាលរបស់ប្រទេស ដែលភាគច្រើននៃអ្នកកាន់តំណែងនេះ គឺជាបុរស។

របាយការណ៍របស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បង្ហាញថា ក្នុងចំណោមប្រទេសជាសមាជិករបស់ IMF សរុប ១៩០ប្រទេស មានអ្នកដឹកនាំជាស្ត្រីត្រឹមតែ **២៦រូប**ប៉ុណ្ណោះ ដែលកាន់តួនាទីជា**រដ្ឋមន្ត្រីហិរញ្ញវត្ថុ** និងមានតែ **១៧រូប**ប៉ុណ្ណោះ ដែលកាន់តួនាទីជា**អគ្គទេសាភិបាលធនាគារកណ្ដាល**។ តួលេខនេះមានន័យថា មានអ្នកដឹកនាំជាស្ត្រីតែ **១១,៣%**ប៉ុណ្ណោះ ដែលកាន់តួនាទីជាអ្នកដឹកនាំនៅស្ថាប័នគោលនយោបាយសេដ្ឋកិច្ចដ៏**សំខាន់ទាំងពីរ** គឺជាអគ្គទេសាភិបាលធនាគារកណ្ដាល និងជារដ្ឋមន្ត្រីហិរញ្ញវត្ថុ។

ក្រោមការដឹកនាំដ៏ប៉ិនប្រសប់ និងឈ្លាសវៃរបស់លោកស្រី ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់ត្រូវបានធ្វើទំនើបកម្ម ជាពិសេសការដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធទូទាត់ដ៏ទំនើបថ្មី «**បាគង**» ដែលប្រើប្រាស់បច្ចេកវិទ្យាប្លុកឆេន បានជួយសម្រួលដល់ការផ្ទេរប្រាក់ពីធនាគារមួយ ទៅធនាគារមួយទៀតបានងាយស្រួល ឆាប់រហ័ស និងសុវត្ថិភាព។

ក្នុងនាមជាអ្នកផ្ដួចផ្ដើមបង្កើតប្រព័ន្ធបាគង លោកស្រីបណ្ឌិត ជា សិរី ត្រូវបានស្ថាប័ន *CoinDesk* ដែលជាស្ថាប័នព័ត៌មានផ្នែកបច្ចេកវិទ្យាហិរញ្ញវត្ថុដ៏ល្បីលើពិភពលោកចាត់ថ្នាក់ លោកស្រីបណ្ឌិត ជា សិរី ជា**ឥស្សរជនឆ្នើមបំផុតប្រចាំឆ្នាំ**ក្នុងចំណោម**ឥស្សរជនឆ្នើម**មានឥទ្ធិពលបំផុតទាំង ៥០ លើពិភពលោកផ្នែកបច្ចេកវិទ្យាហិរញ្ញវត្ថុ។ លើសពីនេះ **ប្រព័ន្ធទូទាត់បាគង**ក៏បានឈ្នះពានរង្វាន់ពីស្ថាប័នព័ត៌មានសេដ្ឋកិច្ចដ៏ល្បីរបស់ជប៉ុន Nikkei Asia ស្ដីពី ពានរង្វាន់សេវាកម្មនិងផលិតផលឆ្នើមប្រចាំឆ្នាំ២០២១។

ប្រភព ៖ Fresh News – 01-08-2023

## ២. រដ្ឋសភាថ្មី

ភាគរយសរុបនៃស្ត្រី និងបុរសជាប់ឆ្នោតភ្លាមជាតំណាងរាស្ត្រ សម្រាប់នីតិកាលទី៧ ឆ្នាំ២០២៣ មាន**គម្លាតគ្នាយ៉ាងខ្លាំង** ដែលក្នុងនោះស្ត្រីជាប់ឆ្នោតមានតិច **១២,៨%** និងបុរសជាប់ឆ្នោតដ៏ច្រើនលើសលុប **៨៧,២% គឺចំនួនស្ត្រីមានការថយចុះ ៨%** បើធៀបនឹងចុងនីតិកាលទី៦ នៃរដ្ឋសភា តំណាងរាស្ត្រស្ត្រីមាន **២០,៨%** ពី ២៦រូប មកត្រឹមតែ ១៦រូប។ ទោះបីជាយ៉ាងណាក៏ដោយ យើងកត់សម្គាល់ឃើញថា មានការផ្លាស់ប្ដូរថ្មីវិជ្ជមានជាប្រវត្តិសាស្ត្រ ជាការផ្ដល់ឱកាសដ៏អស្ចារ្យដល់ស្ត្រីក្លាយជាប្រធានរដ្ឋសភាថ្មី សម្រាប់នីតិកាលទី៧នេះ ដែលជាការផ្លាស់ប្ដូរបែបវិជ្ជមានមួយពុំធ្លាប់មានពីមុននៅប្រទេសកម្ពុជា គឺ លោកជំទាវ ឃួន សុដារី ជាស្ត្រីដំបូងត្រូវបានជ្រើសតាំងជា ប្រធានរដ្ឋសភា[10] ដែលបានបង្ហាញពីការប្ដេជ្ញាចិត្តខ្ពស់ និងការបង្កើនសមភាពយេនឌ័ររបស់ប្រធានគណបក្សប្រជាជនកម្ពុជា ជាគណបក្សឈ្នះឆ្នោតសម្រាប់នីតិកាលទី៧នេះ ហើយសង្ឃឹមថា លោកជំទាវប្រធានរដ្ឋសភានឹងទទួលបានសិទ្ធិ និងអំណាចពេញលេញក្នុងការដឹកនាំស្ថាប័នកំពូលនីតិបញ្ញត្តិប្រកបដោយបរិយាបន្ន និងជម្រុញឱ្យមានសមភាពយេនឌ័រពិតប្រាកដ ដោយផ្ដោត

[10] ការប្រកាសរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន កាលពីថ្ងៃទី៩ ខែសីហា ឆ្នាំ២០២៣ (សារសំឡេង)

ការយកចិត្តទុកដាក់ដល់ការចូលរួមរបស់ក្រុមជនងាយរងគ្រោះ ជាពិសេសស្ត្រីដែលនៅមានឱកាសតិចតួចនៅឡើយ តាមរយៈការផ្តួចផ្តើមគំនិតពិនិត្យមើលច្បាប់បោះឆ្នោត និងធ្វើវិសោធនកម្មច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់ដើម្បីឆ្លើយតបនឹងតម្រូវការយេនឌ័រ ដោយមានចែងជាវិធានការពិសេស ប្រយោជន៍ធានានូវឱកាសស្មើគ្នារវាងស្ត្រី និងបុរសក្នុងការឈរឈ្មោះជាបេក្ខជន និងមានស្ត្រីច្រើនជាតំណាងជាប់ឆ្នោត ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

«ទោះបីគាត់ (លោកជំទាវ ឃួន សុដារី) មកតាមរយៈការឈរឈ្មោះជាសមាជិកគណបក្សមែន តែស្ថាប័នជាតិនេះជាស្ថាប័នឯករាជ្យ ជាស្ថាប័នសម្រាប់ប្រជាជាតិទាំងមូលជួយដល់ប្រជាពលរដ្ឋ ធ្វើឱ្យប្រទេសកម្ពុជាយើងមានការរីកចម្រើនប្រសើរជាងមុន។ ព្រោះតាមការរកឃើញថា នៅពេលមានមេដឹកនាំជាស្ត្រីស្ថិតនៅថ្នាក់កំពូលៗក្នុងការដឹកនាំកាន់តែច្រើន នឹងធ្វើឱ្យលទ្ធផលក្នុងប្រទេសកាន់តែប្រសើរ»។ ដោយអ្នកសម្របសម្រួលកម្មវិធីអប់រំ និងយេនឌ័រនៃអង្គការខុមហ្វ្រែល អ្នកស្រី សឺនកេត សិរីលក្ខណ៍។ *(ការផ្សាយរបស់ VOA, ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៣)*

លោកជំទាវ ឃួន សុដារី ត្រូវបានព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ**នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាដែលបានប្រទានគោរមងារជា **សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី** ។ ប្រភព ៖ Fresh News – 03-09-2023

ក្នុងចំណោម **១០គណៈកម្មការ**នៃរដ្ឋសភា នីតិកាលទី៧ (២០២៣-២០២៨) មាន**ស្ត្រីតែ ២រូប** ប៉ុណ្ណោះដែលមានឱកាសជាប្រធានគណៈកម្មការ។ **<u>១រូប</u> ជាប្រធានគណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី** និង **<u>១រូប</u>**ទៀតជា **ប្រធានសាធារណការ ដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់**[11]។ ស្ត្រីជាប្រធានគណៈកម្មការនេះ ជាចំនួនតិចណាស់ដែលគួរ ត្រូវគិតពីវិធានការពិសេសរបស់ថ្នាក់ដឹកនាំរដ្ឋសភាថ្មីក្នុងការផ្តល់ឱកាសឱ្យស្ត្រីក្លាយជាប្រធានគណៈកម្មការនៃរដ្ឋសភា យ៉ាងហោច **៤រូប** ក្នុងចំណោម **១០រូប** ប្រយោជន៍ស្ត្រីបានចូលរួមដឹកនាំការពិភាក្សាច្បាប់ បង្កើតច្បាប់ប្រកបដោយបរិយាបន្ន និងគ្រប់ជ្រុងជ្រោយ។

របាយការណ៍ខាងក្រោមនេះ គឺបានពីអ្នកសង្កេតការណ៍បោះឆ្នោតស្ត្រីខុមហ្វ្រែល សហការជាមួយអ្នកសង្កេតការណ៍ស្ត្រី-បុរសនៃអង្គការយេនឌ័រ និងការអភិវឌ្ឍន៍ ដើម្បីកម្ពុជា(GADC) ក្រុមការងារយេនឌ័រ/ស្ត្រីនៃអង្គការសង្គមស៊ីវិល និងប្រភពទិន្នន័យផ្សេងៗ។ របាយការណ៍នេះ គឺផ្តោតទៅលើបញ្ហា ឬការប្រឈមដំណោះស្រាយ ឬវិធានការទាក់ទងនឹងការជ្រើសរើសស្ត្រីឈរឈ្មោះជាបេក្ខជន ការចុះបញ្ជីបេក្ខជនស្ត្រី-បុរស កម្មវិធីនយោបាយរបស់គណបក្សទាក់ទងនឹងការដោះស្រាយបញ្ហាស្ត្រី និងកុមារ ស្ត្រីជាប់ឆ្នោត ស្ត្រីជាមន្ត្រីរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ស្ត្រីនិងការពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ស្ត្រីជាអ្នកសង្កេតការណ៍ ភ្នាក់ងារគណបក្សនយោបាយ និងអ្នកបោះឆ្នោតជាស្ត្រី។

---

[11] រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ស្តីពី គណៈកម្មការ នៃរដ្ឋសភា នីតិកាលទី៧ (២០២៣-២០២៨)

## III. ការចូលរួមនយោបាយរបស់ស្ត្រីក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣

ការចូលរួមនយោបាយរបស់ស្ត្រីក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ នេះ ត្រូវបានរកឃើញថា មាន**ភាពប្រសើរជាងមុន** ប៉ុន្តែនៅមាន**បញ្ហាប្រឈម**សំខាន់ៗមួយចំនួនក្នុងការទទួលបានឱកាសស្មើគ្នារវាងស្ត្រី និងបុរសឈរឈ្មោះជាបេក្ខជន ការប្រឈមនឹងបរិយាកាសមិនប្រក្រតីមួយចំនួនក្នុងដំណើរការបោះឆ្នោតដែលមានឥទ្ធិពលលើអ្នកបោះឆ្នោត និងឱកាសឈានទៅមុខក្នុងជីវិតនយោបាយរបស់ស្ត្រីជាប់ឆ្នោត។

### ១- ការជ្រើសរើសបេក្ខជនស្ត្រី និងការចុះបញ្ជីបេក្ខជនគណបក្សនយោបាយ

គណបក្សនយោបាយទាំង១៨ ដែលបានចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ នៅតែបង្ហាញឱ្យឃើញថា ការងារលើកកម្ពស់ភាពជាអ្នកដឹកនាំរបស់ស្ត្រីនៅមានកំរិតនៅឡើយ តាមរយៈលទ្ធផលនៃការឈរឈ្មោះជាបេក្ខជន ជាពិសេសការឈរឈ្មោះជាបេក្ខជនរបស់ស្ត្រីនៅលំដាប់លេខរៀងទី១ដែលមានឱកាសច្រើនក្នុងការក្លាយខ្លួនជាតំណាងជាប់ឆ្នោត ។ ជាក់ស្តែងចំនួននិងភាគរយសរុបនៃបេក្ខជនស្ត្រី និងបេក្ខជនបុរសឈរឈ្មោះនៅ**លេខរៀងទី១ មានគម្លាតគ្នាខ្លាំង គឺ**បេក្ខជនស្ត្រី មាន១៨% ខណៈដែលបេក្ខជនបុរសមានច្រើនលើសលុប **៨២%**។

យោងតាមលទ្ធផលនៃសិក្ខាសាលាពិគ្រោះយោបល់ ស្តីពី **"វិធានការពិសេសដើម្បីពន្លឿនការបង្កើនបេក្ខជនស្ត្រីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣"** ដែលសហការរៀបចំដោយអង្គការខុមហ្វ្រែល(COMFREL), អង្គការសីលការកម្ពុជា(SILAKA), អង្គការយេនឌ័រនិងអភិវឌ្ឍន៍ដើម្បីកម្ពុជា(GADC), អង្គការបន្ទាយស្រី(Banteay Srei), អង្គការអភិវឌ្ឍនិងភាពជាដៃគូក្នុងសកម្មភាព(DPA), អង្គការកម្មវិធីអភិវឌ្ឍន៍ធនធានយុវជន (YRDP) និងទីប្រឹក្សាឯករាជ្យផ្នែកយេនឌ័រ នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៣មុនការបោះឆ្នោត បានបង្ហាញឱ្យឃើញថា ក្នុងចំណោម១៦គណបក្សនយោបាយ និងអ្នកពាក់ព័ន្ធសំខាន់ៗដែលបានចូលរួមសិក្ខាសាលាពិគ្រោះយោបល់នេះ បានលើកឡើងពីមតិយោបល់ និងឆន្ទៈក្នុងការលើកទឹកចិត្ត និងជម្រុញឱ្យមានចំនួនស្ត្រីចូលរួមកាន់តែច្រើនឡើង និងលើកកម្ពស់ការចូលរួមរបស់ស្ត្រីដោយស្មើភាព និងគ្មានការរើសអើងនៅក្នុងគណបក្សនយោបាយរបស់ខ្លួន ដែលមានដូចខាងក្រោម ៖

- **គណបក្សហ្វ៊ុនស៊ិនប៉ិច** កំពុងពង្រឹងចលនាស្ត្រីដើម្បីពង្រឹងភាពអង់អាចរបស់ស្ត្រី ប៉ុន្តែគណបក្សនេះមិនមានកំណត់កូតាជាក់លាក់នៅក្នុងបញ្ជីលេខរៀងឈរឈ្មោះដែលជាប់ឆ្នោតនោះទេ ហើយក៏មិនមានគោលនយោបាយសមភាពយេនឌ័រដែរ។

- **គណបក្សភ្លើងទៀន** មានការលើកទឹកចិត្តតាមរយៈការឧបត្ថម្ភជាថវិកា ចំនួន ៣០០ ដុល្លារអាមេរិកដល់ស្ត្រីដែលឈរឈ្មោះពីលេខរៀងទី១ដល់ទី៣។ គណបក្សកំពុងជម្រុញ និងរកស្ត្រី ប៉ុន្តែផ្អែកលើសមត្ថភាព និងលទ្ធភាព ដោយសារតែឈរឈ្មោះជាបេក្ខជនថ្នាក់ជាតិ និងបានត្រៀមបេក្ខជនស្ត្រីពី៣នាក់ទៅ៤នាក់ឈរឈ្មោះនៅលេខរៀងជាប់ឆ្នោត។ គណបក្សនេះបានសំដែងពីការព្រួយបារម្ភដោយសារស្ត្រីអត់ហ៊ានចូលរួមជាសមាជិកគណបក្សខ្លួន ព្រោះបារម្ភពីសុវត្ថិភាព ។ ដូច្នេះ គណបក្សសូមស្នើរដ្ឋាភិបាលផ្តល់លំហូរសិទ្ធិសេរីភាពក្នុងកិច្ចការនយោបាយ។
- **គណបក្សខ្មែរស្រលាញ់ជាតិ** មានការលើកទឹកចិត្ត ៤៥%ជាស្ត្រីបានឈរឈ្មោះជាបេក្ខជនក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០២២កន្លងមក។ គោលការណ៍គណបក្សខ្មែរស្រលាញ់ជាតិតែងលើកទឹកចិត្ត និងផ្តល់ឱកាសដល់ស្ត្រីឱ្យមានឱកាសក្នុងការឈរជាបេក្ខភាពនៅលេខរៀងទី១ ហើយនឹងលើកទឹកចិត្តឱ្យស្ត្រីឈរឱ្យបានច្រើនជាងបុរស ព្រោះយើងបានគិតថានៅក្នុងសង្គមកម្ពុជារបស់យើងនាពេលបច្ចុប្បន្ននេះ បញ្ហាសីលធម៌សង្គមកាន់តែធ្លាក់ចុះ ដោយសារតែបុរសមិនបានផ្តល់ឱកាស និងលើកទឹកចិត្តដល់ស្ត្រីដែលជាផ្នែកដ៏សំខាន់នៅក្នុងការអភិវឌ្ឍន៍ប្រទេសជាតិ។
- **គណបក្សប្រជាធិបតេយ្យមូលដ្ឋាន** មានគោលការណ៍ផ្ទៃក្នុងនៅក្នុងគណបក្ស ដោយមានស្ត្រី និងបុរសឆ្លាស់គ្នាជាប្រធាន និងអនុប្រធាន និងការកសាងសមត្ថភាពដល់បេក្ខជនស្ត្រី។ គណបក្សនឹងប្រើប្រព័ន្ធឆ្លាស់រវាងបេក្ខជនស្ត្រី និងបេក្ខជនបុរសសម្រាប់ការបោះឆ្នោតជាតិ ឆ្នាំ២០២៣នេះ។
- **គណបក្សខ្មែររួបរួមជាតិ** អនុវត្តនូវគោលការណ៍ឆ្លាស់បេក្ខភាពរវាងស្ត្រីនិងបុរស យ៉ាងហោច៣០% ជាបេក្ខជនស្ត្រីសម្រាប់ការបោះឆ្នោតជាតិ ឆ្នាំ២០២៣នេះ។ គណបក្សមានការជម្រុញ និងលើកទឹកចិត្តខ្លាំងដល់ស្ត្រីមានឱកាសចូលរួមនិងបានឈរឈ្មោះជាបេក្ខជនសម្រាប់ការបោះឆ្នោតជាតិ ឆ្នាំ២០២៣។ ជាក់ស្តែងលោកស្រី**គង់ ចាន់ម៉ាលីន**គឺជាបេក្ខជនម្នាក់ឈរឈ្មោះនៅលេខរៀងទី២នៅខេត្តព្រៃវែង។
- **គណបក្សបំណងពលរដ្ឋ** ត្រៀម និងលើកទឹកចិត្តដល់ស្ត្រីនៅក្នុងគណបក្សនយោបាយ។ សម្រាប់ការដាក់បេក្ខជនស្ត្រីនៅលំដាប់លេខរៀងទី១, ទី២, និងទី៣ គណបក្សមិនប្រកាន់ទេឱ្យតែស្ត្រីជាវីរៈនារីក្លាហានគ្រប់បែបយ៉ាង។
- **គណបក្សកែទម្រង់កម្ពុជា** មានការដាក់ចំនួនស្ត្រីនៅគ្រប់តំណែងនៃគណៈកម្មាធិការនាយក និងគណៈកម្មាធិការអចិន្ត្រៃយ៍ ដោយ៣០%ជាស្ត្រីនៃចំនួនស្ត្រីនៅក្នុងគណបក្ស ដោយមានប្រធានចលនាថ្នាក់ជាតិជាស្ត្រី ការបណ្តុះបណ្តាលអ្នកឈរឈ្មោះជាស្ត្រី។ សម្រាប់បេក្ខភាពស្ត្រីឈរឈ្មោះបោះឆ្នោតតំណាងរាស្ត្រនាពេលខាងមុខ គណបក្សកំពុងតែស្វែងរកស្ត្រីបន្ថែម។
- **គណបក្សខ្មែរតែមួយ** បញ្ហាដែលស្ត្រីមានគម្លាតឆ្ងាយដោយសារតែបុរសមានអាទិភាពជាងស្ត្រី។ គណបក្សនៅតែបន្តនីតិវិធីដោយមានការលើកទឹកចិត្ត ជម្រុញឱ្យស្ត្រីមានឱកាសឈរឈ្មោះជាបេក្ខភាពតំណាងរាស្ត្រឱ្យច្រើនជាងបុរស ហើយធ្វើបែបនេះមិនមែនជាការអូសទាញទេ គឺជាការស្ម័គ្រចិត្ត។
- **គណបក្សកម្លាំងប្រជាធិបតេយ្យ** បានជម្រុញស្ត្រីតាមរយៈការជួយឧបត្ថម្ភទៅដល់គ្រួសារគាត់ ការផ្តល់ឱកាស និងការបណ្តុះបណ្តាលស្ត្រីធ្វើយ៉ាងណាឱ្យមាន៥០% ជាបេក្ខជនស្ត្រី។

- អ្នកចូលរួមពីអង្គការសង្គមស៊ីវិល បានស្នើឱ្យមាន «ប្រព័ន្ធគាំទ្រស្ត្រី» គឺសំខាន់ ទាំងកម្រិតគណបក្សនយោបាយ និងការដឹកនាំក្នុងវិស័យសាធារណៈ ប្រយោជន៍ស្ត្រីមានលទ្ធភាពចូលរួមកាន់តែច្រើន តាមរយៈការផ្តល់ឱកាសដល់ស្ត្រីបានចូលរួម ផ្តល់ឱកាសដល់ស្ត្រីបានឈរឈ្មោះជាបេក្ខជន និងជាអ្នកដឹកនាំគ្រប់កម្រិត ផ្តល់ការបណ្តុះបណ្តាលស្ត្រី ព្រោះយើងទាំងស្ត្រី ទាំងបុរសនឹងមិនមានសមត្ថភាពទេ ប្រសិនបើមិនមានការផ្តល់ឱកាសការងារ ផ្តល់ឱកាសបានក្លាយជាអ្នកដឹកនាំ។
- តំណាងគ.ជ.ប លោកបានថ្លែងថា គ.ជ.បអនុវត្តនិងផ្អែកតាមច្បាប់បោះឆ្នោត មិនអាចបង្កើតបទបញ្ជា និងនីតិវិធីបោះឆ្នោតផ្ទុយពីច្បាប់បោះឆ្នោតឡើយ។

វិធានការពិសេសនានា ដូចជា គោលនយោបាយសមភាពយេនឌ័រ ច្បាប់បោះឆ្នោតឆ្លើយតបនឹងយេនឌ័រ ការកំណត់ចំនួនកូតាជាក់លាក់ ការអនុវត្តនូវការដាក់ឆ្លាស់គ្នារវាងបេក្ខជនស្ត្រីនិងបុរស ការមានកញ្ចប់ថវិកាសម្រាប់កិច្ចការយេនឌ័រ គឺជា**ឧបករណ៍ដ៏សំខាន់។** បន្ថែមពីនេះ ការ**ប្តេជ្ញាចិត្តខ្ពស់**របស់អ្នកដឹកនាំទាំងគណបក្សនយោបាយ និងរដ្ឋាភិបាល និង**ឆន្ទៈនយោបាយ**ក្នុងការគាំទ្រ គឺជា**កត្តាចាំបាច់**ដើម្បីពន្លឿនក្នុងការបង្កើនបេក្ខជនស្ត្រី និងស្ត្រីជាប់ឆ្នោត និងមានសមភាពយេនឌ័រពិតប្រាកដនៅក្នុងដំណើរការប្រជាធិបតេយ្យ សេរី ពហុបក្ស ដែលអនុវត្តនូវប្រព័ន្ធសមាមាត្រក្នុងការបោះឆ្នោតនៅប្រទេសកម្ពុជា ជាពិសេសសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ នេះ។

មុនការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ និងមុនការចុះបញ្ជីគណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោត ក្រុមស្ត្រីដើម្បីទាំងអស់គ្នានៃអង្គការសង្គមស៊ីវិល រួមមាន អង្គការខុមហ្វ្រែល, អង្គការសីលការកម្ពុជា, អង្គការយេនឌ័រនិងអភិវឌ្ឍដើម្បីកម្ពុជា, អង្គការបន្ទាយស្រី និងទីប្រឹក្សាឯករាជ្យផ្នែកយេនឌ័រ បានធ្វើការស្នើណាត់ជួបដើម្បីស្វែងរកមតិគាំទ្រជាមួយស្ថាប័ន និងគណបក្សដែលមានសក្តានុពលដើម្បីពិភាក្សានិងចែករំលែកអនុសាសន៍មួយចំនួនក្នុងការបង្កើនសមភាពយេនឌ័រក្នុងវិស័យនយោបាយ ដូចជា រដ្ឋសភាជាតិ គ.ជ.ប គណបក្សប្រជាជនកម្ពុជា និងគណបក្សភ្លើងទៀន ប៉ុន្តែរដ្ឋសភាជាតិមិនអនុញ្ញាតិឱ្យក្រុមការងារស្ត្រីបានជួបពិភាក្សាឡើយ ដោយហេតុផលជាប់រវល់បេសកកម្មក្រៅប្រទេស។ ចំណែកឯគណបក្សប្រជាជនកម្ពុជា មិនមានការឆ្លើយតបអ្វីទាំងអស់។

លទ្ធផលនៃការជួបពិភាក្សា ស្វែងរកមតិគាំទ្រជាមួយប្រធានគ.ជ.បនិងថ្នាក់ដឹកនាំជាន់ខ្ពស់ និងថ្នាក់ដឹកនាំនៃគណបក្សភ្លើងទៀន ក្រុមស្ត្រីដើម្បីទាំងអស់គ្នាបានកត់សម្គាល់ថា **ប្រធានគ.ជ.បមាន**ការចាប់អារម្មណ៍ក្នុងការលើកកម្ពស់ស្ត្រី ហើយស្ថាប័ន**គ.ជ.ប**ក៏មានការលើកទឹកចិត្ត និងផ្តល់អាទិភាពចំពោះស្ត្រីក្នុងការបម្រើការងារនៅក្នុងវិស័យបោះឆ្នោតផងដែរ ។ **ឯកឧត្តមប្រធាន**បានលើកឡើងថា « **គ.ជ.ប** គឺជាស្ថាប័នអនុវត្តច្បាប់។ **គ.ជ.ប** មិនមានសិទ្ធិអំណាចអ្វីក្នុងការស្នើធ្វើវិសោធនកម្មច្បាប់បោះឆ្នោតឆ្លើយតបនឹងយេនឌ័រឡើយ ដោយ**គ.ជ.ប**ត្រូវបំពេញការងាររបស់ខ្លួនឱ្យស្របទៅតាមច្បាប់ បទបញ្ជា និងនីតិវិធី ផែនការមេ និងប្រតិទិនការងារ ដើម្បីធានាឱ្យការបោះឆ្នោតប្រព្រឹត្តិទៅដោយរលូន សេរី ត្រឹមត្រូវ និងយុត្តិធម៌។ ទោះបីជាយ៉ាងណាក៏ដោយ **ឯកឧត្តមប្រធានគ.ជ.ប** *«បានលើកទឹកចិត្តទៅដល់គ្រប់គណបក្សនយោបាយទាំងអស់ដាក់បេក្ខភាពស្ត្រីឱ្យបានច្រើនសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ នាពេលខាងមុខ*

*នេះ*»។ ប្រធាន**គ.ជ.ប** មានចំណាប់អារម្មណ៍បន្ថែមទៀតថា «**ការដាក់បេក្ខជនស្ត្រីច្រើន ខ្លាចប៉ះពាល់សម្លេងឆ្នោត**»។ ឆ្លើយតបនឹងចំណាប់អារម្មណ៍របស់ប្រធាន**គ.ជ.ប**នេះ ក្រុមស្ត្រីដើម្បីស្ត្រីទាំងអស់គ្នាមើលឃើញថា ការលើកឡើងនេះគឺជាការយល់ខុសហើយមិនទាន់យល់ដឹងស៊ីជម្រៅអំពីសមភាពយេនឌ័រ និងជាការវិនិច្ឆ័យខុសឆ្គងមួយ ពីព្រោះ**សម្លេងឆ្នោត**របស់គណបក្ស **កើន ឬ ថយចុះ** វាមិនអាស្រ័យលើបេក្ខជនស្ត្រីឡើយ ពីព្រោះអ្នកបោះឆ្នោតមិនសូវមានទំលាប់មើលទៅលើបេក្ខជនស្ត្រី ឬ បុរសនៅពេលគេបោះឆ្នោតឱ្យគណបក្សណាមួយដែលខ្លួនស្រឡាញ់ពេញចិត្ត។ ផ្ទុយទៅវិញ**សម្លេងឆ្នោត**របស់គណបក្ស **កើន ឬ ថយចុះ** វាទាក់ទងនឹង**ប្រជាប្រិយភាពគណបក្ស សក្តានុពលគណបក្ស កម្មវិធីនយោបាយរបស់គណបក្ស** និង**កេរ្តិ៍ឈ្មោះរបស់ប្រធានគណបក្ស**នោះជាកត្តាសំខាន់។ បន្ថែមលើនេះ ក្រុមស្ត្រីដើម្បីស្ត្រីទាំងអស់គ្នាមើលឃើញថា **គ.ជ.ប** នៅតែជាតួអង្គសំខាន់ក្នុងការបង្កើតគំនិតផ្តួចផ្តើម និងចូលរួមជម្រុញការស្នើធ្វើវិសោធនកម្មច្បាប់បោះឆ្នោតប្រយោជន៍ធានានូវសមភាពយេនឌ័រក្នុងការបោះឆ្នោត ជាពិសេសគាំទ្រ និងរិះរកគ្រប់មធ្យោបាយដើម្បីជួយស្ត្រីឱ្យមានឱកាសបានឈរឈ្មោះជាបេក្ខជន និងបានជាប់ឆ្នោតច្រើន ដោយហេតុផលថា **គ.ជ.ប**ជាអ្នកអនុវត្តច្បាប់បោះឆ្នោតដោយផ្ទាល់ ជាអ្នកធ្វើកិច្ចការបោះឆ្នោត ហើយវាជាការងាររបស់**គ.ជ.ប**ដែលត្រូវយកចិត្តទុកដាក់ចូលរួមបង្កើនវត្តមានតំណាងស្ត្រីជាប់ឆ្នោតជាអ្នកដឹកនាំ ស្របនឹងអនុសញ្ញាស៊ី-ដរ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពដែលកម្ពុជាបានទទួលយក និងជាកាតព្វកិច្ចរដ្ឋភាគី។

ចំណែកឯគណបក្សភ្លើងទៀន ចង់ដាក់បេក្ខជនស្ត្រី៣០%ក្នុងការបោះឆ្នោតជាតិ ឆ្នាំ២០២៣ ប៉ុន្តែមានផលលំបាកក្នុងការស្វែងរកស្ត្រីចូលរួម ដោយហេតុផលមួយចំនួនដូចជា ការប្រើប្រាស់ខាងផ្នែកតុលាការដាក់បន្ទុកលើស្ត្រី និងដាក់សម្ពាធគ្រប់បែបយ៉ាងមកលើស្ត្រីដែលចូលរួមជាមួយគណបក្សប្រឆាំង, ស្ត្រីខ្លះមានការបាក់ទឹកចិត្តពេលឃើញបរិយាកាសនយោបាយមិនសូវអំណោយផលចំពោះគណបក្សប្រឆាំង, កត្តាជីវភាពរបស់ស្ត្រីដែលពិបាកក្នុងការចូលរួមឈរឈ្មោះជាបេក្ខជន ដោយសារមានតម្រូវការថវិកាពីគណបក្សចំពោះបេក្ខជនស្ត្រីនិងបេក្ខជនបុរស ម្នាក់ៗត្រូវចូលរួមចំណែកថវិកាជាមធ្យមពី **២៥.០០០ ដុល្លារអាមេរិក** ទៅ **៣០.០០០ដុល្លារអាមេរិក** សម្រាប់ការធ្វើយុទ្ធនាការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣។ ជាមួយគ្នានេះដែរ គណបក្សភ្លើងទៀនមានការជម្រុញលើកទឹកចិត្ត និងជួយថវិកាដល់បេក្ខជនស្ត្រីឈរឈ្មោះនៅលេខរៀងទី១ ចំនួន **៣០០ ដុល្លារអាមេរិក** ហើយគណបក្សកំពុងស្វែងរកថវិកា ដើម្បីជួយឱ្យក្រុមចលនាស្ត្រីអាចធ្វើកម្មវិធីជម្រុញស្ត្រី ជួយពង្រឹងស្ត្រីទាំងស្មារតីនិងសមត្ថភាព។ គណបក្សបានបញ្ជាក់ថា កន្លងមកមានស្ត្រីច្រើនមានសមត្ថភាព គុណភាព ប៉ុន្តែ៥ឆ្នាំក្រោយមកស្ត្រីទាំងនោះនៅមានភាពស្ទាក់ស្ទើរក្នុងការចូលរួមក្នុងនយោបាយ ជាពិសេសចូលរួមជាមួយគណបក្សភ្លើងទៀន។ ទោះបីយ៉ាងណា គណបក្សនេះមិនមានឱកាសចូលរួមប្រកួតប្រជែងការបោះឆ្នោតជាតិឆ្នាំ២០២៣ឡើយ ដោយមានបញ្ហាប្រឈមមួយចំនួនក្នុងដំណាក់កាលនៃការចុះបញ្ជីគណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោត។

ក្រុមស្ត្រីដើម្បីទាំងអស់គ្នានៃអង្គការសង្គមស៊ីវិល បានផ្តល់នូវអនុសាសន៍មួយចំនួន ដូចជា ស្នើធ្វើវិសោធនកម្មច្បាប់បោះឆ្នោតឆ្លើយតបនឹងយេនឌ័រដែលមានចែងពីវិធានការពិសេសដើម្បីលើកកម្ពស់សមភាព

យេនឌ័រ និងផ្ដល់ឱកាសឱ្យស្ត្រីចូលរួមដោយស្មើភាពនៅក្នុងវិស័យនយោបាយ តាមរយៈការជំរុញលើកទឹកចិត្តគ្រប់គណបក្សនយោបាយដាក់បេក្ខភាពស្ត្រីច្រើនក្នុងបញ្ជីបេក្ខជនឈរឈ្មោះរបស់គណបក្ស។

**ក-** វិសោធនកម្មច្បាប់បោះឆ្នោត ដើម្បីកែលម្អបន្ថែមលក្ខខណ្ឌនៃការដាក់ពាក្យចុះឈ្មោះបញ្ជីបេក្ខជននៃគណបក្សនយោបាយ ដែលតម្រូវឱ្យដាក់ឆ្លាស់គ្នារវាងបេក្ខជនស្ត្រី និងបុរសតាមលំដាប់លេខរៀងពីលើ ដល់ ក្រោមនៅក្នុងបញ្ជីបេក្ខជនឈរឈ្មោះរបស់គណបក្សនយោបាយ។

**ខ-** ធ្វើវិសោធនកម្មច្បាប់បោះឆ្នោតមានដូចជា ច្បាប់ ស្តីពី ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ **ជំពូកទី៤ មាត្រា២៧ និងមាត្រា២៨** «***បញ្ជីបេក្ខជនឈរឈ្មោះតាមមណ្ឌលនីមួយៗ ត្រូវមានបេក្ខជនស្ត្រី និងបេក្ខជនបុរសឆ្លាស់គ្នាតាមលំដាប់លេខរៀងពី លើ ដល់ ក្រោម***» និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ **ជំពូកទី៦ មាត្រា៣៩** «***បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ត្រូវមានឈ្មោះបេក្ខជនតាមលំដាប់លេខរៀង និងឆ្លាស់គ្នារវាងស្ត្រី និងបុរសពី លើ ដល់ ក្រោម*** »។

ចំណែកឯ ការបង្កើតនិងអនុវត្ត**គោលនយោបាយសមភាពយេនឌ័រនៅក្នុងគណបក្សនយោបាយ** គឺជាវិធានការបន្ទាន់មួយក្នុងការបង្កើនចំនួនបេក្ខជនស្ត្រី និងចំនួនស្ត្រីនៅក្នុងក្រុមប្រឹក្សាភិបាលផ្ទៃក្នុងគណបក្ស និងក្នុងរចនាសម្ព័ន្ធធ្វើសេចក្ដីសម្រេចផ្សេងទៀតនៅក្នុងគណបក្ស ។ បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗត្រូវជានាដាក់ឆ្លាស់គ្នារវាងបេក្ខជនស្ត្រី និងបេក្ខជនបុរសតាមលំដាប់លេខរៀងពីលើដល់ក្រោម។

លទ្ធផលពីការស្វែងរកការគាំទ្រមតិតាមរយៈសិក្ខាសាលាពិគ្រោះយោបល់ និងការជួបប្រជុំជាមួយអ្នកពាក់ព័ន្ធសំខាន់ៗ គឺមាន **៩ គណបក្ស (៥០%)** ក្នុងចំណោម **១៨**គណបក្ស បានដាក់បេក្ខជនស្ត្រីឈរឈ្មោះចន្លោះពី **៣៦,២% ទៅ ៨០,៩%** នៅក្នុងបញ្ជីបេក្ខជនឈរឈ្មោះរបស់គណបក្សខ្លួន សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣។ ចំនួននេះមាន**ភាពប្រសើរជាងមុន** បើធៀបនឹងនីតិកាលទី៦ ឆ្នាំ២០១៨ មានតែ **៧ គណបក្ស (៣៥%)** ក្នុងចំណោម២០គណបក្សនយោបាយ។ គួរកត់សម្គាល់ថា ដោយសារគណបក្សពីរដែលទទួលបានសម្លេងឆ្នោតគាំទ្រច្រើនជាងគេ និងបានទទួលអាសនៈនៅក្នុងរដ្ឋសភា គឺ **គណបក្សប្រជាជនកម្ពុជា** និង**គណបក្សហ៊្វុនស៊ិនប៉ិច** បានដាក់បេក្ខជនស្ត្រី **តិចជាងគេ** ជាមូលហេតុនាំឱ្យស្ត្រីជាប់ឆ្នោតមានចំនួន**តិចនិងធ្លាក់ចុះ** និងមាន**គម្លាតគ្នាឆ្ងាយ**រវាងតំណាងស្ត្រីជាប់ឆ្នោត និងតំណាងបុរសជាប់ឆ្នោត។

គណបក្សនយោបាយមួយចំនួនដែលចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧នេះ បានលើកឡើង អំពី របៀបនៃការជ្រើសរើសបេក្ខជនស្ត្រី-បុរស និងអំពីតម្រូវការថវិកាទាក់ទិននឹងការតែងតាំងបេក្ខជនឈរឈ្មោះ និងលក្ខខណ្ឌមួយចំនួនក្នុងការឈរឈ្មោះជាបេក្ខជន ដូចជា **សមត្ថភាព ចំណេះដឹង បទពិសោធ ប្រជាប្រិយភាព ការយកចិត្តទុកដាក់លើការងារ និងស្នាដៃក្នុងកិច្ចការងារសង្គម ត្រូវសកម្ម មានភាពក្លាហានក្នុងការបញ្ចេញមតិ មានបណ្តាញការងារ មានមនសិកា**។ តម្រូវការថវិកានេះ គឺសម្រាប់ចំណាយលើយុទ្ធនាការឃោសនាបោះឆ្នាត ។ ដូច្នេះ គណបក្សខ្លះមានការកំណត់ចំនួនថវិកាសម្រាប់ការឈរឈ្មោះ ជាពិសេសឈរឈ្មោះនៅលេខរៀងខាងលើ។ រីឯគណបក្សខ្លះទៀតបាន

ស្នើសមាជិកបក្សបរិច្ចាគថវិកាដោយស្ម័គ្រចិត្ត ឬ តាមលទ្ធភាពរបស់ខ្លួនដោយមិនមានការកំណត់ចំនួនថវិកាជាក់លាក់សម្រាប់ការឈរឈ្មោះឡើយ។ ចំណែកគណបក្សខ្លះមិនតម្រូវឱ្យបេក្ខជនចំណាយថវិកាផ្ទាល់ខ្លួនឡើយ គឺគណបក្សជាអ្នកចាត់ចែងរាល់ការចំណាយទាំងអស់។

របាយការណ៍សម្ភាសន៍បេក្ខជនស្ត្រី និងបេក្ខជនបុរសឬ/និងតំណាងគណបក្សនយោបាយជាបុរស អំពី **ការចូលរួមរបស់ស្ត្រីនៅក្នុងគណបក្សសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣**របស់ខុមហ្វ្រែល ឆ្នាំ២០២៣ បានរកឃើញថា **គណបក្សខ្មែរតែមួយ**មានការជ្រើសរើសបេក្ខជនគឺផ្អែកលើការប្រជុំគណៈកម្មការអចិន្ត្រៃយ៍ និងធ្វើការវាយតម្លៃតាមខេត្តនីមួយៗដើម្បីជ្រើសរើសចំនួនបេក្ខជនស្ត្រី និងបុរស ។ **គណបក្សខ្មែរតែមួយ** មានគោលការណ៍ផ្តល់អាទិភាពដល់បេក្ខជនស្ត្រី ការបង្កើននិងលើកកម្ពស់ចំនួនស្ត្រីឱ្យមានភាពសកម្មកាន់តែច្រើនក្នុងវិស័យនយោបាយ។ ទោះបីយ៉ាងណា ការដាក់បេក្ខភាពស្ត្រីឈរឈ្មោះនៅលេខរៀងខាងលើ គឺត្រូវផ្អែកលើលក្ខខណ្ឌមួយចំនួន ដូចជា **កម្រិតចំណេះដឹង ភាពសកម្មភាពក្លាហានក្នុងការបញ្ចេញមតិ មានបណ្តាញការងារ បេក្ខជនរួសរាយរាក់ទាក់ជាមួយអ្នកជុំវិញខ្លួន**។ បេក្ខជនម្នាក់ៗមិនមានការចំណាយថវិកាផ្ទាល់ខ្លួនទេ គឺគណបក្សជាអ្នកចាត់ចែងរាល់ការចំណាយទាំងអស់។ ជាលទ្ធផលបេក្ខជនស្ត្រីមានចំនួនច្រើន **៦១,៦%** ខណៈដែលបេក្ខជនបុរសមានចំនួនតែ **៣៨,៤%**ប៉ុណ្ណោះ ហើយបេក្ខជនស្ត្រី ៣២% បានឈរឈ្មោះនៅលេខរៀងទី១។

ការជ្រើសរើសបេក្ខជនស្ត្រី-បុរសនៃ**គណបក្សប្រជាជនកម្ពុជា** គឺធ្វើឡើងដោយផ្អែកលើគោលការណ៍ប្រជាធិបតេយ្យ ត្រូវមានការពិភាក្សានិងធ្វើការសម្រេចចិត្តនៅផ្ទៃក្នុងគណបក្សនយោបាយ។ ការដាក់បេក្ខជនឈរឈ្មោះនៅលេខរៀងខាងលើគឺត្រូវផ្អែកលើ **ចំណេះដឹង បទពិសោធ ប្រជាប្រិយភាព ការយកចិត្តទុកដាក់លើការងារ និងស្នាដៃក្នុងកិច្ចការងារសង្គម**។ បេក្ខជនត្រូវបរិច្ចាគថវិកាតាមលំដាប់លេខរៀងឈរឈ្មោះពីលេខរៀងទី១ ដល់ ទី៣ គឺមានចំនួនថវិកា**ច្រើនជាង**នីតិកាលមុនៗ[12]។ គណបក្សប្រជាជនកម្ពុជាមានគោលនយោបាយលើកកម្ពស់សមភាពយេនឌ័រ ដើម្បីលើកទឹកចិត្តស្ត្រី ផ្តល់ឱកាសឱ្យស្ត្រីតាំងពីថ្នាក់ជាតិរហូតដល់ថ្នាក់មូលដ្ឋាន ដោយមិនមានការរើសអើងស្ត្រីឡើយ។

ដោយហេតុ គណបក្សប្រជាជនកម្ពុជាពុំមានវិធានការពិសេសជាក់លាក់សម្រាប់បេក្ខជនស្ត្រី រួមនឹងការចំណាយថវិកាដ៏ច្រើនសម្រាប់ការឈរឈ្មោះជាបេក្ខជនដែលស្ត្រីត្រូវប្រកួតប្រជែងជាមួយបុរសភាគច្រើនមានលទ្ធភាពថវិកាខ្ពស់ជាង ព្រមទាំងអ្នកដឹកនាំគណបក្សមិនជម្រុញឱ្យមានការអនុវត្តគោលនយោបាយលើកកម្ពស់សមភាពយេនឌ័ររបស់ខ្លួនដោយប្រសិទ្ធភាព។ ជាលទ្ធផលចំនួនបេក្ខជនស្ត្រី មានតិច ត្រឹមតែ **១២,៨%** គឺ ថយចុះបើធៀប នឹងនីតិកាលទី៦ ឆ្នាំ២០១៨ បេក្ខជនស្ត្រីមានចំនួន ១៥,២% ហើយចំនួននេះកាន់តែតិចតួចបំផុត បើធៀបនឹងគណបក្សភាគច្រើនផ្សេងទៀតដែលចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣នេះ។ ចំណែកបេក្ខជនស្ត្រីឈរឈ្មោះនៅលេខរៀងទី១ មានចំនួនតែ **៤%** ប៉ុណ្ណោះ ខណៈដែលបេក្ខជនបុរសមានច្រើនលើសលុប **៩៦%**។

---

[12] របាយការណ៍ខុមហ្វ្រែលស្តីពីការផ្តល់អំណាចនយោបាយដល់ស្ត្រី និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ និងនីតិកាលទី៦ ឆ្នាំ២០១៨

រីឯការជ្រើសរើសបេក្ខជនស្ត្រី-បុរសរបស់**គណបក្សឯកភាពជាតិខ្មែរ** ធ្វើឡើងដោយផ្អែកលើការស្ម័គ្រចិត្តក្នុងការឈរឈ្មោះ និងមានការបោះឆ្នោតដាក់លេខរៀងដោយធ្វើការសម្រេចចិត្តរួម **២/៣**។ លក្ខខណ្ឌក្នុងការដាក់បេក្ខជនស្ត្រីឈរឈ្មោះនៅលេខរៀងទី១ គឺត្រូវមាន **បទពិសោធ ស្នាដៃ ចំណេះដឹង សកម្មជាងគេ**។ នៅក្នុងគណបក្សមិនមានការរើសអើងស្ត្រី មានតែផ្តល់សិទ្ធិដល់ស្ត្រី ប៉ុន្តែមិនទាន់មានគោលការណ៍កំណត់ចំនួនជាក់លាក់ក្នុងការដាក់បេក្ខជនស្ត្រីឈរឈ្មោះឡើយ។ សម្រាប់បេក្ខជនឈរឈ្មោះ គឺមិនមានការកំណត់ក្នុងការចំណាយថវិកានោះទេ ប៉ុន្តែពេលចុះធ្វើសកម្មភាពឃោសនាបេក្ខជនត្រូវចំណាយថវិកាតាមលទ្ធភាពរបស់ខ្លួន។ ការផ្អែកលើលក្ខខណ្ឌ និងពុំទាន់មានគោលការណ៍ជាក់លាក់ ជាលទ្ធផល**គណបក្សឯកភាពជាតិខ្មែរ** មានបេក្ខជនស្ត្រីតែ **១៩,១%** និងបេក្ខជនបុរសមានច្រើនលើសលុប **៨០,៩%** ហើយពុំមានបេក្ខជនស្ត្រីណាម្នាក់បានឈរឈ្មោះនៅលេខរៀងទី១ឡើយ។

ការជ្រើសរើសបេក្ខជននិងការដាក់បេក្ខជនៅលេខរៀងខាងលើនៃ**គណបក្សបំណងពលរដ្ឋ** ធ្វើឡើងដោយឈរលើមូលដ្ឋាន និងលក្ខខណ្ឌដូចជា **មានបទសោធ សមត្ថភាព ចំណេះដឹង កិច្ចការងារសង្គម ធ្វើការដោយប្រសិទ្ធភាព មានមនសិកា និងប្រជាប្រិយភាព**។ នៅក្នុង**គណបក្សបំណងពលរដ្ឋ**មានគោលនយោបាយសមភាពយេនឌ័រដើម្បីលើកទឹកចិត្តស្ត្រី គឺ ចង់បានឱ្យស្ត្រីចូលរួមមិនថាក្រុមណាក៏ដោយដែលអាចចូលរួមបាន គឺគណបក្សផ្តល់ឱកាសឱ្យចូលរួម។ បេក្ខជនមិនមានការចំណាយថវិកាដើម្បីបានឈរឈ្មោះនោះទេ ប៉ុន្តែ ពេលចុះធ្វើសកម្មភាពឃោសនាបោះឆ្នោតបេក្ខជននីមួយៗត្រូវចំណាយថវិកាតាមលទ្ធភាពរបស់ខ្លួន។ ដោយសារ គណបក្សមានគោលនយោបាយសមភាពយេនឌ័រ ប៉ុន្តែលក្ខខណ្ឌនៃការជ្រើសបេក្ខជនបែរជាឧបសគ្គចំពោះស្ត្រីទៅវិញ ជាលទ្ធផល **គណបក្សបំណងពលរដ្ឋ**មានបេក្ខជនស្ត្រីចំនួនច្រើនគួរសម **៣៧,៨%** និងបេក្ខជនបុរសចំនួន **៦២,២%**។ ចំណែកបេក្ខជនឈរឈ្មោះនៅ**លេខរៀងទី១** គឺមាន**គម្លាតគ្នាយ៉ាងខ្លាំង**រវាងស្ត្រី និងបុរស ដោយបេក្ខជនស្ត្រីមានភាគរយតិចតួច **១១,១%** និងបេក្ខជនបុរសមានចំនួនភាគរយលើសលុប **៨៨,៩%**។

ដោយឡែក ការជ្រើសរើសបេក្ខជនរបស់**គណបក្សស្ត្រីដើម្បីស្ត្រី**ធ្វើឡើងដោយស្ម័គ្រចិត្ត ចូលរួមដោយក្តីស្រលាញ់ គ្មានការបោះឆ្នោតផ្ទៃក្នុង។ ការដាក់បេក្ខជនស្ត្រីនៅលេខរៀងខាងលើគឺដើម្បីលើកតម្កើងចំនួនស្ត្រីនៅក្នុងនយោបាយ។ ក្នុងការដាក់បេក្ខភាពស្ត្រី-បុរសឈរឈ្មោះនៅលេខរៀងខាងលើ ត្រូវផ្អែកលើលក្ខខណ្ឌដូចជា **ត្រូវមានបេះដូងស្រលាញ់ស្នេហាជាតិ ជួយជាតិនិងសង្គម ត្រូវមានចំណេះដឹង សមត្ថភាព សកម្មក្នុងការចូលរួមធ្វើនយោបាយ មានទឹកចិត្ត ដាក់ចិត្តដាក់កាយធ្វើការរួមគ្នាដោយប្រើបេះដូង ត្រូវមានពេលវេលាគ្រប់គ្រាន់**។ គណបក្សមានគោលនយោបាយសមភាពយេនឌ័រដើម្បីលើកទឹកចិត្តស្ត្រី មានការបណ្តុះបណ្តាលដល់បេក្ខជនស្ត្រីបន្ថែម។ នៅក្នុង**គណបក្សស្ត្រីដើម្បីស្ត្រី**គ្មានការរើសអើងមកលើសកម្មជនស្ត្រីទេ គឺមានតែការស្វាគមន៍ ការលើកកម្ពស់ស្ត្រីនិងបុរសឱ្យមានភាពស្មើគ្នាក្នុងការចូលរួមធ្វើនយោបាយ និងគ្មានការរារាំងចំពោះការបញ្ចេញមតិរបស់ស្ត្រីឡើយ។ បេក្ខជននីមួយៗមិនមានការចំណាយថវិកាផ្ទាល់ខ្លួនដើម្បីបានឈរឈ្មោះជាបេក្ខជនទេ ដោយគណបក្សជាអ្នកចំណាយទាំងអស់រាល់ការធ្វើសកម្មភាពនយោបាយ និងការឃោសនាបោះឆ្នោត។

ដោយសារ**គណបក្សស្ត្រីដើម្បីស្ត្រី**មានអ្នកដឹកនាំជាស្ត្រី មានគោលនយោបាយសមភាពយេនឌ័រនៅក្នុងបក្ស និងការដាក់បេក្ខជនស្ត្រីនៅលេខរៀងខាងលើដើម្បីបង្កើនចំនួនស្ត្រី ជាលទ្ធផលគណបក្សនេះមានបេក្ខជនស្ត្រីច្រើនលើសលុប**៨០,៩%** ខណៈដែលបេក្ខជនបុរស មានតិចតួច **១៩,១%** ។ ចំណែកបេក្ខជនស្ត្រីឈរឈ្មោះនៅលេខរៀងទី១ ក៏មានច្រើនដែរ **៧៧,៨%**។

**គណបក្សកម្លាំងប្រជាធិបតេយ្យ** ធ្វើការជ្រើសរើសបេក្ខជនឈរឈ្មោះមានការបោះឆ្នោតផ្ទៃក្នុង ប្រជុំនិងវិភាគពិចារណាជាមួយគណៈកម្មការអចិន្ត្រៃយ៍ សិក្សាលើចំណេះដឹង មានការលើកទឹកចិត្តចំពោះបេក្ខជនបេក្ខជនជានិស្សិត និងបុគ្គលិកក្រុមហ៊ុនអាចចូលរួមឈរឈ្មោះជាបេក្ខជនបាន ដោយត្រូវមានបទពិសោធការងារជាអ្នកនយោបាយ (ធ្លាប់ធ្វើនយោបាយនិងមានការយល់ដឹងអំពីនយោបាយ)។ ចំពោះការដាក់បេក្ខភាពស្ត្រីឈរឈ្មោះនៅលេខរៀងខាងលើ ត្រូវផ្អែកលើលក្ខខណ្ឌដូចជា **មានសមត្ថភាព មិនជាប់ពាក់ព័ន្ធជាមួយគណបក្សនយោបាយដទៃ ស្រលាញ់និងមានគុណធម៌ យុត្តិធម៌ មានលក្ខណៈសម្បត្តិល្អ រឹងមាំ រហ័សរហួនទាំងការបញ្ចេញមតិ**។ ចំពោះចំណេះដឹងមិនកំណត់តឹងតែងពេក ព្រោះគណបក្សកម្លាំងប្រជាធិបតេយ្យនឹងមានការបណ្តុះបណ្តាលបន្ថែម ដើម្បីពង្រឹងសមត្ថភាព។ នៅក្នុងគណបក្សមានការរើសអើងដោយគិតថាស្ត្រីជាមនុស្សទន់ខ្សោយ (វាយតម្លៃស្ត្រីទាំងមិនទាន់ដឹងពីសមត្ថភាព) ស្ត្រីមិនអាចធ្វើអ្វីៗបានដូចបុរស។ បេក្ខជននីមួយៗមិនមានការចំណាយថវិកាផ្ទាល់ខ្លួនដើម្បីបានឈរឈ្មោះជាបេក្ខជនទេ ដោយគណបក្សជាអ្នកចំណាយទាំងអស់រាល់ការធ្វើសកម្មភាពនយោបាយ និងការឃោសនាបោះឆ្នោត។

ដោយសារ**គណបក្សកម្លាំងប្រជាធិបតេយ្យ**មានការលើកទឹកចិត្តចំពោះបេក្ខជន បេក្ខជនជានិស្សិត និងបុគ្គលិកក្រុមហ៊ុនអាចចូលរួមឈរឈ្មោះជាបេក្ខជន និងមិនមានការផ្តោតសំខាន់ទៅលើតែចំណេះដឹង ជាលទ្ធផល គណបក្សនេះមានបេក្ខជនស្ត្រី-បុរសមានគម្លាតតិចតួចគឺ បេក្ខជនស្ត្រី **៤៥,៥%** ឯបេក្ខជនបុរស **៥៤,៥%** ។ ប៉ុន្តែ ដោយមានការរើសអើងចំពោះស្ត្រីនៅក្នុងបក្ស គណបក្សនេះមានបេក្ខជនស្ត្រីឈរឈ្មោះនៅលេខរៀងទី១ តិចតួច**១៦,៧%** ខណៈដែលបេក្ខជនបុរសមានច្រើនលើសលុប **៨៣,៣%**។

តារាងទី១ ៖ ចំនួនបេក្ខជនស្ត្រី-បុរសឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ទាំង១៨ គណបក្ស

| ល.រ | គណបក្សនយោបាយ | បេក្ខជនឈរឈ្មោះពេញសិទ្ធិ | | | | | |
|---|---|---|---|---|---|---|---|
| | | ស្ត្រី | | បុរស | | ចំនួនសរុប | ចំនួនមណ្ឌលឈរឈ្មោះ |
| | | ចំនួន | ភាគរយ | ចំនួន | ភាគរយ | | |
| ១ | សំបុកឃ្មុំសង្គមប្រជាធិបតេយ្យ | ១៥ | ២៦,៣ | ៤២ | ៧៣,៧ | ៥៧ | ៦ |
| ២ | ខ្មែរតែមួយ | ៧៧ | ៦១,៦ | ៤៨ | ៣៨,៤ | ១២៥ | ២៥ |
| ៣ | សញ្ញាតិកម្ពុជា | ២៨ | ២២,៤ | ៩៧ | ៧៧,៦ | ១២៥ | ២៥ |
| ៤ | ខ្មែររួបរួមជាតិ | ១៩ | ១៥,២ | ១០៦ | ៨៤,៨ | ១២៥ | ២៥ |
| ៥ | កម្លាំងប្រជាធិបតេយ្យ | ៣០ | ៤៥,៥ | ៣៦ | ៥៤,៥ | ៦៦ | ១២ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៦ | កសិករ | ១៩ | ៤១,៣ | ២៧ | ៥៨,៧ | ៤៦ | ៨ |
| ៧ | ស្ត្រីដើម្បីស្ត្រី | ៥៥ | ៨០,៩ | ១៣ | ១៩,១ | ៦៨ | ១៨ |
| ៨ | ខ្មែររួបរួម | ៥៦ | ៤៤,៨ | ៦៩ | ៥៥,២ | ១២៥ | ២៥ |
| ៩ | ហ្វ៊ុនស៊ិនប៉ិច | ៨ | ៦,៤ | ១១៧ | ៩៣,៦ | ១២៥ | ២៥ |
| ១០ | ធម្មាធិបតេយ្យ | ៦៣ | ៥០,៤ | ៦២ | ៤៩,៦ | ១២៥ | ២៥ |
| ១១ | ប្រជាធិបតេយ្យមូលដ្ឋាន | ១៩ | ២២,៩ | ៦៤ | ៧៧,១ | ៨៣ | ១២ |
| ១២ | បំណងពលរដ្ឋ | ១៧ | ៣៧,៨ | ២៨ | ៦២,២ | ៤៥ | ៩ |
| ១៣ | ខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច | ២១ | ៣៦,២ | ៣៧ | ៦៣,៨ | ៥៨ | ៧ |
| ១៤ | ឯកភាពជាតិខ្មែរ | ៩ | ១៩,១ | ៣៨ | ៨០,៩ | ៤៧ | ៧ |
| ១៥ | ខ្មែរអភិរក្ស | ២១ | ៤២,៩ | ២៨ | ៥៧,១ | ៤៩ | ៧ |
| ១៦ | យុវជនកម្ពុជា | ៣៤ | ២៧,២ | ៩១ | ៧២,៨ | ១២៥ | ២៥ |
| ១៧ | ជនជាតិដើមប្រជាធិបតេយ្យកម្ពុជា | ១៦ | ១៦,៨ | ៧៩ | ៨៣,២ | ៩៥ | ២២ |
| ១៨ | ប្រជាជនកម្ពុជា | ១៦ | ១២,៨ | ១០៩ | ៨៧,២ | ១២៥ | ២៥ |
| សរុប | ១៨គណបក្សនយោបាយ | ៥២៣ | ៣២,៤ | ១.០៩១ | ៦៧,៦ | | |

ប្រភព ៖ គ.ជ.ប

**ក្រាហ្វិកទី២ ៖**




ប្រភព ៖ គ.ជ.ប

## ក្រាហ្វិកទី៣ ៖ បេក្ខជនស្ត្រី និងបុរស នីតិកាលទី៧ ឆ្នាំ២០២៣ តាមគណបក្ស




ប្រភព ៖ គ.ជ.ប

មានការកើនឡើងចំនួនបេក្ខជនស្ត្រីឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ដែលជាការប្រែប្រួលវិជ្ជមានគួរឱ្យកោតសរសើរ។ ជាក់ស្តែង បេក្ខជនស្ត្រីឈរឈ្មោះមានចំនួន **សរុប ៥២៣ នាក់** ស្មើនឹង **៣២,៤%** នៃបេក្ខជនស្ត្រី-បុរស សរុប ១.៦១៤នាក់ គឺ **កើន** ចំនួន **៧,២%** ធៀបនឹងនីតិកាលទី៦ ឆ្នាំ២០១៨ មានតែ ២៥,២% ប៉ុណ្ណោះ។ ទោះបីជាយ៉ាងណា ចំនួននិងភាគរយសរុបនៃបេក្ខជនស្ត្រី និងបេក្ខជនបុរសនៅមាន **គម្លាតគ្នាឆ្ងាយ** គឺ បេក្ខជនស្ត្រីមានចំនួន ៥២៣នាក់ ស្មើនឹង **៣២,៤%** ខណៈដែលបេក្ខជនបុរសមានដល់ទៅ ១.០៩១នាក់ ស្មើនឹង **៦៧,៦%**។

បើទោះបីចំនួនបេក្ខជនស្ត្រីមានការកើនឡើងក៏ដោយ ក៏ក្រុមស្ត្រីដើម្បីទាំងអស់គ្នានៃអង្គការសង្គមស៊ីវិលមានការកត់សម្គាល់ថា គណបក្សទាំង១៨បានដាក់បេក្ខជនឈរឈ្មោះក្នុងចំនួននិងភាគរយខុសៗគ្នា ដោយគណបក្សខ្លះ**បានបង្កើន**ចំនួនបេក្ខជនស្ត្រីស្មើគ្នានឹងបេក្ខជនបុរស និងគណបក្សខ្លះទៀតបានដាក់ចំនួនបេក្ខជនស្ត្រី**ច្រើនលើស**បេក្ខជនបុរស។ ចំណែកឯគណបក្សខ្លះទៀត បែរជាដាក់ចំនួនបេក្ខជនស្ត្រី**ថយចុះ**ទៅវិញសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ នេះ។

ការដាក់បេក្ខជនឈរឈ្មោះក្នុងចំនួននិងភាគរយខុសៗគ្នាតាមគណបក្សនយោបាយនីមួយៗ ដោយសារប្រទេសកម្ពុជា**ពុំទាន់មានច្បាប់បោះឆ្នោតឆ្លើយតបនឹងយេនឌ័រ ដែលចែងពីវិធានការពិសេស**សម្រាប់ស្ត្រី និងបុរសមានឱកាសស្មើគ្នាក្នុងការឈរឈ្មោះជាបេក្ខជន។ ការដាក់បេក្ខជនតាមការស្ម័គ្ររបស់គណបក្សនេះ

បានជះឥទ្ធិពលដល់លទ្ធផលបោះឆ្នោត និងមានផលប៉ះពាល់ដល់ការចូលរួមរបស់ស្ត្រីក្នុងវិស័យនយោបាយសម្រាប់បច្ចុប្បន្ន និងនាពេលអនាគត។

ដូច្នេះ ការមានគោលនយោបាយសមភាពយេនឌ័រនៅក្នុងគណបក្សផង និងច្បាប់បោះឆ្នោតឆ្លើយតបនឹងយេនឌ័រដែលចែងពីវិធានការពិសេសផង ហើយត្រូវអនុវត្តឱ្យបានល្អនឹងក្លាយជាឧបករណ៍ដ៏សំខាន់ និងមានប្រសិទ្ធភាពសម្រាប់ស្ត្រីក្នុងការទាមទារសិទ្ធិរបស់ពួកគេ និងចាប់យកឱកាសស្មើភាពគ្នាជាបេក្ខជនឈរឈ្មោះនិងជាប់ឆ្នោត។ បន្ថែមពីនេះ ការប្តេជ្ញាចិត្តខ្ពស់របស់អ្នកដឹកនាំ និងឆន្ទៈនយោបាយក្នុងការគាំទ្រ គឺជាកត្តាចាំបាច់ដែលជម្រុញឱ្យការងារនេះទទួលបានជោគជ័យ។

### ក្រាហ្វិកទី៤ ៖ ការកើនឡើងភាគរយបេក្ខជនស្ត្រីតាមគណបក្សដែលធ្លាប់ចូលរួមប្រកួតប្រជែងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ឆ្នាំ២០១៨ ធៀបនឹងនីតិកាលទី៧ ឆ្នាំ២០២៣




ប្រភព ៖ គ.ជ.ប

គណបក្សដែលបាន**បង្កើន**បេក្ខជនស្ត្រីឈរឈ្មោះ និងច្រើនគួរឱ្យកោតសរសើរ ៖ **គណបក្សខ្មែរតែមួយ ៦១,៦%** ឆ្នាំ២០២៣ធៀបនឹងឆ្នាំ២០១៨ តែ២២,៨% **គណបក្សខ្មែរឈប់ក្រ ៤៤,៨%**ធៀបនឹងឆ្នាំ២០១៨ តែ៣៦% **គណបក្សយុវជនកម្ពុជា ២៧,២%**ធៀបនឹងឆ្នាំ២០១៨ តែ១៦,២% **គណបក្សសញ្ជាតិកម្ពុជា ២២,៤%**ធៀបនឹងឆ្នាំ២០១៨ តែ១២% **គណបក្សប្រជាធិបតេយ្យមូលដ្ឋាន ២២,៩%** ធៀបនឹងឆ្នាំ២០១៨ តែ១៧,៦% និង**គណបក្សធម្មាធិបតេយ្យ**នៅរក្សាចំនួនបេក្ខជនស្ត្រីច្រើន**៥០,៤%**។

## ក្រាហ្វិកទី៥ ៖ ការថយចុះនៃចំនួនបេក្ខជនស្ត្រីសម្រាប់ការបោះឆ្នោតនីតិកាលទី៧ ឆ្នាំ២០២៣

ប្រៀបធៀបចំនួនបេក្ខជនស្ត្រីនៃគណបក្សប្រជាជនកម្ពុជានិងហ៊្វុនស៊ិនប៉ិច
សម្រាប់ការបោះឆ្នោត នីតិកាលទី៦ និងទី៧




ប្រភព ៖ គ.ជ.ប

គណបក្ស**ចំនួនពីរ**បានដាក់ចំនួនបេក្ខជនស្ត្រី **ថយចុះ** សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ គឺ **គណបក្សប្រជាជនកម្ពុជា ១២,៨%** ឆ្នាំ២០២៣ ធៀបនឹងឆ្នាំ២០១៨ មាន ១៥,២% និង**គណបក្សហ៊្វុនស៊ិនប៉ិច ៦,៤%** ធៀបនឹងឆ្នាំ២០១៨ មាន ៧,២% ដែលជាចំនួនតិចតួចឃ្លាតឆ្ងាយពីអ្វីដែលក្រុមស្ត្រីនៃអង្គការសង្គមស៊ីវិលបានស្នើសុំដាក់ចំនួនបេក្ខជនស្ត្រីនិងបេក្ខជនបុរសឈរឈ្មោះឱ្យមានសមភាពសម្រាប់ការបោះឆ្នោតជាតិ នីតិកាលទី៧នេះ។

## ក្រាហ្វិកទី៦ ៖ គណបក្សថ្មីទើបចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោត នីតិកាលទី៧ ឆ្នាំ២០២៣

បេក្ខជនស្ត្រី តាមគណបក្ស, ការបោះឆ្នោត នីតិកាលទី៧ ឆ្នាំ២០២៣




ប្រភព ៖ គ.ជ.ប

*គណបក្សថ្មីដែលទើបតែចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោត នីតិកាលទី៧ ឆ្នាំ២០២៣នេះ* បាន ដាក់បេក្ខជនស្ត្រី**ច្រើនលើសលុប** គួរឱ្យកោតសរសើរ ដូចជា **គណបក្សស្ត្រីដើម្បីស្ត្រី** ៨០,៩% **គណបក្សកម្លាំងប្រជាធិបតេយ្យ** ៤៥,៥% **គណបក្សខ្មែរអភិវឌ្ឍ** ៤២,៩% **គណបក្សកសិករ** ៤១,៣% និង **គណបក្សបំណងពលរដ្ឋ** ៣៧,៨%។ តួលេខនេះ បង្ហាញឱ្យឃើញពីការប្តេជ្ញាចិត្តខ្ពស់របស់ប្រធានគណបក្សទាំង៥ក្នុងការលើកកម្ពស់ការចូលរួមរបស់ស្ត្រីកាន់តែច្រើនក្នុងកិច្ចការនយោបាយ ជាពិសេសការផ្តល់ឱកាសដល់ស្ត្រីក្នុងការឈរឈ្មោះជាបេក្ខជន។

**ក្រាហ្វិកទី៧ ៖ ប្រៀបធៀបចំនួនបេក្ខជនស្ត្រី និងបុរសឈរឈ្មោះសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ក្នុងនីតិកាលទី៦ និងទី៧**




បើប្រៀបធៀបនឹងនីតិកាលទី៦ ឆ្នាំ២០១៨ បេក្ខជនស្ត្រីឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ មានចំនួន **សរុប ៥២៣ នាក់** ស្មើនឹង **៣២**,៤% នៃបេក្ខជនស្ត្រី-បុរសសរុប ១.៦១៤នាក់ គឺ **កើន** ចំនួន **៧**,**២**% ធៀបនឹងនីតិកាលទី៦ ឆ្នាំ២០១៨ មានចំនួនតែ ២៥,២% ប៉ុណ្ណោះ។ ទោះបីជាយ៉ាងណាក៏ដោយ ភាគរយសរុបនៃបេក្ខជនស្ត្រី និងបេក្ខជនបុរស នៅមាន**គម្លាតឆ្ងាយ** គឺ បេក្ខជនស្ត្រីមាន **៣២,៤%** ខណៈដែលបេក្ខជនបុរសមានដល់ទៅ **៦៧,៦%** នៃនីតិកាលទី៧ ឆ្នាំ២០២៣។ ចំណែកឯនីតិកាលទី៦ ឆ្នាំ២០១៨ បេក្ខជនស្ត្រី មាន **២៥,២%** ខណៈបេក្ខជនបុរសមានចំនួនច្រើនលើសលុប **៧៤,៨%**។

## ចំនួនបេក្ខជនស្ត្រីឈរឈ្មោះពីលេខរៀងទី១ ដល់ ទី៣ សម្រាប់ការឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣

**តារាងទី៨ ៖ ចំនួនបេក្ខជនស្ត្រីឈរឈ្មោះលេខរៀងទី១, ទី២ និងទី៣ តាមគណបក្ស**

| ល.រ | គណបក្សនយោបាយ | បេក្ខជនឈរឈ្មោះពេញសិទ្ធិពីលេខរៀងទី១, ទី២ និងទី៣ | | | | | | ចំនួនមណ្ឌលឈរឈ្មោះ |
|---|---|---|---|---|---|---|---|---|
| | | ល.រទី១ | | ល.រទី២ | | ល.រទី៣ | | |
| | | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | |
| ១ | សំបុកឃ្មុំសង្គមប្រជាធិបតេយ្យ | ១ | ១៦,៧ | ៣ | ៥០ | ៣ | ៥០ | ៦ |
| ២ | ខ្មែរតែមួយ | ៨ | ៣២ | ៧ | ៤១,២ | ១២ | ៧០,៦ | ២៥ |
| ៣ | សញ្ញាតិកម្ពុជា | ១ | ៤ | ៣ | ១៧,៦ | ៦ | ៣៥,៣ | ២៥ |
| ៤ | ខ្មែររួបរួមជាតិ | ០ | ០ | ០ | ០ | ២ | ១១,៨ | ២៥ |
| ៥ | កម្លាំងប្រជាធិបតេយ្យ | ២ | ១៦,៧ | ៦ | ៦៦,៧ | ៤ | ៤៤,៤ | ១២ |
| ៦ | កសិករ | ៣ | ៣៧,៥ | ២ | ២៨,៦ | ៣ | ៤២,៩ | ៨ |
| ៧ | ស្ត្រីដើម្បីស្ត្រី | ១៤ | ៧៧,៨ | ៨ | ៨០ | ៨ | ៨០ | ១៨ |
| ៨ | ខ្មែរឈប់ក្រ | ៧ | ២៨ | ៥ | ២៩,៤ | ១១ | ៦៤,៧ | ២៥ |
| ៩ | ហ្វ៊ុនស៊ិនប៉ិច | ២ | ៨ | ០ | ០ | ២ | ១១,៨ | ២៥ |
| ១០ | ធម្មាធិបតេយ្យ | ៩ | ៣៦ | ៩ | ៥៣ | ៤ | ២៣,៥ | ២៥ |
| ១១ | ប្រជាធិបតេយ្យមូលដ្ឋាន | ១ | ៨,៣ | ២ | ២០ | ៤ | ៤០ | ១២ |
| ១២ | បំណងពលរដ្ឋ | ១ | ១១,១ | ១ | ១៦,៧ | ១ | ១៦,៧ | ៩ |
| ១៣ | ខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច | ១ | ១៤,៣ | ២ | ២៨,៦ | ៣ | ៤២,៩ | ៧ |
| ១៤ | ឯកភាពជាតិខ្មែរ | ០ | ០ | ២ | ២៨,៦ | ០ | ០ | ៧ |
| ១៥ | ខ្មែរអភិរក្ស | ២ | ២៨,៦ | ១ | ១៦,៧ | ២ | ៣៣,៣ | ៧ |
| ១៦ | យុវជនកម្ពុជា | ១ | ៤ | ៤ | ២៣,៥ | ៦ | ៣៥,៣ | ២៥ |
| ១៧ | ជនជាតិដើមប្រជាធិបតេយ្យកម្ពុជា | ១ | ៤,៥ | ១ | ៧ | ១ | ៧,១ | ២២ |
| ១៨ | ប្រជាជនកម្ពុជា | ១ | ៤ | ៣ | ១៧,៦ | ២ | ១១,៨ | ២៥ |
| **សរុប** | | **៥៥** | **១៨** | **៥៩** | **២៧** | **៧៤** | **៣៤** | |

ប្រភព ៖ គ.ជ.ប

ភាគរយនៃបេក្ខជនឈរឈ្មោះនៅលេខរៀងទី១, លេខរៀងទី២និងលេខរៀងទី៣មាន**គម្លាតគ្នាឆ្ងាយ**រវាងបេក្ខជនស្ត្រី និងបេក្ខជនបុរសសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣នេះ។ ជាក់ស្តែង បេក្ខជនស្ត្រីមានចំនួនតិចតួច គឺ **១៨%** ខណៈបេក្ខជនបុរសមានច្រើនលើសលុប **៨២%** ឈរឈ្មោះនៅលេខរៀងទី១។ នៅលេខរៀងទី២ បេក្ខជនស្ត្រីមាន **២៧%** និងបេក្ខជនបុរស មាន **៧៣%**។ រីឯនៅលេខរៀងទី៣ បេក្ខជនស្ត្រីមាន ភាគរយប្រសើរ គឺ **៣៤%** និងបេក្ខជនបុរសមាន **៦៦%**។ តួលេខនេះ

បានបង្ហាញឱ្យឃើញថា ស្ត្រីមានឱកាសតិចតួចបានឈរឈ្មោះនៅលេខរៀងទី១ ខណៈវត្តមានស្ត្រីកាន់តែច្រើនមានឱកាសឈរឈ្មោះនៅលេខរៀងកាន់តែទាប ដែលករណីនេះបញ្ជាក់ពីការខ្វះនូវវិធានការពិសេសពីគណបក្សនយោបាយក្នុងការផ្តល់ឱកាស និងគាំទ្រស្ត្រីបានឈរឈ្មោះនៅរៀងដែលអាចជាប់ឆ្នោត។ ទោះបីយ៉ាងណា គណបក្សដែលបានដាក់បេក្ខជនស្ត្រីច្រើនឈរឈ្មោះនៅលេខរៀងទី១, ទី២ និងទី៣ មានដូចជាគណបក្សស្ត្រីដើម្បីស្ត្រី, គណបក្សខ្មែរតែមួយ, គណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យ, គណបក្សធម្មាធិបតេយ្យ, គណបក្សខ្មែរឈប់ក្រ, គណបក្សកសិករ និងគណបក្សកម្លាំងប្រជាធិបតេយ្យ។

**តារាងទី៩ ៖ ចំនួនបេក្ខជនស្ត្រីឈរឈ្មោះលេខរៀងទី១ តាមគណបក្ស**

| ល.រ | គណបក្សនយោបាយ | បេក្ខជនឈរឈ្មោះពេញសិទ្ធ លេខរៀងទី១ | | | | |
|---|---|---|---|---|---|---|
| | | ស្ត្រី | | បុរស | | ចំ.សរុបស-ប |
| | | ចំនួន | ភាគរយ | ចំនួន | ភាគរយ | |
| ១ | សំបុកឃ្មុំសង្គមប្រជាធិបតេយ្យ | ១ | ១៦,៧ | ៥ | ៨៣,៣ | ៦ |
| ២ | ខ្មែរតែមួយ | ៨ | ៣២ | ១៧ | ៦៨ | ២៥ |
| ៣ | សញ្ញាតិកម្ពុជា | ១ | ៤ | ២៤ | ៩៦ | ២៥ |
| ៤ | ខ្មែររួបរួមជាតិ | ០ | ០ | ២៥ | ១០០ | ២៥ |
| ៥ | កម្លាំងប្រជាធិបតេយ្យ | ២ | ១៦,៧ | ១០ | ៨៣,៣ | ១២ |
| ៦ | កសិករ | ៣ | ៣៧,៥ | ៥ | ៦២,៥ | ៨ |
| ៧ | ស្ត្រីដើម្បីស្ត្រី | ១៤ | ៧៧,៨ | ៤ | ២២,២ | ១៨ |
| ៨ | ខ្មែរឈប់ក្រ | ៧ | ២៨ | ១៨ | ៧២ | ២៥ |
| ៩ | ហ៊្វុនស៊ិនប៉ិច | ២ | ៨ | ២៣ | ៩២ | ២៥ |
| ១០ | ធម្មាធិបតេយ្យ | ៩ | ៣៦ | ១៦ | ៦៤ | ២៥ |
| ១១ | ប្រជាធិបតេយ្យមូលដ្ឋាន | ១ | ៨,៣ | ១១ | ៩១,៧ | ១២ |
| ១២ | បំណងពលរដ្ឋ | ១ | ១១,១ | ៨ | ៨៨,៩ | ៩ |
| ១៣ | ខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច | ១ | ១៤,៣ | ៦ | ៨៥,៧ | ៧ |
| ១៤ | ឯកភាពជាតិខ្មែរ | ០ | ០ | ៧ | ១០០ | ៧ |
| ១៥ | ខ្មែរអភិរក្ស | ២ | ២៨,៦ | ៥ | ៧១,៤ | ៧ |
| ១៦ | យុវជនកម្ពុជា | ១ | ៤ | ២៤ | ៩៦ | ២៥ |
| ១៧ | ជនជាតិដើមប្រជាធិបតេយ្យកម្ពុជា | ១ | ៤,៥ | ២១ | ៩៥,៥ | ២២ |
| ១៨ | ប្រជាជនកម្ពុជា | ១ | ៤ | ២៤ | ៩៦ | ២៥ |
| សរុប | ១៨គណបក្សនយោបាយ | ៥៥ | ១៨ | ២៥៣ | ៨២ | ៣០៨ |

ប្រភព ៖ គ.ជ.ប

## ក្រាហ្វិកទី១០




ប្រភព ៖ គ.ជ.ប

នីតិកាលទី៧ ឆ្នាំ២០២៣នេះ ចំនួននិងភាគរយសរុបនៃបេក្ខជនស្ត្រីនិងបេក្ខជនបុរសឈរឈ្មោះនៅលេខ**រៀងទី១ មានគម្លាតគ្នាខ្លាំង គឺ** បេក្ខជនស្ត្រីមានចំនួន**៥៥នាក់** (១៨%) និងបេក្ខជនបុរសមានចំនួនច្រើនលើសលុប**២៥៣នាក់** (៨២%) ដែលភាគរយស្ត្រីនេះមានភាគរយប្រហាក់ប្រហែលនឹងឆ្នាំ២០១៨ មាន ១៧,៨%។

## ក្រាហ្វិកទី១១




ប្រភព ៖ គ.ជ.ប

ចំនួននិងភាគរយសរុបនៃបេក្ខជនស្ត្រីនិងបេក្ខជនបុរស ឈរឈ្មោះនៅ**លេខរៀងទី២ ក៏មានគម្លាតគ្នាខ្លាំង** គឺ បេក្ខជនស្ត្រីមាន **៥៩នាក់** ស្មើនឹង **២៧%** និងបេក្ខជនបុរសចំនួន**១៥៩នាក់** ស្មើនឹង**៧៣%**។ គួរកត់សម្គាល់ថា បេក្ខជនស្ត្រីឈរឈ្មោះនៅលេខរៀងទី២ សម្រាប់នីតិកាលទី៧នេះបាន **កើន ១១,២%** បើធៀបនឹងនីតិកាលទី៦ ឆ្នាំ២០១៨ មានតែ១៥,៨% ប៉ុណ្ណោះ។

## ក្រាហ្វិកទី១២




ប្រភព ៖ គ.ជ.ប

រីឯ ចំនួន និងភាគរយសរុបនៃបេក្ខជនស្ត្រី និងបេក្ខជនបុរសឈរឈ្មោះនៅ**លេខរៀងទី៣ ក៏មានគម្លាតគ្នា** គឺ បេក្ខជនស្ត្រីចំនួន**៧៤នាក់** ស្មើនឹង **៣៤%** និង**បេក្ខជនបុរសចំនួន ១៤៤នាក់** ស្មើនឹង **៦៦%**។ ដូចគ្នាដែរ បេក្ខជនស្ត្រីឈរឈ្មោះលេខរៀងទី៣ សម្រាប់នីតិកាលទី៧ នេះបាន **កើនឡើង១៤,៥%** បើធៀបនឹងនីតិកាលទី៦ ឆ្នាំ២០១៨ មានតែ១៩,៥%។

ដោយឡែក បេក្ខជនស្ត្រីឈរឈ្មោះពី**លេខរៀងទី១ ដល់ ទី៣** មានចំនួន **១៨៨នាក់** ស្មើនឹង **២៥,៣%** នៃចំនួនបេក្ខជនស្ត្រី-បុរសពីលេខរៀងទី១ដល់ទី៣សរុប ៧៤៤នាក់ ចំនួននេះបាន**កើនឡើង ៧,៦%** បើធៀបនឹងនីតិកាលទី៦ ឆ្នាំ២០១៨ មានតែ១៧,៧%។ ប៉ុន្តែភាគរយសរុបរវាងបេក្ខជនស្ត្រីនិងបេក្ខជនបុរសឈរឈ្មោះពី**លេខរៀងទី១ដល់ទី៣**នេះ មាន **គម្លាតគ្នាខ្លាំង** គឺបេក្ខជនស្ត្រី **២៥,៣%** និងបេក្ខជនបុរស **៧៤,៧%**។ បេក្ខជនស្ត្រី-បុរសឈរឈ្មោះពីលេខរៀងទី១ដល់ទី៣**តាមគណបក្សក៏គាន់តែមានគម្លាតគ្នាខ្លាំង**។ ជាក់ស្តែងគណបក្ស**ប្រជាជនកម្ពុជា**មានបេក្ខជនស្ត្រី **១០,២%** និងបេក្ខជនបុរស **៨៩,៨%** ខណៈដែលគណបក្សហ៊្វុនស៊ិនប៉ិច មានបេក្ខជនស្ត្រីតែ **៦,៨%** និងបេក្ខជនបុរសដ៏ច្រើនលើសលុប **៩៣,២%**។

ក្រាហ្វិកទី១៣




ប្រភព ៖ គ.ជ.ប

ចំនួនទាំងនេះនៅមាន**គម្លាតគ្នាឆ្ងាយ**រវាងបេក្ខជនស្ត្រី និងបេក្ខជនបុរស ដែលបង្ហាញឱ្យឃើញថាកម្ពុជានៅតែបន្តបញ្ហាអតុល្យភាពនៃការអនុវត្តសិទ្ធិ និងអំណាចនយោបាយរវាងស្ត្រី និងបុរស ហើយវិសមភាពយេនឌ័រក្នុងវិស័យនយោបាយនៅតែជាបញ្ហាត្រូវបន្ថែមការយកចិត្តទុកដាក់ និងត្រូវដាក់ចេញនូវវិធានការពិសេសជាក់លាក់ពីអ្នកដឹកនាំគណបក្សនយោបាយ អ្នកដឹកនាំរដ្ឋាភិបាល និងអ្នកដឹកនាំសភាជាតិ។

## ២- ស្ត្រីជាប់ឆ្នោត

ចំនួនស្ត្រីជាប់ឆ្នោតជាតំណាងរាស្ត្រ បានថយចុះជាបន្តបន្ទាប់រាប់ចាប់ពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣, នីតិកាលទី៦ ឆ្នាំ២០១៨ និងនីតិកាលទី៧ ឆ្នាំ២០២៣ ខណៈដែលវត្តមានស្ត្រីបានកើនឡើងជាលំដាប់ និងចូលរួមយ៉ាងសកម្មក្នុងកិច្ចការនយោបាយ និងការបោះឆ្នោតជាងមួយទសវត្សរ៍ចុងក្រោយនេះ ។

**តារាងទី១៤ ៖**

**ចំនួន និងភាគរយស្ត្រី-បុរសជាប់ឆ្នោត នីតិកាលទី៧ ឆ្នាំ២០២៣ (ជាប់ឆ្នោតភ្លាម)**

| គណបក្សនយោបាយ | អាសនៈទទួលបានសរុប | ស្ត្រី | | បុរស | |
|---|---|---|---|---|---|
| | | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| ប្រជាជនកម្ពុជា | ១២០ | ១៦ | ១៣,៣ | ១០៤ | ៨៦,៧ |
| ហ្វ៊ុនស៊ិនប៉ិច | ៥ | ០ | ០ | ៥ | ១០០ |
| សរុប | ១២៥ | ១៦ | ១២,៨ | ១០៩ | ៨៧,២% |
| **១០មណ្ឌលខេត្ត រាជធានីដែលមានស្ត្រីជាប់ឆ្នោត ៖** រាជធានីភ្នំពេញ (៣នាក់), ខេត្តស្វាយរៀង (៣នាក់), ខេត្តកណ្តាល (១នាក់), ខេត្តតាកែវ (២នាក់), ខេត្តកំពត (២នាក់), ខេត្តបន្ទាយមានជ័យ (១នាក់), ខេត្តកំពង់ស្ពឺ (១នាក់), ខេត្តព្រៃវែង (១នាក់), ខេត្តកំពង់ឆ្នាំង (១នាក់) និងខេត្តសៀមរាប (១នាក់)។ | | | | | |

ប្រភព ៖ គ.ជ.ប

**ចំនួននិងភាគរយសរុបនៃស្ត្រីជាប់ឆ្នោតនិងបុរសជាប់ឆ្នោតជាតំណាងរាស្ត្រ នីតិកាលទី៧នៃរដ្ឋសភាមានគម្លាតគ្នាខ្លាំងគឺ** ស្ត្រីជាប់ឆ្នោតមានចំនួន**១២,៨%** ស្មើនឹង**១៦នាក់** និងបុរសជាប់ឆ្នោតមានចំនួនច្រើនលើសលុប **៨៧,២%** ស្មើនឹង **១០៩នាក់**នៃអាសនៈសរុប ១២៥នាក់។ បើប្រៀបធៀបនឹងចុងនីតិកាលទី៦នៃរដ្ឋសភា ចំនួន**ស្ត្រីជាប់ឆ្នោតបានថយចុះ ៨%** សម្រាប់នីតិកាលទី៧ ឆ្នាំ២០២៣នេះ គឺ ពី ២៦នាក់ ស្មើនឹង ២០,៨%នៅចុងនីតិកាលទី៦ មកត្រឹមតែ ១៦នាក់ ស្មើនឹង ១២,៨% នៅនីតិកាលទី៧ ឆ្នាំ២០២៣ (ជាប់ឆ្នោតភ្លាម)។

មណ្ឌលរាជធានី ខេត្ត ចំនួន ១០ ដែលមានស្ត្រីជាប់ឆ្នោតជាតំណាងរាស្ត្រសម្រាប់នីតិកាលទី៧នៃរដ្ឋសភា មានដូចជា ៖ រាជធានី**ភ្នំពេញ** ចំនួន **៣នាក់** និងខេត្ត**ស្វាយរៀង** ចំនួន**៣នាក់**ដែលជាចំនួនច្រើនជាងបណ្តា៨ខេត្តផ្សេងៗ។ រីឯ មណ្ឌលខេត្តដែលមានភាគរយស្ត្រីជាប់ឆ្នោត**ខ្ពស់បំផុត** គឺ ខេត្ត**ស្វាយរៀង ៦០%** និងរាជធានី ខេត្តដែលមានភាគរយ**មធ្យម** គឺ ខេត្ត**កំពត ៣៣,៣%**, រាជធានី**ភ្នំពេញ ២៥%**, ខេត្ត**កំពង់ឆ្នាំង ២៥%** និងខេត្ត**តាកែវ ២៥%**។ ខេត្តដែលមានភាគរយទាប គឺ ខេត្ត**សៀមរាប ១៦,៧%**, ខេត្តកំពង់ស្ពឺ ១៦,៧% និងខេត្ត**បន្ទាយមានជ័យ ១៦,៧%**។ ឯខេត្តដែលមានភាគរយ**ទាបបំផុត** គឺ ខេត្ត**ព្រៃវែង ៩,១%** និងខេត្ត**កណ្តាល ៩,១%**។ (សូមមើលឧបសម្ព័ន្ធទី២)

## ក្រាហ្វិកទី១៥




**គណបក្សពីរ**ដែលទទួលបានសម្លេងឆ្នោតគាំទ្រពីអ្នកបោះឆ្នោត និងទទួលបានអាសនៈនៅក្នុងរដ្ឋសភានីតិកាលទី៧នេះ គឺ **គណបក្សប្រជាជនកម្ពុជា** ចំនួន ១២០អាសនៈនិង**គណបក្សហ្វ៊ុនស៊ិនប៉ិចចំនួន៥ អាសនៈ**

មានតែគណបក្សប្រជាជនកម្ពុជាតែមួយគត់ដែលមានស្ត្រីជាប់ឆ្នោត។ ប៉ុន្តែ**ចំនួននិងភាគរយនៃស្ត្រីនិងបុរសជាប់ឆ្នោតនៃគណបក្សនេះ មានគម្លាតគ្នាខ្លាំង គឺស្ត្រី**ចំនួន **១៦នាក់(១៣,៣%)**និង**បុរស**មានចំនួនដ៏ច្រើនលើសលុប **១០៤នាក់ (៨៦,៧%)**។

ប្រភព ៖ គ.ជ.ប

## ក្រាហ្វិកទី១៦ ៖ ស្ត្រីជាប់ឆ្នោតថ្មីនិងចាស់ និងតាមវ័យនៃគណបក្សប្រជាជនកម្ពុជា




ប្រភព ៖ គ.ជ.ប

ក្រាហ្វិកទី១៦នេះ បង្ហាញឱ្យឃើញថា ក្នុងចំណោមស្ត្រីជាប់ឆ្នោតជាតំណាងរាស្ត្រទាំង១៦រូប (ជាប់ឆ្នោតភ្លាម) គឺមានស្ត្រីវ័យចំណាស់ទាំងអស់ (១៦រូប) និងភាគច្រើនជាស្ត្រីជាប់ឆ្នោតចាស់ (ស្ត្រីដែលធ្លាប់ជាប់ឆ្នោតក្នុងនីតិកាលមុនៗនិងបច្ចុប្បន្ន)មានចំនួន ១១រូប (៦៩%) ខណៈស្ត្រីដែលទើបជាប់ឆ្នោតថ្មី (ស្ត្រីដែលទើបជាប់ឆ្នោតថ្មី នីតិកាលទី៧ ឆ្នាំ២០២៣) មានចំនួនតែ ៥រូប (៣១%) សម្រាប់នីតិកាលទី៧នៃរដ្ឋសភា។ តួលេខនេះបញ្ជាក់ថា ស្ត្រីវ័យក្មេង និងអ្នកជាប់ឆ្នោតថ្មី មិនសូវមានឱកាសក្នុងការចាប់យកបទពិសោធជាតំណាងជាប់ឆ្នោតក្នុងជីវិតនយោបាយរបស់ខ្លួនឡើយ ដែលការណ៍នេះត្រូវការឱ្យមានវិធានការពិសេសនៅក្នុងគណបក្សផង និងនៅក្នុងច្បាប់បោះឆ្នោតផង ប្រយោជន៍មានសមភាពយេនឌ័រពេញលេញ។

## ក្រាហ្វិកទី១៧

### ការប្រៀបធៀបចំនួនស្ត្រីជាប់ឆ្នោតជាតំណាងរាស្ត្រពីនីតិកាលទី១ ដល់ ទី៧




ប្រភព ៖ គ.ជ.ប & រដ្ឋសភា

ភាគរយស្ត្រីជាប់ឆ្នោតជាតំណាងរាស្ត្រ មានការ**កើនឡើង**ជាបន្តបន្ទាប់រាប់ចាប់ពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី១ ឆ្នាំ១៩៩៣ មាន **៦%**, នីតិកាលទី២ មាន **១១%**, នីតិកាលទី៣ មាន **២០%** និងនីតិកាលទី៤ ឆ្នាំ២០០៨ មាន **២១,១%** នៃរដ្ឋសភា។ ប៉ុន្តែភាគរយស្ត្រីជាប់ឆ្នោត ត្រូវបាន**ធ្លាក់ចុះ**ជាបន្តបន្ទាប់វិញនៅនីតិកាលទី៥ មាន **២០,២%** និងនីតិកាលទី៦ មាន **២០,៨%** ហើយកាន់តែ**ធ្លាក់ចុះខ្លាំង**នៅនីតិកាលទី៧នេះ មាន **១២,៨%** បើទោះបីមានការខិតខំរួមចំណែកពីគណបក្សនយោបាយមួយចំនួន រាជរដ្ឋាភិបាល អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ និងសហគមន៍អន្តរជាតិក្នុងការអភិវឌ្ឍសមត្ថភាពស្ត្រី ការលើកកម្ពស់ស្ត្រីតាមរយៈពាក្យសំដី ផែនការសកម្មភាព និងឆន្ទៈនយោបាយ ប្រយោជន៍បង្កើនឱកាស និងគាំទ្រស្ត្រីចូលរួមដោយស្មើភាពនៅក្នុងវិស័យនយោបាយក៏ដោយ។ គណបក្សពីរដែលមានប្រជាប្រិយភាពខ្លាំង និងបានទទួលការគាំទ្រច្រើនពីអ្នកបោះឆ្នោតដែលមានអាសនៈនៅក្នុងរដ្ឋសភាពីមួយអាណត្តិទៅមួយអាណត្តិ មិនបានគិតគូជាវិធានការពិសេសដើម្បីពន្លឿនការបង្កើនចំនួនបេក្ខជនស្ត្រីឈរឈ្មោះបោះឆ្នោត និងជាប់ឆ្នោតឡើយ។

### ៣- ផលប៉ះពាល់

ចំនួននិងភាគរយដែលបានរៀបរាប់ខាងលើបង្ហាញពីការមិនទាន់ឆ្លើយតបគ្រប់គ្រាន់នូវភាពជាតំណាងរបស់ស្ត្រី និងបង្ហាញឱ្យឃើញពីកង្វះការប្តេជ្ញាចិត្តខ្ពស់របស់អ្នកដឹកនាំក្នុងការបង្កើនតំណាងស្ត្រីជាប់ឆ្នោតដែលនាំឱ្យមានប៉ះពាល់ ៖ (១) មិនអាចសម្រេចបាននូវគោលដៅសមភាពយេនឌ័រ ជាពិសេសការជំរុញស្ត្រីចូលរួមក្នុងវិស័យនយោបាយនៅក្នុងផែនការយុទ្ធសាស្ត្រជាតិក៏ដូចជាគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ (២) បង្អាក់ទឹកចិត្តស្ត្រីដែលកំពុងត្រៀមខ្លួន និងកំពុងប្រឡូកនៅក្នុងឆាកនយោបាយនៅកម្រិតថ្នាក់ជាតិ ជាពិសេសស្ត្រីវ័យក្មេង ដោយសារឃើញថាមិនសូវមានការផ្តល់ឱកាសដល់ស្ត្រី និងស្ត្រីដែលជាគំរូភាពនៅតែ

មានចំនួនតិច។ (៣) បញ្ហាបរិយាបន្នសង្គមរបស់ប្រជាពលរដ្ឋ ជាពិសេសបញ្ហាស្ត្រី កុមារ និងបញ្ហាសមភាពយេនឌ័រនៅថ្នាក់ជាតិ និងទូទាំងប្រទេសនឹងមិនត្រូវបានយកចិត្តទុកដាក់ និងឆ្លើយតបដោយប្រសិទ្ធភាពនិងគ្រប់ជ្រុងជ្រោយ។ (៤) កង្វះការឆ្លើយតបនឹងតម្រូវការយេនឌ័រ និងបរិយាបន្ននៅក្នុងដំណើរការពិភាក្សា បង្កើតនិងអនុម័តច្បាប់នានានិងការសម្រេចចិត្តផ្នែកនយោបាយ ដោយសារមិនមានភាពចម្រុះយេនឌ័រនៅ ក្នុងរដ្ឋសភា។

## ៤- ការប្រឈម

ស្ត្រីជាប់ឆ្នោតជាតំណាងរាស្ត្រដែលមាន **ចំនួនតិច** និង **ថយចុះ** ជាបន្តបន្ទាប់ ដោយសារមានកត្តាចម្បង និងការប្រឈមមួយចំនួន ៖ (១) **កង្វះឆន្ទៈនយោបាយរបស់គណបក្ស និងការប្តេជ្ញាចិត្តខ្ពស់របស់អ្នកដឹកនាំ** ជាពិសេសគណបក្សដែលមានសម្លេងឆ្នោតគាំទ្រច្រើនពីអ្នកបោះឆ្នោត (ទទួលបានអាសនៈនៅក្នុងរដ្ឋសភា)ក្នុងការជំរុញឱ្យមានសមភាពយេនឌ័រក្នុងវិស័យនយោបាយ និងថ្នាក់សម្រេចចិត្ត ជាក់ស្តែងគណបក្សប្រជាជនកម្ពុជា និងគណបក្សហ្វ៊ុនស៊ិនប៉ិច បានដាក់បេក្ខជនស្ត្រីឈរឈ្មោះរបស់ខ្លួនក្នុងចំនួនតិចតួចពេកសម្រាប់ការបោះឆ្នោត នីតិកាលទី៧នេះ។ (២) **ខ្វះគោលនយោបាយសមភាពយេនឌ័រ**ជាក់លាក់ជាលាយលក្ខណ៍អក្សរនៅក្នុងគណបក្សនយោបាយ រួមទាំង**មិនមានចែងជាក់លាក់អំពីវិធានការពិសេសក្នុងមាត្រាមួយចំនួននៃច្បាប់បោះឆ្នោត** ដើម្បីគាំទ្រ និងផ្តល់ឱកាសឱ្យស្ត្រីចូលរួមដោយស្មើគ្នានឹងបុរសក្នុងវិស័យនយោបាយ ជាពិសេសការឈរឈ្មោះជាបេក្ខជន និងជាប់ឆ្នោតក្លាយជាអ្នកដឹកនាំ។ (៣) **រចនាសម្ព័ន្ធនៃការគ្រប់គ្រងភាគច្រើនលើសលុបជាបុរស** ហើយបុរសនៅតែបន្តរក្សាតំណែងរបស់ខ្លួន ឬ/និងខ្សែស្រឡាយរបស់ខ្លួន ដែលនេះធ្វើឱ្យឱកាសទទួលបានមុខតំណែងរបស់ស្ត្រីកាន់តែរួមតូច។ (៤) **បញ្ហាថវិកា** ក្នុងការឈរឈ្មោះជាបេក្ខជនដែលគណបក្សតម្រូវសម្រាប់ធ្វើការឃោសនាបោះឆ្នោត គឺជាឧបសគ្គដ៏ធំបំផុតមួយដែលស្ត្រីបានប្រឈម។ (៥) សកម្មជនស្ត្រីគណបក្សនយោបាយនិងអ្នកនយោបាយស្ត្រីនៅតែប្រឈមនឹង**ការរើសអើង**និង**អំពើហិង្សា**គ្រប់ទម្រង់ ដែលជាឧបសគ្គរាំងពួកគេក្នុងការចូលរួមក្នុងសកម្មភាពនយោបាយ និងការទទួលបាននូវយុត្តិធម៌យេនឌ័រនិងផលប្រយោជន៍ពីការចូលរួមក្នុងវិស័យនយោបាយ។ (៦)**បទដ្ឋានវប្បធម៌និងសង្គមមួយចំនួន**ដែលមានផ្នត់គំនិតអវិជ្ជមានក្នុងការលើកកម្ពស់ភាពជាអ្នកដឹកនាំរបស់ស្ត្រី គឺជាឫសគល់បញ្ហាបង្កជារនាំងរាំងដល់ការចូលរួមរបស់អ្នកនយោបាយស្ត្រីប្រកបដោយគុណភាពនិងប្រសិទ្ធភាព។

## ករណីសិក្សាទី១ ៖

*មូលហេតុចម្បងដែលបណ្តាលឱ្យនាងខ្ញុំចូលរួមក្នុងកិច្ចការនយោបាយ គឺ ដោយសារនាងខ្ញុំចង់ជួយសង្គមដោយផ្ទាល់ ចង់ឃើញប្រទេសជាតិមានការអភិវឌ្ឍ ចង់លើកកម្ពស់សមភាពយេនឌ័រ និងដើម្បីការពារផលប្រយោជន៍របស់ស្ត្រី។ មានការគាំទ្រយ៉ាងពេញទំហឹងពីក្រុមគ្រួសារដោយពួកគាត់បានគោរព និងស្របតាមការសម្រេចចិត្តរបស់នាងខ្ញុំ។*



លោកស្រី **ម៉ាន់ ស្រីនៀន** កើតនៅឆ្នាំ១៩៨៥ (៣៨ឆ្នាំ) ជាបេក្ខជនមណ្ឌលរាជធានីភ្នំពេញ ឈរឈ្មោះនៅលេខរៀងទី១មកពីគណបក្សខ្មែរតែមួយ។ បច្ចុប្បន្នលោកស្រីរស់នៅសង្កាត់កំបូល ខណ្ឌកំបូល រាជធានីភ្នំពេញ។ លោកស្រីមានកម្រិតវប្បធម៌ថ្នាក់បរិញ្ញាបត្រ និងទើបតែបានឈរឈ្មោះជាបេក្ខជនជាលើក ដំបូងសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣នេះ។

*«មូលហេតុចម្បងដែលជម្រុញឱ្យនាងខ្ញុំ ចូលរួមក្នុងកិច្ចការនយោបាយ គឺដោយសារតែនាងខ្ញុំចង់ជួយសង្គមដោយផ្ទាល់ ចង់ឃើញប្រទេសជាតិមានការអភិវឌ្ឍ ចង់លើកកម្ពស់សមភាពយេនឌ័រ និងដើម្បីការពារផលប្រយោជន៍របស់ស្ត្រី»* លោកស្រី **ម៉ាន់ ស្រីនៀន** បានបញ្ជាក់យ៉ាងច្បាស់។

មុនពេលឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រ លោកស្រី **ម៉ាន់ ស្រីនៀន** គឺជាសមាជិកគណបក្សធម្មតាប៉ុណ្ណោះ។ ក្នុងការឈរឈ្មោះជាបេក្ខជននេះ ក្រុមគ្រួសារផ្ទាល់របស់លោកស្រីមានការគាំទ្រយ៉ាងពេញទំហឹង ដោយពួកគាត់បានគោរពនិងស្របតាមការសម្រេចចិត្តរបស់លោកស្រី ប៉ុន្តែក្រុមគ្រួសារក៏មានការព្រួយបារម្ភផងដែរចំពោះសុខសុវត្ថិភាពរបស់លោកស្រី។ ចំពោះញាតិជិតខាង មិត្តភក្តិរបស់ លោកស្រីក៏មានការអបអរសាទរ និងកោតសរសើរពីទឹកចិត្តក្លាហានរបស់លោកស្រីក្នុងការចូលរួមប្រឡូកក្នុងការងារនយោបាយនេះ។ ទោះបីយ៉ាងណាក៏ដោយ មានមិត្តភក្តិមួយចំនួនតូចមិនចង់ឱ្យលោកស្រីចូលរួមក្នុងវិស័យនយោបាយទេ ដោយសារមានការព្រួយបារម្ភពីសុវត្ថិភាពផ្ទាល់របស់លោកស្រី។

របៀបនៃការជ្រើសរើសបេក្ខជនឈរឈ្មោះនៅក្នុង**គណបក្សខ្មែរតែមួយ** គឺផ្អែកលើការប្រជុំគណៈកម្មការអចិន្ត្រៃយ៍ និងធ្វើការវាយតម្លៃតាមខេត្តនីមួយៗដើម្បីជ្រើសរើសចំនួនបេក្ខជនស្ត្រីនិងបុរសក្រោមការរៀបចំចាត់ចែងរបស់ប្រធានគណបក្សផ្ទាល់។ **គណបក្សខ្មែរតែមួយ** មានគោលការណ៍ផ្តល់អាទិភាពដល់បេក្ខជនស្ត្រី ការបង្កើន និងលើកកម្ពស់ចំនួនស្ត្រីឱ្យមានភាពសកម្មកាន់តែច្រើន ។ ទោះបីយ៉ាងណា ការដាក់ បេក្ខភាពស្ត្រីឈរឈ្មោះនៅលេខរៀងខាងលើ គឺត្រូវផ្អែកលើលក្ខខណ្ឌមួយចំនួន ដូចជា **កម្រិតចំណេះដឹង ភាពសកម្ម ភាពក្លាហានក្នុងការបញ្ចេញមតិ មានបណ្តាញការងារ បេក្ខជនរួសរាយរាក់ទាក់ជាមួយអ្នក ជុំវិញខ្លួន**។

ការប្រឈមរបស់លោកស្រី **ម៉ាន់ ស្រីនៀន** ក៏ដូចជាស្ត្រីដទៃទៀត គឺការរើសអើង ការមិនឱ្យតម្លៃស្ត្រី និងការគំរាមកំហែង។ លោកស្រីបានលើកឡើងថា *«ការប្រឈមរបស់ខ្ញុំ ក៏ដូចជាការប្រឈមរបស់ស្ត្រីដទៃទៀតដែរនៅក្នុងវិស័យនយោបាយ គឺ គេមិនឱ្យតម្លៃដល់ស្ត្រី មានការរើសអើង ការនិយាយស្តីគំរាមកំហែង បំបាក់ទឹកចិត្ត ដែលធ្វើឱ្យស្ត្រីមិនសូវមានភាពក្លាហានក្នុងការប្រឡូកក្នុងការងារនយោបាយ»*។ ជាក់ស្តែង លោកស្រី **ម៉ាន់ ស្រីនៀន** បានទទួលការមាក់ងាយពីប្រជាពលរដ្ឋជាបុរសមួយចំនួននៅក្នុងអំឡុងពេលនៃការឃោសនាបោះឆ្នោតផងដែរ។

វិធីសាស្ត្រដែលលោកស្រី **ម៉ាន់ ស្រីនៀន** បានប្រើប្រាស់អំឡុងពេលឃោសនាបោះឆ្នោត ដើម្បីទាក់ទាញការគាំទ្រពីប្រជាពលរដ្ឋនោះ គឺ **ការសន្យា និងសកម្មភាពសប្បុរសធម៌ជួយប្រជាពលរដ្ឋដែលជួបបញ្ហាលំបាក**។ ដោយសន្យាថា ប្រសិនបើគណបក្សលោកស្រីបានឈ្នះឆ្នោត គណបក្សនឹងមានការតម្លើងប្រាក់បៀវត្សរ៍ជូនមន្ត្រីរាជការ កម្មករ កម្មការិនី មានប្រាក់ឧបត្ថម្ភសម្រាប់ចាស់ជរា ជនមានពិការភាព

និងលើកកម្ពស់ស្ត្រីឱ្យមានភាពក្លាហានក្នុងការចូលរួមកិច្ចការនយោបាយ ។ ជាមួយគ្នាដែរ លោកស្រីបានបង្ហាញពីស្នាដៃចូលរួមក្នុងការងារសប្បុរសធម៌ ដោយបានជួយដល់ជនមានពិការភាព ចាស់ជរា និងកុមារកំព្រាបានជាច្រើនគ្រួសារផងដែរ។

ដើម្បីបង្កើនចំនួនស្ត្រីឈរឈ្មោះសម្រាប់ការបោះឆ្នោតអាណត្តិក្រោយៗ លោកស្រីបានផ្តល់យោបល់ថា *«ត្រូវអប់រំណែនាំស្ត្រីឱ្យបានយល់ដឹងអំពីកិច្ចការនយោបាយ និងត្រូវជម្រុញលើកទឹកចិត្តស្ត្រីបង្កើនភាពក្លាហាននិងអង់អាចក្នុងការប៉ានជំនះនូវឧបសគ្គក្នុងការចូលរួមប្រឡូកក្នុងវិស័យនយោបាយ»* ។

លោកស្រី **ម៉ាន់ ស្រីនឿន** មានសំណូមពរទៅកាន់បុរសឱ្យមានការ *«បើកចិត្តទូលាយទទួលយកនូវការសម្រេចចិត្តរបស់ស្ត្រី កុំមានការមើលងាយពីសមត្ថភាព ពីការចូលរួមរបស់ស្ត្រី កុំយកផ្នត់គំនិតចាស់ៗដែលថា ស្ត្រីមិនអាចធ្វើអ្វីបានដូចបុរសមកធ្វើការវាយប្រហារបំបាក់ទឹកចិត្តស្ត្រី»*។ **ទន្ទឹមនឹងនេះ លោកស្រីបានសំណូមពរដល់ក្រុមគ្រួសាររបស់ស្ត្រីទាំងអស់ថា** ***«កុំផ្តល់ឧបសគ្គ កុំមានការរារាំងនូវការសម្រេចចិត្តរបស់ស្ត្រីចូលរួមក្នុងកិច្ចការនយោបាយ»***។ ផ្ទុយមកវិញ ទាំងក្រុមគ្រួសារ ទាំងបុរសត្រូវមានការគាំទ្រ លើកទឹកចិត្ត និងជម្រុញបន្ថែម ដើម្បីឱ្យស្ត្រីកាន់តែមានកម្លាំងចិត្តចូលរួម។ ចំណែកស្ត្រីខ្លួនឯងជាពិសេស យុវតីត្រូវមានឆន្ទៈ មានភាពក្លាហានមោះមុតចូលរួមចំណែកស្រឡាញ់ជាតិ កសាងនិងអភិវឌ្ឍន៍ប្រទេសជាតិ តាមរយៈការចូលរួមក្នុងវិស័យនយោបាយនេះ។

## ករណីសិក្សាទី២ ៖



«មូលហេតុចម្បងដែលជម្រុញឱ្យនាងខ្ញុំចូលប្រឡូកការងារក្នុងវិស័យនយោបាយ គឺចង់ជួយសង្គមដោយផ្ទាល់ គិតពីអនាគតកូនចៅ និងចង់ដឹង ចង់សាកល្បងការងារនយោបាយ ពីព្រោះការងារនយោបាយមិនមែនជាកាងាររបស់បុរសតែម្នាក់នោះទេ ស្ត្រីគឺជាចលករមួយដ៏សំខាន់ក្នុងការចូលរួមអភិវឌ្ឍប្រទេសជាតិ ។ នាងខ្ញុំទទួលបានការគាំទ្រពីសំណាក់គ្រួសារដោយផ្តល់តម្លៃចំពោះការគិត និងការវិនិច្ឆ័យរបស់ខ្ញុំនូវអ្វីដែលខ្ញុំពេញចិត្ត សម្រេចចិត្ត ដោយមានការសាទរ និងគាំទ្រជានិច្ច »

លោកជំទាវ **ភា ធារិទ្ធ** ជាបេក្ខជនឈរឈ្មោះនៅលេខរៀងទី៣ មកពីគណបក្សហ្វ៊ុនស៊ិនប៉ិច ហើយជាលើកដំបូងដែលលោកជំទាវ បានឈរឈ្មោះជាបេក្ខជនសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣។ បច្ចុប្បន្ន លោកជំទាវ **ភា ធារិទ្ធ** មានអាយុ៣៨ឆ្នាំ (ឆ្នាំ១៩៨៥) និងមានទីលំនៅក្នុងសង្កាត់ដើមមៀន ក្រុងតាខ្មៅ ខេត្តកណ្តាល។ លោកជំទាវមានកម្រិតវប្បធម៌នៅថ្នាក់អនុបណ្ឌិត ផ្នែកធុរកិច្ច និងជំនាញគ្រប់គ្រង។ មុនពេលឈរឈ្មោះជាបេក្ខជន លោកជំទាវមានតួនាទីជាសមាជិកគណបក្ស និងជា

អនុប្រធានចលនាស្ត្រីនៅក្នុងគណបក្សនយោបាយ។ បន្ទាប់មក ថ្នាក់ដឹកនាំបានបោះឆ្នោតជ្រើសតាំងជាសមាជិក គណៈកម្មការនាយកនៃគណបក្សហ៊្វុនស៊ិនប៉ិច។

ការជ្រើសរើសបេក្ខជនឈរឈ្មោះនៅក្នុង**គណបក្សហ៊្វុនស៊ិនប៉ិច** គឺ ត្រូវឆ្លងកាត់នូវការវិនិច្ឆ័យ និងប្រជុំចំនួន**២លើក**ជាមួយគណៈកម្មការនាយក ហើយនៅពេលដែលគណៈកម្មការនាយកសម្រេចថាបុគ្គល នោះអាចមានសមត្ថភាព លទ្ធភាព និងធនធានជាមួយចំណេះជំនាញ និងអាចឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្របាន បន្ទាប់មកត្រូវធ្វើសេចក្ដីសម្រេច ហើយផ្ញើសេចក្ដីសម្រេចនោះទៅកាន់ប្រធានគណបក្ស ដើម្បី សម្រេចតែងតាំងបេក្ខភាពនោះឱ្យឈរឈ្មោះជាបេក្ខជនសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។

មូលហេតុចម្បងដែលជម្រុញឱ្យលោកជំទាវ **ភា ឆារិទ្ធ** ចូលប្រឡូកការងារក្នុងវិស័យនយោបាយ គឺចង់ជួយសង្គមដោយផ្ទាល់ និងគិតពីអនាគតកូនចៅ។ លោកជំទាវបានលើកឡើងថា « ***ខ្ញុំចង់ដឹង ចង់សាកល្បង និងមានការគិតអំពីអនាគតប្រជាពលរដ្ឋទូទៅ ហើយការងារនយោបាយមិនមែនជាការងារសម្រាប់តែបុរសនោះទេ ស្ត្រីក៏ជាចលករមួយដ៏សំខាន់ក្នុងការចូលរួមអភិវឌ្ឍន៍ប្រទេសជាតិផងដែរ។ បើមានស្ត្រីកាន់តែច្រើន នោះការបង្កើតគោលនយោបាយដឹកនាំប្រទេស គឺ យើងអាចលើកពីបញ្ហាណាមួយដាក់បញ្ចូលទៅក្នុងគោលនយោបាយដើម្បីការពារ គាំពារ និងផ្ដល់ប្រយោជន៍ដល់ស្ត្រីបានកាន់តែច្រើន*** » ។ លោកជំទាវ បានបញ្ជាក់ផងដែរថា « ***ក្រុមគ្រួសារ និងស្វាមីមានការសាទរ និងគាំទ្រជាខ្លាំងដោយផ្ដល់តម្លៃចំពោះការគិត និងការវិនិច្ឆ័យរបស់ខ្ញុំនូវអ្វីដែលខ្ញុំពេញចិត្ត និងសម្រេចចិត្ត*** » ។

វិធីសាស្ត្រដែលលោកជំទាវ **ភា ឆារិទ្ធ** ប្រើដើម្បីទាក់ទាញការគាំទ្រពីអ្នកបោះឆ្នោតក្នុងអំឡុងពេលឃោសនាបោះឆ្នោត គឺ ៖

- ឧស្សាហ៍ចុះទៅតាមមូលដ្ឋាននៅក្នុងសហគមន៍ដែលលោកជំទាវធ្វើជាអ្នកតំណាងនៅក្នុងស្រុកនោះ។
- ចុះជួបជាមួយប្រជាពលរដ្ឋ ដើម្បីសួរនាំ និងដឹងពីសុខទុក្ខរបស់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានតាមរយៈក្រុមការងារនៅតាមឃុំ សង្កាត់របស់គណបក្សហ៊ុនស៊ិនប៉ិច។
- ពិភាក្សាគ្នារកដំណោះស្រាយជូនប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន ហើយបង្កើតជាកម្មវិធីនយោបាយទៅកាន់ប្រជាពលរដ្ឋអំពីជំហររបស់គណបក្សហ៊ុនស៊ិនប៉ិច ក្នុងបំណងចុះជួយ និងដោះស្រាយបញ្ហាជូនប្រជាពលរដ្ឋដែលបានជួបបញ្ហាប្រឈមផ្សេងៗ។
- អ្វីដែលពិសេសបំផុតនោះ យើងជាស្ត្រីដូចគ្នាគឺមានភាពងាយស្រួលក្នុងការស្វែងយល់អំពីទុក្ខលំបាករបស់ប្រជាជនជាស្ត្រីដូចគ្នាជាងបេក្ខជនបុរស។ ពេលខ្លះស្ត្រីមិនអាចចែករំលែកអំពីបញ្ហារបស់ ខ្លួនទៅប្រាប់សកម្មជនជាបុរសទេ។ ដូច្នេះយើងជាស្ត្រីដូចគ្នាគឺ អាចមានឱកាសនៅក្នុងការចែករំលែក ត្រង់ៗចំពោះគ្នាបានច្រើន ពាក់ព័ន្ធជាមួយនឹងបញ្ហាការបៀតបៀន បញ្ហាអំពើហិង្សានៅក្នុងគ្រួសារ ជាដើម។
- យើងត្រូវបង្កើតនូវកម្មវិធីនយោបាយទៅតាមតំបន់ដែលប្រជាពលរដ្ឋរស់នៅ ហើយជួបបញ្ហាផ្សេងៗ។

លោកជំទាវ **ភា ឆារិទ្ធ** បាន**សន្យាបន្ថែមពិសេស** ក្នុងការដោះស្រាយបញ្ហាស្ត្រី កុមារ និងការធ្វើឱ្យមានសមភាពរវាងស្ត្រី និងបុរសរួមមាន ៖

- ធ្វើការពិនិត្យ និងកែលម្អនូវប្រព័ន្ធគ្រប់គ្រងទៅតាមនីតិវិធី របៀបរបបក្នុងការអនុវត្តការងារដើម្បីឆ្លើយតបទៅនឹងសមភាពយេនឌ័រទាំងបុរស និងស្ត្រី គឺគោលបំណងធំចង់លុបបំបាត់ការរើសអើង និងការបៀតបៀន ការមិនគោរពសិទ្ធិ ការមិនឱ្យតម្លៃស្មើគ្នារវាងបុរស និងស្ត្រីផងដែរ។
- បង្កើនចំនួនស្ត្រីនៅក្នុងមុខតំណែងគ្រប់គ្រង តាមរយៈការកំណត់បេក្ខភាពស្ត្រីឱ្យមានសក្ដានុពលក្នុងមុខតំណែងជាអ្នកគ្រប់គ្រង និងការអភិវឌ្ឍសមត្ថភាពបេក្ខភាពស្ត្រីឱ្យកាន់តែមានលក្ខណៈគ្រប់គ្រាន់ក្នុងការទទួលយកមុខតំណែង។
- ជម្រុញឱ្យមានការងារ មុខតំណែង ធនធានដើម្បីឆ្លើយតបទៅតាមសមភាពយេនឌ័រ ដោយធានាបានថាទាំងស្ត្រី និងបុរសត្រូវទទួលបាននូវអត្ថប្រយោជន៍ដូចគ្នា ទាំងការផ្ទេរមុខតំណែង ធនធានដើម្បីឆ្លើយតបទៅនឹងសមភាពយេនឌ័រ។

ក្នុងជីវិតនយោបាយរបស់លោកជំទាវ **ភា ធារិទ្ធ** ពុំឃើញមានការប្រឈម ឬក៏ឧបសគ្គរាំងណាទេ គឺមានតែការលើកទឹកចិត្ត អបអរសាទរ និងគាំទ្រពីសំណាក់សង្គម គ្រួសារ បុរស កន្លែងការងារ ជាពិសេសបំផុត គឺអ្នកដឹកនាំកំពូលៗរបស់គណបក្សហ៊ុនស៊ិនប៊ិច តែងតែលើកចិត្ត ជម្រុញ និងផ្ដល់យោបល់ក្នុងការធ្វើការក៏ដូចជាដោះស្រាយបញ្ហាផ្សេងៗ ។ ជាពិសេស បុរសភាគច្រើនតែងតែសប្បាយចិត្តនិងសាទរជាមួយអ្វីដែលស្ត្រីអាចធ្វើបាន។ ទោះបីយ៉ាងណា មានមិត្តភក្តិ និងអ្នកជិតខាងមួយចំនួន យល់ថា ស្ត្រីមិនត្រូវពាក់ព័ន្ធនឹងកិច្ចការនយោបាយទេ ពីព្រោះអាចមានផលប៉ះពាល់ជាច្រើនដល់ជីវភាព គ្រោះថ្នាក់ និងចំណាយពេលវេលាច្រើន។

ដើម្បីបង្កើនចំនួនបេក្ខជនស្ត្រីឈរឈ្មោះសម្រាប់ការបោះឆ្នោតអាណត្តិក្រោយ លោកជំទាវ **ភា ធារិទ្ធ** បានផ្ដល់អនុសាសន៍មួយចំនួន ៖

- គួររួមគ្នាលើកទឹកចិត្ត និងផ្ដល់ឱកាសឱ្យស្ត្រី ជាពិសេសយុវតីបានចូលរួមនៅក្នុងគណបក្សនយោបាយ និងបានយល់ដឹងអំពីគោលនយោបាយ ជាពិសេស ការលើកកម្ពស់ស្ត្រីក្នុងការឈរឈ្មោះជាបេក្ខជន និងការអភិវឌ្ឍសង្គមជាតិ។
- ស្ត្រីខ្លួនឯងផ្ទាល់គួរតែសម្រេចចិត្តសាកល្បងចូលរួមធ្វើកិច្ចការនយោបាយ ថាតើអាចធ្វើឱ្យពួកគាត់ បានផលចំណេញអ្វីខ្លះ។ ហើយស្ត្រីគួរផ្លាស់ប្ដូរផ្នត់គំនិតអវិជ្ជមាន «ស្ត្រីមិនអាចធ្វើបាន» មកជា ផ្នត់គំនិតវិជ្ជមាន **«ស្ត្រីអាចធ្វើបាន»**។
- ស្ត្រីត្រូវលើកកម្ពស់ស្ត្រីទាំងអស់ឱ្យមានភាពក្លាហាន យល់ដឹងថាការងារនយោបាយជាការងាររបស់យើងទាំងអស់គ្នា មិនមែនជាការងាររបស់បុរសតែម្នាក់ទេ។
- អប់រំសង្គមទាំងមូលឱ្យយល់ដឹងថា ស្ត្រីមានសមត្ថភាពធ្វើកិច្ចការងារផ្សេងៗបានដូចបុរសដែរ ហើយអាចធ្វើកិច្ចការផ្សេងៗលើសពីបុរសទៀតផង។

លោកជំទាវ **ភា ធារិទ្ធ** បានសំណូមពរទៅស្ត្រី ជាពិសេសយុវវ័យ សូមចូលរួមឱ្យបានច្រើនដោយផ្ទាល់ក្ដី ដោយប្រយោលក្ដី ដោយត្រូវស្ដាប់នូវព័ត៌មានទាន់ហេតុការណ៍នានា និងនយោបាយរបស់ប្រទេសជាតិឱ្យបានកាន់តែច្រើនដើម្បីឱ្យមានភាពរីកចម្រើននៅក្នុងការអភិវឌ្ឍប្រទេសជាតិ និងធ្វើឱ្យមានវិជ្ជាជីវៈនៅ

ក្នុងផ្នែកនយោបាយ និងជម្រុញឱ្យមានសមភាពយេនឌ័រនៅក្នុងគណបក្សនយោបាយទាំងអស់ ដើម្បីឱ្យស្ត្រីមានឱកាសចូលរួមធ្វើការសម្រេចចិត្ត និងក្នុងការលើកកម្ពស់សង្គមតាមបែបប្រជាធិបតេយ្យ។

លោកជំទាវបានសំណូមពរទៅ គណបក្សនយោបាយ និងរាជរដ្ឋាភិបាល « *ត្រូវផ្តល់ឱកាសជូនស្ត្រីទាំងអស់ក្នុងការទទួលបានការងារធំៗ និងតំណែងធ្វើសេចក្តីសម្រេចលើរឿងផ្សេងៗដូចជាបុរសផងដែរ*»។ **លោកជំទាវបានបន្ថែមថា** *«ខ្ញុំជឿជាក់ថាមិនអាចដំណើរការទៅបានទេទាំងស្ថាប័នជាតិ អង្គការ សង្គមស៊ីវិល និងផ្នែកផ្សេងៗទៀត លុះត្រាតែមានទាំងស្ត្រីនិងបុរស ទើបដំណើរការនៅក្នុងស្ថាប័នទាំងអស់មានដំណើរការល្អឥតខ្ចោះ រួមទាំងមានសិល្បៈនៃការងារផងដែរ* »។

## ៥- កម្មវិធីនយោបាយថ្នាក់ជាតិរបស់គណបក្ស អំពីបញ្ហាស្ត្រី កុមារនិងសមភាពយេនឌ័រ

ក្នុងដំណើរការយុទ្ធនាការឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ មាន**រយៈពេល២១ថ្ងៃ ចាប់ពីថ្ងៃទី១ ខែកក្កដា ដល់ ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៣** គណបក្សនយោបាយទាំង១៨ បានធ្វើសកម្មភាពឃោសនាដើម្បីបង្ហាញដល់អ្នកបោះឆ្នោតនូវកម្មវិធីនយោបាយរបស់ខ្លួនក្នុងការដឹកនាំ និងអភិវឌ្ឍប្រទេស ក្នុងនោះក៏បានបង្ហាញនូវកម្មវិធីនយោបាយទាក់ទងនឹងការដោះស្រាយបញ្ហាស្ត្រី និងកុមារ និងការបង្កើនសមភាពយេនឌ័រ សម្រាប់នីតិកាលទី៧នេះផងដែរ។

កម្មវិធីនយោបាយ និងការសន្យាសំខាន់របស់គណបក្សនយោបាយខាងក្រោមនេះ បានដកស្រង់ចេញពីឯកសារនៅក្នុងគេហទំព័ររបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) ពីគណបក្សនយោបាយ កម្មវិធីឱកាសស្ត្រី ស្តីពី « កម្មវិធីនយោបាយលើកកម្ពស់ស្ត្រី » របស់មណ្ឌលព័ត៌មានស្ត្រីកម្ពុជា (WMC) និងបានដកស្រង់ចេញពីរបាយការណ៍សង្កេតការណ៍របស់ខុមហ្វ្រែលស្តីពី « ការចូលរួមនយោបាយរបស់ស្ត្រីក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ » ព្រមទាំងបានដកស្រង់ព័ត៌មានពីបេក្ខជនស្ត្រីក្នុងតំបន់គោលដៅរបស់ខុមហ្វ្រែលចំនួន**៥ខេត្ត** គឺ **ខេត្តកំពង់ធំ ខេត្តកំពង់ចាម ខេត្តកំពង់ឆ្នាំង ខេត្តតាកែវ និងខេត្តព្រះវិហារ**។

គណបក្សនយោបាយប្រមាណ៧២%ក្នុងចំណោមគណបក្សនយោបាយ១៨ បានគិតគូរក្នុងការដោះស្រាយបញ្ហាស្ត្រី និងកុមារ និងលើកកម្ពស់សមភាពយេនឌ័រ ៖

**តារាងទី១៩ ៖ កម្មវិធីនយោបាយថ្នាក់ជាតិរបស់គណបក្សដើម្បីដោះស្រាយបញ្ហាស្ត្រី កុមារ និងសមតាពយេនឌ័រ**

| ល.រ | កម្មវិធីនយោបាយ | ឈ្មោះគណបក្ស |
|---|---|---|
| ១ | - ការពារ និងលើកតម្កើងស្ត្រីជាចម្បង<br>- ជួយចិញ្ចឹមចាស់ជរា និងក្មេងកំព្រាទូទាំងប្រទេស ដោយផ្តល់កន្លែងស្នាក់នៅ និងផ្តល់អាហារគ្រប់គ្រាន់។<br>- ពាក្យស្លោក ស្ត្រីអាចធ្វើបាន<br>- មានគោលដៅជ្រើសរើសបេក្ខភាពជាស្ត្រីទាំង ១០០% | ស្ត្រីដើម្បីស្ត្រី |

| | | |
|---|---|---|
| | - មានគោលនយោបាយលើកកម្ពស់សេដ្ឋកិច្ចស្ត្រី ដោយបង្កើតនូវភូមិមួយផ្សារមួយ។<br>- អប់រំចំណេះដឹង វិជ្ជាជីវៈស្ត្រី។ បង្រៀននិងបណ្តុះបណ្តាលផ្តោតសំខាន់ទៅលើស្ត្រីនៅជនបទ និងប្រជាពលរដ្ឋក្រីក្រ ដោយបង្កើតសាលាវិជ្ជាជីវៈក្នុងភូមិ និងផ្សារកសិកម្ម ឧស្សាហកម្ម សិប្បកម្មនៅក្នុងភូមិ ដើម្បីឱ្យស្ត្រីអាចរៀនសូត្របាន និងមានសេដ្ឋកិច្ចល្អបង្កើតជាសមាគម ភូមិស្ត្រី។ | |
| ២ | - ជម្រុញការបញ្ជ្រាបយេនឌ័រនៅក្នុងក្របខ័ណ្ឌគោលនយោបាយ និងកម្មវិធីជាតិ រួមទាំងគ្រប់កម្មវិធីកំណែទម្រង់រដ្ឋ គោលនយោបាយជាតិ គាំពារសង្គម និងកម្មវិធីប្រែប្រួលអាកាសធាតុអភិវឌ្ឍន៍បៃតង។<br>- បន្តលើកកម្ពស់ការចូលរួម និងពង្រឹងភាពជាអ្នកដឹកនាំរបស់ស្ត្រីនៅក្នុងវិស័យសាធារណៈ វិស័យឯកជន និងវិស័យនយោបាយ។<br>- ពង្រឹងភាពអង់អាចរបស់ស្ត្រីនៅក្នុងវិស័យសេដ្ឋកិច្ច តាមរយៈការអភិវឌ្ឍសហគ្រិនភាពរបស់ស្ត្រី ការគាំទ្រស្ត្រីដែលដឹកនាំនិងគ្រប់គ្រងអាជីវកម្មខ្នាតមីក្រូតូច និងមធ្យម។<br>- ការលើកកម្ពស់ចំណេះដឹង ជំនាញរបស់ស្ត្រី លើកកម្ពស់សេដ្ឋកិច្ចគ្រួសាររបស់ស្ត្រី និងការពារសិទ្ធិស្ត្រីនៅក្នុងសកម្មភាពសេដ្ឋកិច្ច និងអនុវត្តកម្មវិធីលើកកម្ពស់គុណភាពជីវិតការងារ និងគ្រួសារ។<br>- បន្តទប់ស្កាត់អំពើហិង្សាគ្រប់រូបភាពលើស្ត្រី និងក្មេងស្រី តាមរយៈការអនុវត្តផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ការពង្រីកវិសាលភាពសេវាជួយជនរងគ្រោះ និងការពង្រឹងការអនុវត្តច្បាប់។<br>- បន្តលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រីនិងគ្រួសារខ្មែរតាមរយៈការបន្តអនុវត្តកម្មវិធីភាពជាមាតា និងបិតា ការអប់រំកូនតាមបែបវិជ្ជមាន ពង្រឹងវប្បធម៌អហិង្សាព្រមទាំងកសាងគ្រួសារប្រកបដោយសុភមង្គល។<br>- បន្តអនុវត្តកម្មវិធីឧបត្ថម្ភស្ត្រីមានផ្ទៃពោះនិងកុមារអាយុក្រោម២ឆ្នាំនៃគ្រួសារក្រីក្រ និងកម្មវិធីឧបត្ថម្ភកម្មការិនីមានផ្ទៃពោះ និងកូនអាយុក្រោម ២ឆ្នាំ។ | **ប្រជាជនកម្ពុជា** |
| ៣ | - រដ្ឋទទួលបន្ទុកតម្រូវការព្យាបាលសម្រាប់ ចាស់ជរា ជនពិការ ស្ត្រីឯកោមានផ្ទៃពោះ និងកុមារកំព្រា។ | **សំបុកឃ្មុំសង្គមប្រជាធិបតេយ្យ** |
| ៤ | - ផ្តល់ប្រាក់ឧបត្ថម្ភ និងប័ណ្ណទិញម្ហូបប្រចាំខែ និងប័ណ្ណធានារ៉ាប់រង ដើម្បីថែទាំព្យាបាលសុខភាពដោយវេជ្ជបណ្ឌិតមានបច្ចេកទេស និងទេពកោសល្យកម្រិតខ្ពស់មកពីបរទេសជូនជនក្រីក្រ ចាស់ជរា ជនពិការ កុមារ ស្ត្រីមានផ្ទៃពោះដោយឥតគិតថ្លៃ។ | **ខ្មែរឈប់ក្រ** |

| | | |
|---|---|---|
| | - ផ្ទង់ស្មារតីដើម្បីកាត់បន្ថយមរណភាពនៃស្ត្រីមានផ្ទៃពោះស្លាប់ ដោយផ្តល់ជំនួយពិសេសសម្រាប់ការសម្រាលទារក។ | |
| ៥ | - ចាស់ៗអាយុចាប់ពី៦៥ឆ្នាំឡើងទៅ ទទួលបានប្រាក់ឧបត្ថម្ភ៣សែនរៀលក្នុង១ខែ និងកុមារនៃគ្រួសារក្រីក្រក្រោមអាយុ៦ឆ្នាំ ទទួលបានប្រាក់ឧបត្ថម្ភ៤ម៉ឺនរៀលក្នុង១ខែ។<br>- លើកតម្លៃស្ត្រីឱ្យចូលរួមការងារសង្គម និងការងារនយោបាយឱ្យកាន់តែច្រើន<br>- ផ្តល់សិទ្ធិ និងតួនាទីដល់ស្ត្រី និងបុរសឱ្យស្មើភាពគ្នា<br>- ត្រូវលើកតម្កើង និងការពារស្ត្រី<br>- ផ្សព្វផ្សាយ និងអប់រំឱ្យបុរសបានយល់ដឹងអំពីបញ្ហាប្រឈមរបស់ស្ត្រី ដូចជាបញ្ហាសុខភាព និងកាតព្វកិច្ចនៅក្នុងគ្រួសារផងដែរ។<br>- គិតគូរលើច្បាប់ដែលផ្តល់នូវអាទិភាពដល់ស្ត្រី និងគិតគូរពីសុខភាពស្ត្រីជាចម្បង។ លើកផែនការឱ្យស្ត្រីមានឱកាសបានមកគ្រប់គ្រង និងកាន់នៅគ្រប់ក្រសួងស្ថាប័នឱ្យបានច្រើនយ៉ាងតិច ៥០%។ | **ឯកភាពជាតិខ្មែរ** |
| ៦ | - លើកកម្ពស់ឱ្យមានការចូលរួមដូចគ្នាទាំងអស់រវាងស្ត្រី និងបុរស។ ការប្រកួតប្រជែងដោយសំអាងទៅលើទ្រឹស្តីកម្មផល គិតពីសមត្ថភាព គិតពីកម្លាំងនៃការផលិត ដោយលើកតម្កើងទៅតាមជំនាញ និងកម្រិតនៃបច្ចេកទេសនិងការខិតខំប្រឹងប្រែង។<br>-ចំពោះសមភាពយេនឌ័រ ការលើកកម្ពស់ស្ត្រី គឺត្រូវតែគិតពីសមត្ថភាព<br>- ក្នុងចំណោមបេក្ខភាព ២៦៦នាក់ មានបេក្ខភាពជាស្ត្រីចំនួន ៦៤នាក់ ប្រហែល ២៤% គណបក្សក៏បានជម្រុញនិងលើកទឹកចិត្តស្ត្រីឱ្យមានការចូលរួមនៅក្នុងនយោបាយកាន់តែច្រើន។<br>- គោលនយោបាយជាក់លាក់ក្នុងការលើកកម្ពស់ស្ត្រីសំខាន់ៗរួមមាន៖<br>• ជម្រុញ និងលើកកម្ពស់ដល់មាតាបិតា ត្រូវជម្រុញឱ្យបុត្រីបុត្រារបស់គាត់បានចូលសាលារៀន។<br>• ជម្រុញនិងលើកកម្ពស់ដល់ការបញ្ចប់រាល់ទម្រង់នៃការរើសអើងទាំងអស់ទៅលើស្ត្រី និងកុមារី។ បង្កើនភាពអង់អាចក្លាហានរបស់ស្ត្រីនិងកុមារីតាមរយៈការបង្កើនការអប់រំ លើកកម្ពស់ការងារ (ការផ្តល់ការងារឱ្យពួកគាត់) ភាពជាតំណាងរបស់គាត់នៅក្នុងនយោបាយ ដោយលើកកម្ពស់សុខភាព មាតា និងទារក។<br>• ត្រូវជម្រុញ និងលើកកម្ពស់ដល់ការកសាងសមត្ថភាពជំនាញដល់ពួកគាត់ និងចូលរួមការងារទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិឱ្យមាន | **សញ្ញាតិកម្ពុជា** |

| | | |
|---|---|---|
| | ភាពស្មើគ្នា។<br>• ត្រូវជម្រុញ និងលើកកម្ពស់ដល់ក្រុមហ៊ុននិងដៃគូអភិវឌ្ឍផ្សេងៗទៀតក្នុងការជួយជម្រុញ និងលើកកម្ពស់ស្ត្រី។ | |
| ៧ | - សិក្សាពីរឿងស្ត្រី និងរកមធ្យោបាយដោះស្រាយជូនស្ត្រី<br>- ការពារសិទ្ធិ និងផលប្រយោជន៍របស់ប្រជាពលរដ្ឋគ្រប់រូបពីការរំលោភបំពានរបស់អ្នកមានអំណាច ការពារសិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ សិទ្ធិស្ត្រី សិទ្ធិការងារ សិទ្ធិសហជីព និងសិទ្ធិដីធ្លី។<br>- សទី១អំពីសេដ្ឋកិច្ច ៖ លោកយាយទាំងអស់មានអាយុចាប់ពី ៦៥ឆ្នាំ គឺ ផ្តល់ជូន ២៥០ ០០០រៀលក្នុងមួយខែ។<br>- សទី២អំពីការងារសុខាភិបាល ៖ ស្ត្រី និងកុមារ ទាំងលោកយាយវ័យចាស់ គឺសុទ្ធតែបានចូលទៅក្នុងមន្ទីរពេទ្យដោយមានការទទួលបម្រើសេវាយ៉ាងល្អ ចំពោះស្ត្រីដែលសម្រាលបុត្រ គឺ មានជួយជាការឧបត្ថម្ភនូវទឹកប្រាក់ចំនួន ៨០០ ០០០រៀល។<br>- សទី៣អំពីការសិក្សាធិការ ៖ ចំពោះកុមារវិញដើម្បីឱ្យមាតាបានទៅធ្វើការបានល្អ មាតាជួយបានល្អ គឺ សាលាមត្តេយ្យតាមភូមិជាសាលាដែលមានគុណភាពត្រឹមត្រូវមានបរិមាណល្អសមស្របទៅតាមសហគមន៍ដែលមាន។<br>- សទី៤ អំពីសង្គមកិច្ច<br>- សទី៥ អំពីសេវាកម្មសាធារណៈ<br>- មានក្រុមតំណាងស្ត្រីជាក្រុម ដែលប្រមូលព័ត៌មានទាក់ទងទៅនឹងអំពើហិង្សាដែលកើតឡើងក្នុងសហគមន៍ និងក្នុងគ្រួសារ។ រាល់អំពើហិង្សានឹងត្រូវដោះស្រាយ ដោយបានសិក្សាជាមួយនឹងឯកសារ មានទំនាក់ទំនងជាមួយអង្គការសង្គមស៊ីវិលនានាដែលពាក់ព័ន្ធទៅនឹងការងារ។ | **ប្រជាធិបតេយ្យមូលដ្ឋាន** |
| ៨ | - លើកកម្ពស់ស្ត្រី ដើម្បីផ្តល់នូវឱកាស វគ្គបណ្តុះបណ្តាល គួបផ្សំចំណេះដឹងផ្ទាល់ខ្លួន បទពិសោធដើម្បីឱ្យមានស្ត្រីកាន់តែច្រើននៅក្នុងការដឹកនាំប្រទេសឱ្យមានការរីកចម្រើនទៅមុខ។<br>- ជម្រុញឱ្យស្ត្រីមានភាពក្លាហាន ដើម្បីចូលរួមជួយក្នុងសង្គម រៀនសូត្រពីថ្នាក់ដឹកនាំល្អៗដើម្បីក្រេបយកចំណេះជំនាញ ជាទំពាំងស្នងឬស្សីដើម្បីអភិវឌ្ឍន៍ប្រទេសកាន់តែរីកចម្រើនទៅមុខ។<br>- មានវគ្គបណ្តុះបណ្តាលជូនបេក្ខជនស្ត្រី ដោយមានការចូលរួមរៀនសូត្រឱ្យមានចំណេះជំនាញ ដឹកនាំស្ត្រីឱ្យមានការងារធ្វើដើម្បីផ្លាស់ប្តូរជីវភាពគ្រួសារ និងមានចំណេះជំនាញនៅក្នុងខ្លួន ព្រមទាំងពង្រឹង និងពង្រីកខ្លួនឱ្យកាន់តែ | **ខ្មែររួបរួមជាតិ** |

| | | |
|---|---|---|
| | រឹងមាំ។<br>- លើកកម្ពស់កុមារ និងស្ត្រីក្រីក្រនៅតាមជនបទដើម្បីមានឱកាសចូលបម្រើការងារនៅក្នុងសង្គម ដោយលើកទឹកចិត្ត និងជម្រុញការបណ្តុះបណ្តាលដើម្បីពួកគាត់បានរៀនសូត្រ និងមានការងារធ្វើដើម្បីលើកកម្ពស់ស្ត្រីឱ្យកាន់តែមានជីវភាពរីកចម្រើន ហើយជួយសង្គមជាតិទាំងមូល កាត់បន្ថយការធ្វើការចំណាកស្រុកទៅក្រៅប្រទេស។<br>- ជួយស្ត្រីរងគ្រោះពីការគៀបសង្កត់នៅក្នុងគ្រួសារ ដូចជាអំពើហិង្សាក្នុងគ្រួសារ ប្ដីវ៉ៃធ្វើបាបប្រពន្ធកូន គ្មានភាពក្លាហានក្នុងការតវ៉ា ឬប្តឹងឱ្យអាជ្ញាធរធ្វើការអន្តរាគមន៍ទេ។ ចំពោះកុមារវិញ រងការគៀបសង្កត់ពីឪពុកម្ដាយដោយប្រើក្មេងមិនទាន់គ្រប់អាយុឱ្យទៅធ្វើការងារស៊ីឈ្នួលរកលុយបញ្ឈប់ពីការសិក្សារៀនសូត្រ។ | |
| ៩ | - បង្កើនឱ្យមានតម្លាភាពនៃការចូលរួមរបស់ស្ត្រីនៅក្នុងការអប់រំ ការងារទទួលបានប្រាក់ឈ្នួលក្រៅពីវិស័យឧស្សាហកម្ម រួមទាំងការឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រផង ដោយមានគោលនយោបាយដូចជា ៖<br>• រួមបញ្ចូលសមភាពយេនឌ័រនៅក្នុងក្របខ័ណ្ឌគោលនយោបាយនិងផែនការអភិវឌ្ឍរបស់គណបក្សកម្លាំងប្រជាធិបតេយ្យ ការកាត់បន្ថយគម្លាតយេនឌ័រក្នុងការអប់រំ បង្កើតគំនិតផ្តួចផ្តើមសហគ្រិនភាពសម្រាប់ស្ត្រី កាត់បន្ថយអំពើហិង្សានៅក្នុងគ្រួសារ និងការរំលោភបំពានផ្លូវភេទលើស្ត្រីនិងកុមារ រួមទាំងលើកកម្ពស់សីលធម៌សង្គមឱ្យកាន់តែមានតម្លៃថែមទៀត។<br>• ការលុបបំបាត់រាល់ទម្រង់នៃអំពើហិង្សា និងការជួញដូរស្ត្រី និងកុមារ ដោយត្រូវពន្យល់នៅតាមមូលដ្ឋានឱ្យចេះស្រលាញ់គ្រួសារ ជាពិសេសគឺត្រូវកាត់បន្ថយការពិសារនូវគ្រឿងស្រវឹង ការលេងល្បែងស៊ីសងនានា និងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ខូចដល់អនាគតគ្រួសារ និងអនាគតរបស់កុមារផងដែរ។<br>• ធានាឱ្យបានពេញលេញក្នុងភាពជាអ្នកដឹកនាំ ត្រូវផ្តល់ឱកាសឱ្យស្ត្រីដើម្បីចូលរួមក្នុងការដឹកនាំសង្គមជាតិ។<br>• ផ្តល់សិទ្ធិស្មើភាពគ្នាលើធនធានសេដ្ឋកិច្ច ការគ្រប់គ្រងអចលនទ្រព្យ និងសេវាកម្មហិរញ្ញវត្ថុ។<br>• លើកកម្ពស់សិទ្ធិអំណាចរបស់ស្ត្រីតាមរយៈការប្រើប្រាស់បច្ចេកវិទ្យា<br>• ពង្រឹងគោលនយោបាយ និងបទដ្ឋានគតិយុត្តនានា សម្រាប់លើក | **កម្លាំងប្រជាធិបតេយ្យ** |

| | | |
|---|---|---|
| | កម្ពស់សមភាពយេនឌ័រ។<br>• អប់រំឱ្យស្ត្រីជៀសឱ្យឆ្ងាយពីគ្រឿងញៀន និងល្បែងស៊ីសងផ្សេងៗ<br>• ពង្រឹងសិទ្ធិអំណាចស្ត្រីគឺ ការផ្តល់ឱកាសឱ្យគាត់បានចូលរួម និងផ្តល់ឱកាសឱ្យគាត់មានអាទិភាពក្នុងការសម្រេចទៅលើរឿងអ្វីមួយដែលជាសិទ្ធិនិងសេរីភាព។ ការផ្តល់អំណាចក្នុងការគ្រប់គ្រងទៅលើបណ្តាសហគ្រាស ឬគ្រប់គ្រងក្រុមហ៊ុនអ្វីមួយ គឺស្ត្រីមានសិទ្ធិជាអាទិភាព។ | |
| ១០ | - មានចក្ខុវិស័យឱ្យមានការផ្លាស់ប្តូរ ដើម្បីឱ្យស្ត្រីស្មើភាពគ្នាជាមួយបុរស។<br>- ពង្រឹងប្រព័ន្ធការពារស្ត្រី និងកុមារ<br>- កសាងក្របខ័ណ្ឌច្បាប់ ដើម្បីផ្តល់នូវការគាំទ្រទៅដល់ស្ត្រី និងកុមារ<br>- លុបបំបាត់នូវអំពើហិង្សានិងការប្រើប្រាស់អំពើហិង្សាទៅលើស្ត្រីនិង កុមារ។ | **យុវជនកម្ពុជា** |
| ១១ | - អប់រំ និងបណ្តុះបណ្តាលដល់ស្ត្រីឱ្យមានភាពរឹងមាំ ដើម្បីពួកគាត់មានអំណាចការពារផលប្រយោជន៍ក្រុមគ្រួសារ និងសង្គមជាតិ។ | **ធម្មាធិបតេយ្យ** |
| ១២ | - រៀបចំឱ្យមានសមាសភាពយេនឌ័រដែលផ្តល់ឱកាសឱ្យស្ត្រីបានចូលរួមក្នុងការងារសង្គម ការងារនយោបាយ សេដ្ឋកិច្ច វប្បធម៌ និងការងារអភិវឌ្ឍន៍ផ្សេងៗ។<br>- ការលើកទឹកចិត្ត ផ្តល់ឱកាសឱ្យស្ត្រីបានចូលរួមក្នុងការងារនយោបាយទាំងថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងនៅលើឆាកអន្តរជាតិ។ លើសពីនេះទៅទៀត គឺការកំណត់ថវិកាចំណាយថ្នាក់ជាតិសម្រាប់គាំពារស្ត្រី និងកុមារពីការរំលោភបំពានផ្សេងៗ អំពីការកេងប្រវ័ញ្ចនូវកម្លាំងពលកម្ម ឬការរើសអើងផ្សេងៗព្រមទាំងផ្តន្ទាទោសឱ្យបានតឹងរ៉ឹងបំផុតចំពោះអ្នកដែលប្រព្រឹត្តិបទល្មើសទាំងនោះ<br>- បង្កើតនូវបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) សម្រាប់ជួយដល់ស្ត្រីនិងកុមារ ពិសេសស្ត្រីដែលមានជីវភាពទីទល់ក្រ ស្ត្រីមេម៉ាយឬស្ត្រីគ្មានទីពឹង<br>- លើកទឹកចិត្ត និងផ្តល់ឱកាសឱ្យស្ត្រី និងកុមារីបានចូលរៀនសម្រាប់ចំណេះទូទៅគ្រប់កម្រិត គ្រប់ភូមិបានសិក្សាទាំងអស់ឱ្យមានជំនាញ វិជ្ជាជីវៈ និងរកប្រាក់ចំណូលបន្ថែម។<br>- បង្កើតនូវមជ្ឈមណ្ឌលសម្រាប់គាំពារស្ត្រី ដើម្បីបង្រៀនទាក់ទងនឹងការបង្កើតអាជីវកម្មខ្នាតតូចសម្រាប់ស្ត្រីដែលមិនសូវមានជំនាញឬចំណេះវិជ្ជាខ្ពង់ខ្ពស់និងផ្តល់អាហារូបករណ៍ជាច្រើនកន្លែងជូនចំពោះ ជាពិសេសនិស្សិតស្រីឱ្យមានឱកាសបានបន្តការសិក្សានៅក្នុង និងក្រៅប្រទេស។<br>- លុបបំបាត់នូវអំពើហិង្សាក្នុងគ្រួសារដែលបង្កឡើងដោយភាគីជាបុរស និងអំពើហិង្សាមកលើស្ត្រី និងកុមារដែលបម្រើការងារនៅតាមផ្ទះ។ | **ហ៊្វុនស៊ិនប៉ិច** |

| | | |
|---|---|---|
| ១៣ | - លើកកម្ពស់សិទ្ធិស្ត្រីឱ្យចូលរួមគ្រប់ទម្រង់ក្នុងវិស័យនយោបាយ សង្គម វិស័យឯកជន ជាដើម។<br>- លុបបំបាត់អំពើហិង្សាគ្រប់ទម្រង់ ទោះបីជាអំពើហិង្សាផ្លូវកាយ ផ្លូវចិត្ត និង ផ្តន្ទាទោសជនទាំងឡាយណាដែលប្រើប្រាស់នូវអំពើហិង្សាទៅលើស្ត្រីឱ្យ សមនឹងទង្វើដែលបានប្រព្រឹត្តិ។<br>- ផ្តល់ឱ្យស្ត្រីទទួលបានការសិក្សា និងកាត់បន្ថយការបោះបង់ចោលការសិក្សា របស់ស្ត្រីជាអតិបរមា។<br>- ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងផ្តល់ឱកាសការងារដល់ស្ត្រីដោយទាក់ទង ជាមួយស្ត្រីដែលមានពិការភាព ដោយសារពួកគាត់ទទួលបានការរើសអើង នៅក្នុងសង្គមចំពោះអ្នកគ្មានកាយសម្បទាគ្រប់គ្រាន់។ | **បំណងពលរដ្ឋ** |

## តារាងទី២០ ៖ កម្មវិធីនយោបាយរបស់គណបក្សតាមមណ្ឌលខេត្ត ដែលបានសន្យា ដោយបេក្ខជនស្ត្រីដើម្បីដោះស្រាយបញ្ហាស្ត្រី និងកុមារ



*ប្រភព ៖ Fresh News*



*ប្រភព ៖ គណបក្សហ្វ៊ុនស៊ិនប៉ិច*

ការឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២៩២៣នេះ បេក្ខជនស្ត្រីឈរឈ្មោះបានឃោសនាតាមកម្មវិធីនយោបាយរបស់គណបក្សខ្លួន និងបានធ្វើការសន្យាបន្ថែមទៅតាមតម្រូវការក្នុងមណ្ឌលខេត្តដោយឡែកៗពីគ្នាទាក់ទិននឹងបញ្ហាស្ត្រី និងកុមារ។ ការសន្យាសំខាន់ៗ តាមមណ្ឌលខេត្តនេះ បានដកស្រង់ព័ត៌មានពីបេក្ខជនស្ត្រីក្នុងតំបន់គោលដៅរបស់ខុមហ្វ្រែល ចំនួន**៥ខេត្តគឺ ខេត្តកំពង់ចាម ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ធំ ខេត្តតាកែវ និងខេត្តព្រះវិហារ**។

| ល.រ | កម្មវិធីនយោបាយរបស់គណបក្ស និងការសន្យាបន្ថែមរបស់បេក្ខជនតាមមណ្ឌលខេត្ត | បេក្ខជនស្ត្រី | ឈ្មោះគណបក្សនយោបាយ |
|---|---|---|---|
| ១ | ជួយជាស្បៀង និងជួសជុលផ្ទះសម្បែងដល់ស្ត្រីដែលជួបការលំបាក គ្មានផ្ទះសម្បែង ស្ត្រីមេម៉ាយ និងស្ត្រីចាស់ជរា។ ពេលសម្រាលកូនមានថវិកាជូនចំនួន**៥០ ០០០រៀល** និងចុះសំបុត្រកំណើតឱ្យកូនទើបកើតភ្លាមៗតែម្តង។ | បេក្ខជនស្ត្រី ខេត្តកំពង់ឆ្នាំង | ប្រជាជនកម្ពុជា |
| ២ | ជួយកុមារមានជម្ងឺ (ផ្តល់ជាថវិកា) មនុស្សចាស់ជរាផ្តល់ជាអង្ករគ្រឿងបរិភោគនិងថវិកាតាមលទ្ធភាព។ ជួយស្ត្រីមានផ្ទៃពោះនិងពិនិត្យសុខភាពនៅពេលសម្រាលមិនយកថ្លៃសេវា។ | បេក្ខជនស្ត្រី ខេត្តព្រះវិហារ | |
| ៣ | លើកស្ទួយសមភាពយេនឌ័រ ៖ លុបបំបាត់អំពើហិង្សាក្នុងគ្រួសារ ជួយកុមារដែលមិនបានចូលរៀនសូត្រ ឬខ្វះសម្ភារៈក្នុងការសិក្សា និងលើកស្ទួយស្ត្រីឱ្យមានសិទ្ធិស្មើនឹងបុរស។ | បេក្ខជនស្ត្រី ខេត្តកំពង់ចាម | |
| ៤ | ខិតខំជួយជំរុញឱ្យស្ត្រីមានភាពក្លាហាន មានភាពវៃឆ្លាតនិងរកការងារជូនស្ត្រី និងការពារពីការរំលោភសិទ្ធិស្ត្រី។ ផ្តល់សេវាកម្មសម្រាលកូន ជួយសាងសង់លំនៅឋាន ជួយស្ត្រីចាស់ជរា និងលើកទឹកចិត្តស្ត្រីក្នុងការធ្វើនយោបាយ។ | បេក្ខជនស្ត្រី ខេត្តកំពង់ចាម | |
| ៥ | **ចំពោះស្ត្រី** ៖ លើកកម្ពស់សិទ្ធិស្ត្រី និងបុរសឱ្យស្មើភាពគ្នានិងជំរុញស្ត្រីក្នុងគោលនយោបាយ។ ពង្រឹងផ្នែកដឹកនាំឯកជននិងសាធារណៈ ដឹកនាំវិស័យសេដ្ឋកិច្ច ពង្រឹងផ្នែកការងារទប់ស្កាត់អំពើហិង្សា អប់រំស្ត្រីផ្នែកសីលធម៌និងវប្បធម៌ និងយកចិត្តទុកដាក់ផ្នែកសុខភាព ។ល។<br>**ចំពោះកុមារ** ៖ លុបបំបាត់ការឈប់រៀននៅកម្រិតថ្នាក់បឋមនិងមធ្យមសិក្សា។ ការពារកុមារពីអំពើហិង្សានិងការរំលោភសិទ្ធិពលកម្មកុមារ និងមានការគិតគូរអំពីសុខភាព។ | បេក្ខជនស្ត្រី ខេត្តកំពង់ចាម | |

| | | | |
|---|---|---|---|
| ៦ | ដើម្បីលើកស្ទួយសមភាពយេនឌ័រ គឺជួយជំរុញឱ្យពួកគាត់មានសេចក្តីក្លាហានក្នុងការធ្វើការងារសង្គមជាតិ និងចូលរួមវគ្គបណ្តុះបណ្តាលនៅតាមស្ថាប័ន ឬអង្គការដៃគូរឱ្យបានច្រើន ដើម្បីបង្កើនចំណេះដឹង និងទទួលបាននូវបទពិសោធថ្មីៗថែមទៀតផង។ ជួយដោះស្រាយអំពើហិង្សាក្នុងគ្រួសារ ការជួញដូរមនុស្សទៅក្រៅប្រទេស និងជួយបង្រៀនអក្ខរកម្មដល់មនុស្សចាស់ និងកុមារឱ្យចេះសរសេរ និងចេះអាន។ | បេក្ខជនស្ត្រី ខេត្តកំពង់ធំ | |
| ៧ | ដោះស្រាយបញ្ហាស្ត្រីនិងកុមារ លើកស្ទួយសមភាពយេនឌ័រ ដូចជាផ្តល់ថវិកាជូនស្ត្រីនិងកុមារ ចាប់ពីពេលពពោះរហូតដល់កុមារមានអាយុ ២ឆ្នាំ។ ជួយស្ត្រី និងកុមារងាយរងគ្រោះបញ្ហាខ្វះខាតលុយ ការផ្តល់ការសិក្សាដល់កុមារ និងយុវជនឱ្យមានការងារធ្វើ។ ជួយគ្រួសារក្រីក្រ ផ្តល់សេវាសុខភាពនៅតាមមន្ទីរពេទ្យរដ្ឋដោយមិនយកលុយ។ | បេក្ខជនស្ត្រី ខេត្តតាកែវ | |
| ៨ | ផ្តល់សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ ជំនឿសាសនា និងលុបបំបាត់ការជួញដូរស្ត្រី និងកុមារ។ លើកកម្ពស់សិទ្ធិនារីក្នុងការចូលរួមវិស័យនយោបាយនិងអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ | បេក្ខជនស្ត្រី ខេត្តតាកែវ | ហ៊្វុនស៊ិនប៉ិច |

## ៦- សមាជិកស្ត្រីរបស់គ.ជ.ប លធ.ខប គធ.ខប គឃ.សប មន្ត្រីការិយាល័យបោះឆ្នោតនិងរាប់សន្លឹកឆ្នោត

### ថ្នាក់ជាតិ

> ស្ត្រីនៅតែមានចំនួនតិចតួចក្នុងតួនាទីជាអ្នកគ្រប់គ្រង និងចាត់ចែងការបោះឆ្នោតនៅថ្នាក់ជាតិសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ ឆ្នាំ២០២៣។

ពុំមានស្ត្រីសោះជាអ្នកដឹកនាំនៅថ្នាក់ជាតិជាសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ក្នុងចំណោមសមាសភាពទាំង**៩រូប** និងជាអគ្គលេខាធិការនិងអគ្គលេខាធិការរងទាំង**៥រូប** ។ ចំណែកឯមន្ត្រីក្របខណ្ឌ មន្ត្រីកិច្ចសន្យារយៈពេលវែង មន្ត្រីកិច្ចសន្យារយៈពេលខ្លី និងមន្ត្រីមួយចំនួនទៀតតាមភាពចាំបាច់ដែលបានបម្រើការនៅស្ថាប័នគ.ជ.ប ថ្នាក់ជាតិ សរុបចំនួន **១ ៧០២នាក់** ក្នុងនោះស្ត្រីមានចំនួន **៤៥០នាក់ ស្មើនឹង ២៦,៤%**[13] សម្រាប់ចាត់ចែង ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣។

[13] សេចក្តីរាយការណ៍ពីសមាជិក គ.ជ.ប

## ថ្នាក់ក្រោមជាតិ

ពុំមានទិន្នន័យពីគ.ជ.បអំពីមន្ត្រីចាត់ចែងការបោះឆ្នោត នៅថ្នាក់ក្រោមជាតិ ។



*ប្រភព ៖ ខុមហ្វ្រែល*

## ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត

ពុំមានទិន្នន័យពីគ.ជ.ប អំពីមន្ត្រីការិយាល័យ បោះឆ្នោត និងរាប់សន្លឹកឆ្នោត






*ប្រភព ៖ Phnom Penh Post*

ក្រាហ្វិកទី២១ ៖ តួនាទីរបស់ស្ត្រីជាមន្ត្រីការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត




ប្រភព ៖ ខុមហ្វ្រែល និងហ្វេតស៊ី

ក្រាហ្វិកទី២២




ប្រភព ៖ ខុមហ្វ្រែល និងហ្គេតស៊ី

របាយការណ៍សង្កេតការណ៍របស់ខុមហ្វ្រែល និងហ្គេតស៊ី ស្តីពី« *ការចូលរួមនយោបាយរបស់ស្ត្រីក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣*» បានរកឃើញថា នៅថ្ងៃបោះឆ្នោត ភាគរយសរុបនៃមន្ត្រីការិយាល័យបោះឆ្នោតនិងរាប់សន្លឹកឆ្នោតជាស្ត្រី និងបុរស មានភាគរយប្រហាក់ប្រហែលគ្នា គឺ ស្ត្រីចំនួន **៣៥៤នាក់ ស្មើនឹង ៤៨,៤% និងបុរសចំនួន ៣៧៨នាក់ ស្មើនឹង ៥១,៦%** នៃចំនួនសរុប **៧៣២នាក់** ក្នុង**១២៤**ការិយាល័យបោះឆ្នោតនិងរាប់សន្លឹកឆ្នោត ។ ទោះបីយ៉ាងណា ស្ត្រីជាមន្ត្រីការិយាល័យបោះឆ្នោត**ភាគច្រើន**មានតួនាទីជា**សមាជិក**ចំនួន**៤៩,៤%** ខណៈដែលតួនាទីជា**ប្រធាន**មាន**តិចតួច ៨,៥%** ប៉ុណ្ណោះ។ ចំណែកឯ តួនាទីជា**លេខាធិការ**មានចំនួន **២៥,១%** និងជា**អនុប្រធាន**មានចំនួន **១៦,៩% ជាភាគរយប្រហាក់ប្រហែលនឹងបុរសដែរ**[14]។

## ៧- អ្នកសង្កេតការណ៍ ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសារព័ត៌មាន

ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣នេះ ជាពិសេសនៅថ្ងៃបោះឆ្នោតនិងរាប់សន្លឹកឆ្នោត អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍន៍ បណ្តាស្ថានទូតនានាប្រចាំនៅកម្ពុជា និងគណបក្សនយោបាយ បានដាក់ពង្រាយអ្នកសង្កេតការណ៍ និងតំណាងរបស់ខ្លួនតាមការិយាល័យបោះឆ្នោតនៃរាជធានី ខេត្តនីមួយៗ ដើម្បីចូលរួមសង្កេត ឃ្លាំមើលដំណើរការរៀបចំការបោះឆ្នោត ។ តាមតួលេខផ្លូវការរបស់ គ.ជ.ប បានបង្ហាញនូវចំនួនអ្នកសង្កេតការណ៍ជាតិ អន្តរជាតិ ភ្ញៀវពិសេស ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសារព័ត៌មាន ដូចខាងក្រោម[15] ៖

[14] ការដាក់ពង្រាយអ្នកសង្កេតការណ៍ស្ត្រី-បុរសនៃខុមហ្វ្រែល និងហ្គេតស៊ី ក្នុងតំបន់គោលដៅចំនួន ៧ខេត្ត នៅថ្ងៃបោះឆ្នោតនិងរាប់សន្លឹកឆ្នោត ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣

[15] លទ្ធផលផ្លូវការនៃការចុះឈ្មោះអ្នកសង្កេតការណ៍ជាតិ-អន្តរជាតិ និងភ្ញៀវពិសេសសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ និងសេចក្តីប្រកាសព័ត៌មាន ស្តីពីសរុបព្រឹត្តិការណ៍ថ្ងៃបោះឆ្នោត ដោយគ.ជ.ប នៅថ្ងៃទី២២ និងទី២៤ ខែកក្កដា ឆ្នាំ២០២៣

## អ្នកសង្កេតការណ៍ជាតិជាស្ត្រី




ប្រភព ៖ ខុមហ្វ្រែល

**អ្នកសង្កេតការណ៍ជាតិជាស្ត្រី**ដែលគ.ជ.ប បានអនុញ្ញាតឱ្យ ចូលរួមសង្កេតមើលដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ មានចំនួន **៥២ ៦៥២នាក់ ស្មើនឹង ៥៨,៨%** ក្នុងនោះ**ស្ត្រីមានពិការភាព** ចំនួន**១២នាក់ ស្ត្រីម៉ូស្លីម** ចំនួន **១៧៥នាក់** និង**ស្ត្រីជនជាតិដើមភាគតិច**ចំនួន**២នាក់** នៃចំនួនសរុប **៨៩ ៥៦២នាក់** មកពីសមាគម-អង្គការមិនមែនរដ្ឋាភិបាលចំនួន ១៣៤ស្ថាប័ន ហើយចំនួនសរុបអ្នកសង្កេតការណ៍ជាតិនេះបាន**កើនឡើង ១២,៥%** បើធៀបនឹងនីតិកាលទី៦ ឆ្នាំ២០១៨ មានចំនួនសរុបតែ ៧៩ ៦១២នាក់។




ប្រភព ៖ ខុមហ្វ្រែល

គួរកត់សម្គាល់ថា ការបោះឆ្នោតជាតិលើកនេះ **អ្នកសង្កេតការណ៍ជាស្ត្រីមានចំនួនច្រើនជាងបុរស។** ជាក់ស្តែង សមាគមនារីកម្ពុជាដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ (CWPD)បានដាក់ពង្រាយអ្នកសង្កេតការណ៍ស្ត្រីរបស់ខ្លួនស្ទើរតែ១០០%ទូទាំងប្រទេស មានចំនួន **២៦ ៦៩២នាក់** ស្មើនឹង **៩៩,៩%** នៃចំនួនសរុប **២៦ ៦៩៥នាក់។** ចំណែកឯអង្គការខុមហ្វ្រែលបានដាក់ពង្រាយអ្នកសង្កេតការណ៍របស់ខ្លួនសរុបចំនួន **៥ ០៣៦នាក់** ក្នុងនោះ ស្ត្រី ចំនួន **២ ៣៤០នាក់** ស្មើនឹង **៤៦,៥%**។ ដោយឡែក សហភាពសហព័ន្ធយុវជនកម្ពុជាបានដាក់ពង្រាយអ្នកសង្កេតការណ៍របស់ខ្លួនទូទាំងប្រទេស**ច្រើនជាងគេ** ចំនួន **៤១ ៣៣៣នាក់** ក្នុងនោះ ស្ត្រីចំនួន **១៧ ៨៩៩នាក់** ស្មើនឹង **៤៣,៣%** សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣នេះ។ (*ព័ត៌មានលម្អិតសូមមើលឧបសម្ព័ន្ធទី៤*)

មិនមានការប្រឈមគួរឱ្យកត់សម្គាល់មកលើអ្នកសង្កេតការណ៍ស្ត្រីរបស់ខុមហ្វ្រែល និងអ្នកសង្កេតការណ៍ស្ត្រី-បុរស របស់ អង្គការហ្គេតស៊ី នៅថ្ងៃបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើយ។ មន្ត្រីការិយាល័យបោះឆ្នោតបានផ្តល់អាទិភាពឱ្យអ្នកសង្កេតការណ៍ស្ត្រី-បុរសទាំងនោះបានបោះឆ្នោតមុន និងបានអនុញ្ញាតឱ្យចូលសង្កេតការណ៍នៅក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ស្របតាមបទបញ្ជា និងនីតិវិធីបោះឆ្នោត។

## អ្នកសង្កេតការណ៍អន្តរជាតិជាស្ត្រី

**អ្នកសង្កេតការណ៍អន្តរជាតិជាស្ត្រី**ដែលគ.ជ.បបានអនុញ្ញាត មានចំនួន **១៦៣នាក់ ស្មើនឹង ២៧,៨%** នៃចំនួនសរុប**៥៨៤នាក់**ដែលមកពី ប្រទេស គណៈកម្មការរៀបចំការបោះឆ្នោត ស្ថានទូត សហគមន៍ សភា ស្ថាប័នស្រាវជ្រាវ អ្នកបកប្រែភាសា សមាគម និងអង្គការអន្តរជាតិ សរុបចំនួន៥២ស្ថាប័ន។ ចំនួនប្រុស-ស្រីនៃអ្នកសង្កេតការណ៍អន្តរជាតិនេះ បាន**កើនឡើង** ចំនួន **២៦២នាក់** (៨១,៤%) ពី ៣២២នាក់ក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ឆ្នាំ២០១៨ ទៅ ៥៨៤នាក់ នីតិកាលទី៧ ឆ្នាំ២០២៣។

## ភ្ញៀវពិសេសជាស្ត្រី

**ភ្ញៀវពិសេសជាស្ត្រី**ដែលគ.ជ.បបានអនុញ្ញាតដើម្បីសង្កេតលើដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ មានចំនួន **៧នាក់** ស្មើនឹង **៣៩%** នៃចំនួនសរុបស្រី-ប្រុស ១៨នាក់ ដែលមកពី បណ្ដាស្ថានទូតមួយចំនួន សមាគមនិងសាកលវិទ្យាល័យបរទេសសរុបចំនួន ១០ស្ថាប័ន។

## ភ្នាក់ងារគណបក្សនយោបាយជាស្ត្រី

| ភ្នាក់ងារគណបក្សនយោបាយពេញសិទ្ធិ-បម្រុង នីតិកាលទី៧ ឆ្នាំ២០២៣ | | | | |
|---|---|---|---|---|
| សរុប ស្ត្រី-ប្រុស | ស្ត្រី | | ប្រុស | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| ៥៧ ០១២នាក់ | ១៦ ៦២៤នាក់ | ២៩,២% | ៤០ ៣៨៨នាក់ | ៧០,៨% |

ប្រភព ៖ គ.ជ.ប

[16]**ភ្នាក់ងារគណបក្សនយោបាយជាស្ត្រី**ដែលបានអនុញ្ញាតដោយ គ.ជ.ប មានចំនួន **១៦ ៦២៤នាក់ ស្មើនឹង២៩,១%** (ពេញសិទ្ធិនិងបម្រុង) នៃចំនួនសរុបស្រី-ប្រុស **៥៧ ០១២នាក់** (ពេញសិទ្ធិនិងបម្រុង) មកពី **៨ គណបក្សនយោបាយ** ដើម្បីសង្កេតមើលការបោះឆ្នោតនៅតាមការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣។ ចំនួនសរុបនេះ បាន**ថយចុះ** **២២ ៨៣៧នាក់** (២៨,៦%) បើធៀបនឹងនីតិកាលទី៦ ឆ្នាំ២០១៨ មានចំនួន សរុប **៧៩ ៨៤៩នាក់**។

## អ្នកសារព័ត៌មានជាតិ និងអន្តរជាតិជាស្ត្រី

**អ្នកសារព័ត៌មានជាតិ និងអន្តរជាតិជាស្ត្រី**ដែលបានអនុញ្ញាតដោយ គ.ជ.ប មានចំនួន **២១៥នាក់ ស្មើនឹង១៥%** នៃចំនួនសរុបស្រី-ប្រុស **១ ៤២៦នាក់** ក្នុងនោះ**អ្នកសារព័ត៌មានជាតិជាស្ត្រី** មានចំនួន **១៨៥នាក់** (១៤,៤%)នៃចំនួនសរុប១ ២៨៩នាក់មកពី**១២៧អង្គភាព** និង**អ្នកសារព័ត៌មានអន្តរជាតិជាស្ត្រី**ចំនួន **៣០នាក់**

---

[16] លទ្ធផលផ្លូវការនៃការចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ដោយគ.ជ.ប នៅថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០២៣

(២១,៩%) នៃចំនួនសរុប ១៣៧នាក់ មកពី **៣៨អង្គភាព** ដើម្បីចូលរួមយកព័ត៌មានក្នុងដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣[17]។

## ៨- អ្នកបោះឆ្នោតស្ត្រី

## ៨.១. ស្ត្រីក្នុងការពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ២០២២

### ក. ស្ត្រីដែលបានពិនិត្យឈ្មោះ និងបានចុះឈ្មោះបោះឆ្នោត

| ចំនួនអ្នកបានពិនិត្យឈ្មោះ និងបានចុះឈ្មោះបោះឆ្នោត ប្រចាំឆ្នាំ២០២២ | | | |
|---|---|---|---|
| ចំនួនសរុប ស្រី-ប្រុស | | ចំនួនស្ត្រី | |
| ចំនួន | % | ចំនួន | % |
| ៩ ៧១០ ៦៥៥ | ៨៩,៣ | ៥ ១៦១ ៩០៩ | ៥៣,២ |

**ប្រភព ៖ គ.ជ.ប** *(សូមមើលព័ត៌មានលម្អិតនៅក្នុងឧបសម្ព័ន្ធទី៥)*

យោងតាមលទ្ធផលផ្លូវការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០២២ ចេញផ្សាយដោយគ.ជ.ប នៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៣ ស្ត្រីបានចុះឈ្មោះបោះឆ្នោត និងមានឈ្មោះក្នុងបញ្ជីអ្នកបោះឆ្នោតទូទាំងប្រទេសមានចំនួន **៥៣,២%** ស្មើនឹង **៥ ១៦១ ៩០៩នាក់** នៃចំនួនប្រុស-ស្រីសរុប ៩ ៧១០ ៦៥៥ នាក់។ ដោយឡែកក្នុងតំបន់គោលដៅរបស់ខុមហ្វ្រែល ចំនួន១០ឃុំ សង្កាត់ ក្នុង៥ខេត្ត ស្ត្រីបានចុះឈ្មោះថ្មី មានចំនួន ១១ ៣១៩នាក់ (៥៣,៦%) និងបុរសចំនួន ៩ ៨១៥នាក់ (៤៦,៤%) នៃចំនួនសរុបប្រុស-ស្រី ២១.១៣៤នាក់ ក្នុងនោះមានស្ត្រីវ័យក្មេងចំនួន ៥៨៧នាក់ (២,៨%)។

អ្នកសង្កេតការណ៍ស្ត្រីខុមហ្វ្រែល បានជួបសម្ភាសន៍បែបសំណេះសំណាលជាមួយនឹងស្ត្រីដែលបានពិនិត្យបញ្ជីឈ្មោះ និងបានចុះឈ្មោះបោះឆ្នោត ចំនួន **៦០នាក់** ដោយទទួលបានហេតុផលមួយចំនួន[18] ៖

| អំពី «ភាពងាយស្រួល» ក្នុងឃុំ សង្កាត់ | |
|---|---|
| **ការពិនិត្យបញ្ជីឈ្មោះ** | **ការចុះឈ្មោះបោះឆ្នោត** |
| ងាយស្រួលពិនិត្យឈ្មោះ ដោយសារមានប្រជាពលរដ្ឋតិចទៅពិនិត្យបញ្ជីឈ្មោះ។ | មានភាពងាយស្រួលក្នុងការចុះឈ្មោះបោះឆ្នោត ព្រោះកន្លែងចុះឈ្មោះនៅជិតផ្ទះ។ |
| មានមន្ត្រីក.ច.បចាំជួយពិនិត្យ និងរកឈ្មោះជូនប្រជាពលរដ្ឋ។ | មន្ត្រីចុះឈ្មោះ(ក.ច.ប)មានការលើកទឹកចិត្តអ្នកមកចុះឈ្មោះ យកចិត្តទុកដាក់ រាក់ទាក់ជួយសម្រួលដល់ប្រជាពលរដ្ឋប្រើពាក្យសំដីគួរជាទីគោរព។ |
| ក្រុមមន្ត្រីក.ច.បបានធ្វើការផ្សព្វផ្សាយបានទូលំទូលាយនៅតាមសហគមន៍ ភូមិ ឃុំ សង្កាត់ ដើម្បីណែនាំទៅកាន់ប្រជាពលរដ្ឋទាក់ទងនឹងដំណើរការពិនិត្យបញ្ជី | មានការិយាល័យចុះឈ្មោះចល័តនៅតាមភូមិដោយ ក.ច.ប ចុះមកដល់ទីកន្លែងរស់នៅផ្ទាល់។ |

[17] លទ្ធផលផ្លូវការនៃការចុះឈ្មោះអ្នកសារព័ត៌មានជាតិនិងអន្តរជាតិសម្រាប់ចូលរួមយកព័ត៌មានក្នុងដំណើរការបោះឆ្នោត ដោយគ.ជ.ប នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២៣

[18] ខុមហ្វ្រែលបានដាក់ពង្រាយអ្នកសង្កេតការណ៍ស្ត្រីក្នុងខេត្តគោលដៅ៥ ៖ ខេត្តកំពង់ចាម ខេត្តកំពង់ធំ ខេត្តកំពង់ឆ្នាំង ខេត្តតាកែវ និងខេត្តព្រះវិហារ ក្នុងរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ប្រចាំឆ្នាំ២០២២

| | |
|---|---|
| ឈ្មោះ និងចុះឈ្មោះបោះឆ្នោត។ | |
| ពិនិត្យឈ្មោះក្នុងឃុំ សង្កាត់ដោយផ្ទាល់ និងចូលមើលក្នុងវេសាយរបស់គ.ជ.ប។ | ការចុះឈ្មោះបោះឆ្នោតមាននីតិវិធីល្អ ដោយសារគេចុះឈ្មោះតាមប្រព័ន្ធកុំព្យូទ័រ និងថតរូបនៅនឹងកន្លែងចុះឈ្មោះ។ |
| បិទបញ្ជីឈ្មោះមានរបៀបរៀបរយល្អនិងចាត់ចែងបានល្អ។ | អាជ្ញាធរចេញឯកសារបញ្ជាក់អត្តសញ្ញាណសម្រាប់ចុះឈ្មោះជូនប្រជាពលរដ្ឋ ដោយគ្មានការរើសអើង។ |
| មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងមានប័ណ្ណព័ត៌មានកាន់មកជាមួយ។ | |

| អំពី «ការលំបាក» ក្នុងឃុំ-សង្កាត់ | |
|---|---|
| **ការពិនិត្យបញ្ជីឈ្មោះ** | **ការចុះឈ្មោះបោះឆ្នោត** |
| គ្មាន | ប្រជាពលរដ្ឋខ្លះខ្វះឯកសារសម្រាប់ចុះឈ្មោះ |

| មូលហេតុដែលស្ត្រីទៅពិនិត្យឈ្មោះ និងទៅចុះឈ្មោះបោះឆ្នោត | |
|---|---|
| **ពិនិត្យបញ្ជីឈ្មោះ** | **ចុះឈ្មោះបោះឆ្នោត** |
| ខ្លាចខុសឈ្មោះពី អ.ខ | ព្រោះគ្រប់អាយុត្រូវចុះឈ្មោះបោះឆ្នោត |
| ខ្លាចបាត់ឈ្មោះ | បំពេញតួនាទី ភារកិច្ចជាពលរដ្ឋខ្មែរ |
| ខ្លាចគ្មានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោត | មានសិទ្ធិក្នុងការជ្រើសរើសតំណាងល្អ |
| ខ្លាចមិនបានបោះឆ្នោត | ដើម្បីបានបោះឆ្នោតឱ្យបានរីកចម្រើននៅក្នុងប្រទេស |
| ដើម្បីប្រាកដថាមានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោត។ | |
| ដើម្បីងាយស្រួលក្នុងការមកបោះឆ្នោត និងអាចជ្រើសរើសគណបក្សដែលខ្លួនពេញចិត្ត។ | |
| ចង់បានអ្នកដឹកនាំល្អ១រូប ដើម្បីបំរើដល់សង្គមជាតិយើង | |

*២. ចំណាប់អារម្មណ៍ និងការយល់ឃើញផ្ទាល់របស់អ្នកសង្កេតការណ៍ស្ត្រីខុមព្រៃហ្វែល*

| ដំណើរការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ | | |
|---|---|---|
| **ទិដ្ឋភាពរួម** | **ចំណុចខ្លាំង** | **ចំណុចខ្សោយ** |
| ◇ មានសុវត្ថិភាពនិងដំណើរការល្អ<br>◇ ឃុំខ្លះមិនសូវមានមនុស្សច្រើន ទៅពិនិត្យឈ្មោះនិងចុះឈ្មោះបោះឆ្នោត។<br>◇ ប្រជាពលរដ្ឋចូលរួមច្រើន ហើយមន្ត្រីក.ច.បមានការ | ▪ មន្ត្រីចុះឈ្មោះបោះឆ្នោតរួសរាយមានក្រមសីលធម៌ល្អ (ប្រើពាក្យសម្ដីគួរឱ្យគោរព)។<br>▪ ផ្ដល់ព័ត៌មានបានលឿន<br>▪ គោរពពេលវេលានិងធ្វើការរហ័សរហួន។<br>▪ បានត្រៀមជាមុនដោយពន្យល់ក្បោះក្បាយពីលក្ខខណ្ឌនិងរបៀបធ្វើឯកសារ។<br>▪ ប្រជាពលរដ្ឋមានការយល់ដឹងច្រើន | • គ្មានស្ត្រីជាមន្ត្រីចុះឈ្មោះបោះឆ្នោតនៅឃុំមួយចំនួន។<br>•មន្ត្រីក.ច.បខ្លះមិនសូវសហការគ្នា។<br>• ក្រុមប្រឹក្សាឃុំ សង្កាត់មិនសូវសហការជាមួយអ្នកអ្នកសង្កេតការណ៍។ |

| | | |
|---|---|---|
| យកចិត្តទុកដាក់និងពន្យល់បានក្បោះក្បាយទៅកាន់ប្រជាពលរដ្ឋ។<br>◇ មន្ត្រីចុះឈ្មោះបោះឆ្នោតផ្តល់សេវាល្អនិងធ្វើការទៀងពេលវេលា។<br>◇ សហការបានល្អ<br>◇ ចេះជួយសម្របសម្រួល និងផ្តល់ភាពងាយស្រួលដល់ប្រជាពលរដ្ឋ និងអ្នកសង្កេតការណ៍។ | ▪ អ្នកសង្កេតការណ៍បានសហការជាមួយមន្ត្រីក.ច.ប<br>▪ ក្រុមមន្ត្រីក.ច.បចេះសហការជាមួយក្រុមប្រឹក្សាឃុំ សង្កាត់បានល្អ។<br>▪ សំណេះសំណាលជាមួយប្រជាពលរដ្ឋដែលមកពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោត។<br>▪ មានឯកសារគ្រប់គ្រាន់<br>▪ ក្រុមការងារឃុំ សង្កាត់ចុះផ្តល់ព័ត៌មានផ្ទាល់តាមផ្ទះប្រជាពលរដ្ឋ។<br>▪ ដំណើរការធ្វើអត្តសញ្ញាណប័ណ្ណថ្មីជូនប្រជាពលរដ្ឋប្រកបទៅដោយរលូន។<br>▪ ក្រុមមន្ត្រីក.ច.ប និងមន្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ធ្វើការទៀងពេលវេលាល្អ។<br>▪ ប្រធាននិងអនុប្រធានឬការីកុំព្យូទ័របិទបញ្ជីឈ្មោះបានល្អ។<br>▪ មន្ត្រីក.ច.បផ្តល់ព័ត៌មានច្បាស់លាស់ជូនប្រ.ពលរដ្ឋ | • ប្រជាពលរដ្ឋខ្លះមិនយល់អំពីនីតិវិធីនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតរបស់ គ.ជ.ប។<br>•ប្រជាពលរដ្ឋមិនយកចិត្តទុកដាក់<br>• ប្រជាពលរដ្ឋមួយចំនួនតូចខ្វះឯកសារ។<br>• មន្ត្រីក.ច.បមួយចំនួនខ្វះក្រមសីលធម៌។ |

## ៨.២. ថ្ងៃបោះឆ្នោត



រូបភាព ៖ KBN News

អ្នកមានសិទ្ធិបោះឆ្នោតជាស្ត្រីនៅក្នុងបញ្ជីបោះឆ្នោតផ្លូវការ ឆ្នាំ២០២២មានចំនួន **៥ ១៦១ ៩០៩នាក់** ស្មើនឹង **៥៣,២%** នៃចំនួនអ្នកមានសិទ្ធិបោះឆ្នោតស្រី-ប្រុស សរុប ៩ ៧១០ ៦៦៥នាក់[19] សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ នេះ។ មានអ្នកបោះឆ្នោតចំនួន **៨ ២១៤ ៤៣០នាក់** (៨៤,៦%)[20] ក្នុងនោះតាមការប៉ាន់ស្មាន អ្នកបោះឆ្នោតស្ត្រី **<u>ច្រើនជាង</u>** អ្នកបោះឆ្នោតបុរសបានចេញទៅបោះឆ្នោតនៅថ្ងៃបោះឆ្នោតនាថ្ងៃអាទិត្យ ទី២៣ ខែកក្កដា ឆ្នាំ២០២៣។ របាយការណ៍ សង្កេតរបស់អ្នកសង្កេតការណ៍ស្ត្រី**ខុមហ្វ្រែល** និងអ្នកសង្កេតការណ៍ស្ត្រី-បុរសរបស់អង្គការ**ហ្គេតស៊ី** (GADC) ក្នុងខេត្តគោលដៅចំនួន ៧ បានរកឃើញថា[21] ក្នុងចំណោមការិយាល័យបោះឆ្នោតសរុបចំនួន **១២២ ការិយាល័យ** មាន **១០៤ ការិយាល័យ**បោះឆ្នោត ស្ត្រីបានមកបោះឆ្នោត**<u>ច្រើនជាង</u>**បុរសដែលមានចន្លោះចាប់ពី **៥០,២%** រហូតដល់

---

[19] លទ្ធផលផ្លូវការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ប្រចាំឆ្នាំ២០២២ ចេញផ្សាយដោយគជប នៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៣

[20] លទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ នៅថ្ងៃអាទិត្យ ទី២៣ ខែកក្កដា ឆ្នាំ២០២៣ ចេញផ្សាយដោយគជប នៅថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៣

[21] របាយការណ៍សង្កេតរបស់ខុមហ្វ្រែល and GADC ស្តីពី « ការចូលរួមនយោបាយរបស់ស្ត្រីក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ក្នុងខេត្តគោលដៅ ៧ (ខេត្តកំពង់ធំ កំពង់ចាម កំពង់ឆ្នាំង តាកែវ ព្រះវិហារ ពោធិ៍សាត់ និងខេត្តព្រៃវែង)

**៧៧,២%។ ៥៥** ការិយាល័យបោះឆ្នោត មានយុវជនបានមកបោះឆ្នោតចន្លោះពី**១០,២%** ទៅ **៧៣%** ក្នុងនោះ ស្ត្រីវ័យក្មេងមានចន្លោះពី **២៣,៧%** ទៅ **៦៤,៨%។**



*ប្រភព ៖ ខុមហ្វ្រែល*

**នៅថ្ងៃបោះឆ្នោត**មានភាពមិនប្រក្រតីមួយចំនួនគួរកត់សម្គាល់ ដោយមានករណីអាជ្ញាធរមូលដ្ឋានឈរនៅមុខការិយាល័យបោះឆ្នោតធ្វើសកម្មភាពមិនប្រក្រតីមួយចំនួននិងមានការកៀរគរប្រជាពលរដ្ឋមកបោះឆ្នោត ដូចជា ៖ (១) មេឃុំឈរនៅមុខការិយាល័យបោះឆ្នោត ឈរជជែកជាមួយអ្នកបោះឆ្នោត និងដើរប្រមូលបញ្ជីអ្នកមកបោះឆ្នោតរៀងរាល់មួយម៉ោងម្តងៗ ចាប់ពីម៉ោង៨ព្រឹករហូតជិតបញ្ចប់ម៉ោងបោះឆ្នោត។ (២) មេភូមិដើរចុះដើរឡើងពីការិយាល័យបោះឆ្នោតមួយទៅការិយាល័យបោះឆ្នោតមួយ និងឈរនៅមុខការិយាល័យបោះឆ្នោតដែលជាហេតុធ្វើឱ្យអ្នកបោះឆ្នោតមានការភ័យខ្លាច។ (៣)មេភូមិទូរស័ព្ទហៅប្រធានក្រុមឱ្យប្រមូលសមាជិកឬកូនក្រុមឱ្យមកបោះឆ្នោតឱ្យបាន។ (៤) មេភូមិដើរចូលក្នុងការិយាល័យបោះឆ្នោត សុំឈ្មោះអ្នកមានក្នុងបញ្ជីបោះឆ្នោតដែលមិនទាន់បានមកបោះឆ្នោត។ មេភូមិនិយាយថា *«បើយើងប្រមូលប្រជាពលរដ្ឋមកបោះឆ្នោតមិនបានអស់ ថ្នាក់លើយើងកៀបពួកយើង ដូច្នេះយើងត្រូវតែដើរឌុបតាមផ្ទះ»* ដោយចាប់ផ្តើមប្រមូលនិងដើរឌុបប្រជាពលរដ្ឋពីម៉ោង១១ព្រឹករហូតដល់ជិតបញ្ចប់ម៉ោងបោះឆ្នោត។ (៥) អាជ្ញាធរសម្តីអាក្រក់ដាក់ប្រជាពលរដ្ឋដែលធ្វើឱ្យប្រជាពលរដ្ឋមានការអាក់អន់ចិត្តមិនចង់មកបោះឆ្នោត។ (៦) មន្ត្រីការិយាល័យបោះឆ្នោតខ្លះមិនបានផ្ទៀងផ្ទាត់ឯកសារគ្រាន់តែសួររកលេខរៀង អ្នកបោះឆ្នោតក៏អាចបោះឆ្នោតបាន។ មន្ត្រីការិយាល័យបោះឆ្នោតខ្លះមិនបានអនុវត្តតាមបទបញ្ញា និងនិតិវិធីបោះឆ្នោតបានគ្រប់ជ្រុងជ្រោយឡើយ។



*ប្រភព ៖ Khmer Time*

អ្នកមានសិទ្ធិបោះឆ្នោតចំនួន **១ ៤៩៦ ២៣៥នាក់** (១៥,៤%) មិនបានទៅបោះឆ្នោត និង/ឬ មិនបានបោះឆ្នោត ក្នុងនោះក៏អាចមានស្ត្រីមួយចំនួនធំផងដែរ ពួកគេបានជួបការលំបាកខ្លះក្នុងការទៅបោះឆ្នោតនៅថ្ងៃបោះឆ្នោត ដោយសារមានមូលហេតុ និងភាពមិនប្រក្រតីមួយចំនួនដែលប៉ះពាល់ដល់សិទ្ធិអ្នកបោះឆ្នោត ជាពិសេសអ្នកបោះឆ្នោតស្ត្រី ដូចជា មានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការ ប៉ុន្តែបាត់/គ្មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ, ឈ្មោះនិងទិន្នន័យមិនត្រឹមត្រូវក្នុងបញ្ជីបោះឆ្នោត។ មិនអាចរកឈ្មោះរបស់ពួកគាត់ឃើញនៅក្នុងបញ្ជីបោះឆ្នោត និងបានជួបបញ្ហាជាយថាហេតុមួយចំនួន។

យោងតាមរបាយការណ៍សង្កេតស្ត្រីរបស់ខុមហ្វ្រែល និងអង្គការហ្គេតស៊ីបានរកឃើញទៀតថា នៅថ្ងៃបោះឆ្នោតមានបញ្ហា និងភាពមិនប្រក្រតីកើតឡើងចំពោះអ្នកបោះឆ្នោតជាស្ត្រី ចំនួន **៨៤ ករណី** នៅក្នុង **៣២ ការិយាល័យបោះឆ្នោត** ដូចជា ៖ (១) អ្នកបោះឆ្នោតជាស្ត្រីមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការ ប៉ុន្តែបាត់/គ្មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬមិនមានឯកសារបញ្ជាក់អត្តសញ្ញាណ។ (២) ឈ្មោះ និងទិន្នន័យមិនត្រឹមត្រូវក្នុងបញ្ជីបោះឆ្នោត។ (៣) អ្នកបោះឆ្នោតជាស្ត្រីមួយចំនួនមិនអាចរកឈ្មោះរបស់ពួកគាត់ឃើញនៅក្នុងបញ្ជីបោះឆ្នោត ដោយសារពួកគាត់មិនបានទទួលប័ណ្ណព័ត៌មានអ្នកបោះឆ្នោត ឬមិនដឹងពីការផ្លាស់ប្តូរលេខកូដការិយាល័យបោះឆ្នោត។ (៤) ជួបបញ្ហាដាយថាហេតុ ដូចជា សមាជិកគ្រួសារឈឺត្រូវទៅពេទ្យបន្ទាន់។

**ការស្ទង់មតិរហ័ស**[22] (Rapid Survey) **របស់ខុមហ្វ្រែល** ស្តីពីការចូលរួមនយោបាយរបស់ស្ត្រី នៅក្នុងខេត្តគោលដៅទាំង៥ នៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៣ គឺ**ក្រោយ**ថ្ងៃបោះឆ្នោតមួយថ្ងៃទៅលើ « ***ស្ត្រីបានបោះឆ្នោត ឬ មានទឹកខ្មៅនៅម្រាមដៃ, ស្ត្រីមិនបានបោះឆ្នោត ឬមិនមានទឹកខ្មៅនៅម្រាមដៃ*** » បានបង្ហាញឱ្យឃើញថា ក្នុងចំណោមស្ត្រី សរុប **៦០នាក់**ដែលបានសម្ភាសន៍ មាន**៥០%បានបោះឆ្នោត**ដោយបានបញ្ជាក់ពីមូលហេតុដែលខ្លួនបានចេញទៅបោះឆ្នោត។ **៥០%មិនបានបោះឆ្នោត** ដោយបានលើកឡើងពីបញ្ហារបស់ខ្លួនដែលមិនអាចចេញទៅបោះឆ្នោត ឬមិនអាចបោះឆ្នោតបាន។ សូមបញ្ជាក់ថា **ស្ត្រីដែលបានបោះឆ្នោត**ភាគច្រើនមានមុខរបរជា អ្នកធ្វើស្រែចំការ មេផ្ទះ និងអ្នកធ្វើការក្រុមហ៊ុន ឬរោងចក្រ។ ចំណែក**ស្ត្រីដែលមិនបានបោះឆ្នោត**ភាគច្រើនមានមុខរបរជា កម្មការិនីរោងចក្រនៅទីក្រុងភ្នំពេញ និងជាអ្នកចំណាកស្រុក។

***៥០% នៃស្ត្រីដែលបានបោះឆ្នោត បានលើកឡើងថាពួកគាត់ចង់ទៅបោះឆ្នោត ដោយសារ ៖***

| **មូលហេតុ** |
|---|
| ចង់ប្រើប្រាស់សិទ្ធិក្នុងការបោះឆ្នោត |
| គាំទ្រគណបក្សដែលខ្លួនពេញចិត្ត |
| ព្រោះគ្រប់ៗគ្នាគេទៅបោះឆ្នោត |
| ចង់ឱ្យអាជ្ញាធរឃុំ និងរដ្ឋមន្ត្រីធ្វើផ្លូវដើរឱ្យបានស្អាត |
| យល់ឃើញថាការចូលរួមរបស់ស្ត្រីមានសារៈសំខាន់សម្រាប់ការបោះឆ្នោតជាតិ នីតិកាលទី៧ ឆ្នាំ២០២៣ |
| សង្ឃឹមថា នឹងទទួលបានអ្នកតំណាងជាស្ត្រីដែលជាមេដឹកនាំដ៏ល្អ និងមានការគិតគូរដល់បញ្ហាស្ត្រីនិងកុមារជាពិសេសធ្វើឱ្យប្រព័ន្ធសិក្សាអប់រំមានលក្ខណៈកាន់តែទូលំទូលាយ។ |
| ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនៅក្នុងឃុំ សង្កាត់ ខេត្តរបស់ពួកគាត់ |
| ចង់បានមេដឹកនាំល្អម្នាក់។ |

[22] ការស្ទង់មតិរហ័សរបស់អ្នកសង្កេតការណ៍ស្ត្រីខុមហ្វ្រែល នៅក្នុងតំបន់គោលដៅចំនួន ៥ខេត្ត ៖ កំពង់ចាម កំពង់ធំ កំពង់ឆ្នាំង តាកែវ និងព្រះវិហារ

៥០% នៃស្ត្រីដែលមិនបានបោះឆ្នោត បានលើកឡើងថា ពួកគាត់មិនបានបោះឆ្នោត ដោយសារ ៖

| មូលហេតុ |
|---|
| មិនមានពេលទៅបោះឆ្នោត |
| មិនយល់ពីនយោបាយ |
| មិនគិត ឬមិនយកចិត្តទុកដាក់លើបញ្ហានយោបាយ |
| រកឈ្មោះមិនឃើញ |
| ឈ្មោះ និងទិន្នន័យមិនត្រឹមត្រូវ (ក្នុងបញ្ជីឈ្មោះបោះឆ្នោត) |
| ឈឺមិនអាចទៅបោះឆ្នោតបាន |
| បាត់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ |
| ភ្លេចអត្តសញ្ញាណប័ណ្ណនៅកន្លែងធ្វើការ |

# IV. សេចក្តីសន្និដ្ឋាន និងសង្ខេប

កម្ពុជានៅបន្តបញ្ហាវិសមភាពនៃតំណាង និងការទទួលបានឱកាសស្មើគ្នារវាងស្ត្រីនិងបុរសនៅក្នុងវិស័យនយោបាយ និងវិស័យសាធារណៈ។ ជាក់ស្តែង ភាគរយសរុបនៃស្ត្រីនិងបុរសជាប់ឆ្នោតក្លាយជាតំណាងរាស្ត្រ សម្រាប់នីតិកាលទី៧ ឆ្នាំ២០២៣ មាន**គម្លាតគ្នាឆ្ងាយ** គឺ ស្ត្រីជាប់ឆ្នោតមានតិច**១២,៨%** និងបុរសជាប់ឆ្នោតដ៏ច្រើនលើសលុប **៨៧,២%**។ ចំណែកស្ត្រីនៅក្នុងតំណែងសាធារណៈជាតំណែងនយោបាយដឹកនាំនៅថ្នាក់ជាតិ គឺ មាន**ភាគរយតិចតួច** និងមាន**គម្លាតគ្នាឆ្ងាយ**ផងដែររវាងស្ត្រី និងបុរស គឺ ស្ត្រីមានតែ **១៤,៧%** ឯបុរសមាន**៨៥,៣%** ខណៈពេលដែលសិទ្ធិអំណាចផ្លូវការពេញលេញរបស់ស្ត្រីក្នុងការបំពេញតួនាទីរបស់ខ្លួននៅមានការប្រឈមនឹងការរើសអើង និងនៅមានកម្រិត។ នេះយើងមិនទាន់វិភាគទៅដល់ភាពចម្រុះផ្សេងទៀតរបស់ស្ត្រីដែលមានពិការភាព ជនជាតិដើមភាគតិច អ្នកស្រលាញ់ភេទដូចគ្នាជាដើមផងដោយសារភាពមិនគ្រប់ជ្រុងជ្រោយនៃទិន្នន័យ។

**លោកជំទាវ ឃួន សុដារី ជាស្ត្រីដំបូង**ត្រូវបានជ្រើសតាំងជា **ប្រធានរដ្ឋសភា** សម្រាប់នីតិកាលទី៧នៃរដ្ឋសភា។ ការណ៍នេះ បានបង្ហាញពីការប្តេជ្ញាចិត្តខ្ពស់ និងឆន្ទៈក្នុងការបង្កើនសមភាពយេនឌ័ររបស់អ្នកដឹកនាំកំពូល និងជាការផ្លាស់ប្តូរបែបវិជ្ជមានមួយពុំធ្លាប់មានពីមុននៅប្រទេសកម្ពុជា។

**លោកស្រីបណ្ឌិត ជា សិរី** ឥស្សរជនជាស្ត្រីដំបូងគេដែលបានតែងតាំងជា**អគ្គទេសាភិបាលថ្មី** របស់ធនាគារជាតិនៃកម្ពុជាសម្រាប់រាជរដ្ឋាភិបាលថ្មី នីតិកាលទី៧ នៃរដ្ឋសភា។

បេក្ខជនស្ត្រីឈរឈ្មោះបោះឆ្នោត សម្រាប់នីតិកាលទី៧ ឆ្នាំ២០២៣មានចំនួន **៣២,៤%** បាន**កើន ៧**,២% ធៀបនឹងនីតិកាលទី៦ ឆ្នាំ២០១៨ មានតែ ២៥,២% ប៉ុណ្ណោះ។ ទោះបីជាយ៉ាងណា ចំនួននិងភាគរយសរុបនៃបេក្ខជនស្ត្រី និងបេក្ខជនបុរសនៅមាន **គម្លាតគ្នាឆ្ងាយ** ដែលវិសមភាពយេនឌ័រក្នុងវិស័យនយោបាយនៅតែជាបញ្ហាត្រូវបន្ថែមការយកចិត្តទុកដាក់ និងត្រូវដាក់ចេញនូវវិធានការពិសេសជាក់លាក់ពីអ្នកដឹកនាំគណបក្សនយោបាយ និងអ្នកដឹកនាំរដ្ឋាភិបាលនិងសភាជាតិ ។

**ចំនួនស្ត្រីជាប់ឆ្នោត**សម្រាប់នីតិកាលទី៧ ឆ្នាំ២០២៣ **បានថយចុះ** ៨% បើធៀបនឹងចុងនីតិកាលទី៦ នៃរដ្ឋសភា តំណាងរាស្ត្រស្ត្រីមាន **២០,៨%** ពី ២៦រូប មកត្រឹមតែ ១៦រូប (**១២,៨%**) នីតិកាលទី៧។

ស្ត្រីជាប់ឆ្នោតមានចំនួនតិចនិងបានថយចុះជាបន្តបន្ទាប់នេះ ដោយសារមានកត្តាចម្បង និងការប្រឈមមួយចំនួន ៖ (១) កង្វះឆន្ទៈនយោបាយរបស់គណបក្ស ដែលមានការគាំទ្រច្រើនពីអ្នកបោះឆ្នោត និងការប្តេជ្ញាចិត្តខ្ពស់របស់អ្នកដឹកនាំក្នុងការជំរុញឱ្យមានសមភាពយេនឌ័រក្នុងវិស័យនយោបាយ និងថ្នាក់សម្រេចចិត្ត។ (២) ខ្វះគោលនយោបាយសមភាពយេនឌ័រជាក់លាក់នៅក្នុងគណបក្សនយោបាយ រួមទាំងមិនមានចែងជាក់លាក់អំពី វិធានការពិសេសក្នុងមាត្រាមួយចំនួននៃច្បាប់បោះឆ្នោត ដើម្បីគាំទ្រ និងផ្តល់ឱកាសឱ្យស្ត្រីចូលរួមដោយស្មើគ្នានឹងបុរសក្នុងវិស័យនយោបាយ ជាពិសេសការឈរឈ្មោះជាបេក្ខជន និងជាប់ឆ្នោត។

(៣) របនាសម្ព័ន្ធនៃការគ្រប់គ្រងភាគច្រើនលើសលុបជាបុរស ហើយបុរសនៅតែបន្តរក្សាតំណែងរបស់ខ្លួន ដែលនេះធ្វើឱ្យឱកាសទទួលបានមុខតំណែងរបស់ស្ត្រីកាន់តែរួមតូច ។ (៤) បញ្ហាថវិកាក្នុងការឈរឈ្មោះជាបេក្ខជនដែលគណបក្សតម្រូវសម្រាប់ធ្វើការឃោសនាបោះឆ្នោត គឺជាឧបសគ្គដ៏ធំបំផុតមួយដែលស្ត្រីបានប្រឈម ។ (៥) សកម្មជនស្ត្រីគណបក្សនយោបាយ និងអ្នកនយោបាយស្ត្រីនៅតែប្រឈមនឹង**ការរើសអើង** និង**អំពើហិង្សា**គ្រប់ទម្រង់ ដែលជាឧបសគ្គរារាំងពួកគេក្នុងការចូលរួមក្នុងសកម្មភាពនយោបាយ និងការទទួលបាននូវយុត្តិធម៌យេនឌ័រ និងផលប្រយោជន៍ពីការចូលរួមក្នុងវិស័យនយោបាយ។ (៦) បទដ្ឋានវប្បធម៌ និងសង្គមមួយចំនួនដែលមានផ្នត់គំនិតអវិជ្ជមានក្នុងការលើកកម្ពស់ភាពជាអ្នកដឹកនាំរបស់ស្ត្រី គឺជាឫសគល់បញ្ហាបង្កជារនាំងរារាំងដល់ការចូលរួមរបស់អ្នកនយោបាយស្ត្រីប្រកបដោយគុណភាព និងប្រសិទ្ធភាព ។

គណបក្សនយោបាយទាំង**១៨** ដែលបានចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ នៅតែបង្ហាញឱ្យឃើញថា ការងារលើកកម្ពស់ភាពជាអ្នកដឹកនាំរបស់ស្ត្រីនៅមានកំរិតនៅឡើយ តាមរយៈលទ្ធផលនៃការឈរឈ្មោះជាបេក្ខជន ជាពិសេសការឈរឈ្មោះជាបេក្ខជនរបស់ស្ត្រីនៅលំដាប់លេខរៀងទី១ដែលមានឱកាសច្រើនក្នុងការក្លាយខ្លួនជាតំណាងជាប់ឆ្នោត។ ជាក់ស្តែង ចំនួននិងភាគរយសរុបនៃបេក្ខជនស្ត្រី និងបេក្ខជនបុរសឈរឈ្មោះនៅ**លេខរៀងទី១ មានគម្លាតគ្នាខ្លាំង គឺ** បេក្ខជនស្ត្រី មាន**១៨%** ខណៈដែលបេក្ខជនបុរសមានច្រើនលើសលុប **៨២%**។

**គណបក្សពីរ**ទទួលបានការគាំទ្រពីអ្នកបោះឆ្នោត និងទទួលបានអាសនៈច្រើនសម្រាប់នីតិកាល ទី៧ នៃរដ្ឋសភា គឺ **គណបក្សប្រជាជនកម្ពុជា** និង**គណបក្សហ្វុនស៊ិនប៉ិច** ប៉ុន្តែអ្នកដឹកនាំគណបក្សទាំងពីរនេះនៅខ្វះការប្តេជ្ញាចិត្តខ្ពស់របស់ខ្លួន និងគោលនយោបាយរួមទាំងថវិកាដែលបម្រុងទុកក្នុងការបង្កើនសមភាពយេនឌ័រក្នុងវិស័យនយោបាយ និងតួនាទីសម្រេចចិត្ត ដោយបានដាក់បេក្ខជនស្ត្រីឈរឈ្មោះមានភាគរយ**តិចតួច ហើយបេក្ខជនស្ត្រីភាគច្រើនឈរឈ្មោះនៅលេខរៀងខាងក្រោម**នៅក្នុងបញ្ជីឈរឈ្មោះគណបក្សរបស់ខ្លួនសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ។

គណបក្សនយោបាយប្រមាណ**៧២%**ក្នុងចំណោមគណបក្សនយោបាយ១៨ បានគិតគូរក្នុងការដោះស្រាយបញ្ហាស្ត្រី និងកុមារ និងលើកកម្ពស់សមភាពយេនឌ័រ សម្រាប់នីតិកាលទី៧ នៃរដ្ឋសភា។

**អ្នកបោះឆ្នោតស្ត្រី ច្រើនជាង អ្នកបោះឆ្នោតបុរស**បានចេញទៅបោះឆ្នោត នៅថ្ងៃបោះឆ្នោតថ្ងៃអាទិត្យទី២៣ ខែកក្កដា ឆ្នាំ២០២៣ ។ ជាក់ស្តែង **អ្នកបោះឆ្នោតស្ត្រី**បានមកបោះឆ្នោតតាមការិយាល័យបោះឆ្នោតចាប់ពី **៥០,២%** រហូតដល់ **៧៧,២%** នៅក្នុង **១០៤** ការិយាល័យបោះឆ្នោត ។ **៥៥ ការិយាល័យ**បោះឆ្នោតមាន**យុវជន**បានមកបោះឆ្នោតចន្លោះពី **១០,២%** ទៅ **៧៣%** ក្នុងនោះ**ស្ត្រីវ័យក្មេង**មានចន្លោះពី **២៣,៧%** ទៅ **៦៤,៨%** នៃតំបន់គោលដៅរបស់អង្គការខុមហ្វ្រែល និងអង្គការហ្គេតស៊ី។

**ពុំមានស្ត្រីសោះ** ជាអ្នកដឹកនាំនៅថ្នាក់ជាតិជាសមាជិក គ.ជ.បក្នុងចំណោមសមាសភាពទាំង**៩រូប** និងជាអគ្គលេខាធិការនិងអគ្គលេខាធិការរងទាំង**៥រូប** ។ ផ្ទុយទៅវិញ **ស្ត្រីកាន់តែច្រើន ៤៨,៤%** ចូលរួមចាត់ចែងការបោះឆ្នោតនៅថ្នាក់ទាបជាមន្ត្រីគកប និងគករ ក្នុងនោះភាគច្រើនមានតួនាទីជា**សមាជិក ៤៩,៤%** ខណៈ

ដែលតួនាទីជា**ប្រធាន**មាន**តិចតួច ៨,៥%** នៅក្នុង**១២៤**ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតនៃតំបន់គោលដៅរបស់អង្គការខុមហ្វ្រែល និងអង្គការហ្គេតស៊ី។

**នៅថ្ងៃបោះឆ្នោត**មានភាពមិនប្រក្រតីមួយចំនួនគួរកត់សម្គាល់ ដោយមានករណីអាជ្ញាធរមូលដ្ឋានឈរនៅមុខការិយាល័យបោះឆ្នោតធ្វើសកម្មភាពមិនប្រក្រតីមួយចំនួន និងមានការកៀរគរប្រជាពលរដ្ឋមកបោះឆ្នោត។

ស្ត្រី និងបុរសខ្មែរត្រូវបានធានាយ៉ាងពេញលេញ និងស្មើភាពគ្នាដោយរដ្ឋធម្មនុញ្ញកម្ពុជាស្តីពីការចូលរួម និងផលប្រយោជន៍នយោបាយរបស់ពួកគេ។ ទោះយ៉ាងណា លក្ខណៈងាយស្រួល និងបរិយាកាសអំណោយផលសម្រាប់ស្ត្រី (women-friendly and enabling environment), គោលនយោបាយច្បាប់បោះឆ្នោត, និងមាត្រដ្ឋាននៃប្រតិបត្តិការមិនទាន់បានឆ្លើយតបជាក់ស្តែងចំពោះស្ថានភាពនៃការចូលរួមរបស់ស្ត្រីក្នុងឆាកនយោបាយទេ។ គម្លាតនៃគោលនយោបាយនិងច្បាប់បោះឆ្នោតមិនឆ្លើយតបនឹងយេនឌ័រ, គម្លាតមាត្រដ្ឋាននៃប្រតិបត្តិការ និងការវិនិយោគ បាន**ពង្រឹងវិសមភាព**នៃភាពជាតំណាង និងការចូលរួមរបស់ស្ត្រី។

ហេតុនេះ មាន**គោលនយោបាយសមភាពយេនឌ័រនៅក្នុងគណបក្ស** និង**ច្បាប់បោះឆ្នោតឆ្លើយតបនឹងយេនឌ័រ** ហើយត្រូវ**អនុវត្តបានល្អ**នឹងក្លាយជាឧបករណ៍ដ៏សំខាន់ និងមានប្រសិទ្ធភាពសម្រាប់ស្ត្រីក្នុងការទាមទារសិទ្ធិរបស់ពួកគេ និងចាប់យកឱកាសស្មើភាពគ្នាជាបេក្ខជនឈរឈ្មោះ និងជាប់ឆ្នោត ។ បន្ថែមពីនេះ ការ**ប្តេជ្ញាចិត្តខ្ពស់របស់អ្នកដឹកនាំ** និង**ឆន្ទៈនយោបាយ**ក្នុងការគាំទ្រ គឺជាកត្តាចាំបាច់ដែលជម្រុញឱ្យការងារនេះទទួលបានជោគជ័យ ។

## V. អនុសាសន៍

ដើម្បីបង្កើនសមភាពយេនឌ័រឈានទៅសម្រេចតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ការផ្ដល់អំណាចនយោបាយដល់ស្ត្រី និងបង្កើនការចូលរួមដោយបរិយាបន្ន វិធានការខាងក្រោមគួរត្រូវបានដោះស្រាយ ៖

### ១. រដ្ឋសភា និងព្រឹទ្ធសភា

ធានាថាច្បាប់បោះឆ្នោតដែលរួមមាន ច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្លើយតបនឹងយេនឌ័រដែលមានចែងពីវិធានការពិសេសដើម្បីលើកកម្ពស់សមភាពយេនឌ័រ និងផ្ដល់ឱកាសឱ្យស្ត្រីចូលរួមដោយស្មើភាពនៅក្នុងវិស័យនយោបាយ តាមរយៈការជំរុញលើកទឹកចិត្តគ្រប់គណបក្សនយោបាយដាក់បេក្ខភាពស្ត្រីច្រើនក្នុងបញ្ជីបេក្ខជនឈរឈ្មោះរបស់គណបក្ស ។ ការលើកទឹកចិត្តដើម្បីអនុវត្តរបស់គណបក្សនយោបាយនេះ គឺត្រូវស្ថិតក្នុងក្របខណ្ឌច្បាប់ គឺសំដៅដល់ការធ្វើវិសោធនកម្មច្បាប់បោះឆ្នោត ។

**ក-** វិសោធនកម្មច្បាប់បោះឆ្នោត ដើម្បីកែលម្អបន្ថែមលក្ខខណ្ឌនៃការដាក់ពាក្យចុះឈ្មោះបញ្ជីបេក្ខជននៃគណបក្សនយោបាយ ដែលតម្រូវឱ្យដាក់ឆ្លាស់គ្នារវាងបេក្ខជនស្ត្រី និងបុរសតាមលំដាប់លេខរៀងពី លើ ដល់ ក្រោមនៅក្នុងបញ្ជីបេក្ខជនឈរឈ្មោះរបស់គណបក្សនយោបាយ ។

**ខ-** ធ្វើវិសោធនកម្មច្បាប់បោះឆ្នោតមានដូចជា ច្បាប់ ស្ដីពី ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ **ជំពូកទី៤ មាត្រា២៧ និងមាត្រា២៨**« ***បញ្ជីបេក្ខជនឈរឈ្មោះតាមមណ្ឌលនីមួយៗត្រូវមានបេក្ខជនស្ត្រីនិងបេក្ខជនបុរសឆ្លាស់គ្នាតាមលំដាប់លេខរៀងពី លើ ដល់ ក្រោម*** » និងច្បាប់ស្តីពី ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ **ជំពូកទី៦ មាត្រា៣៩** « ***បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗត្រូវមានឈ្មោះបេក្ខជនតាមលំដាប់លេខរៀង និងឆ្លាស់គ្នារវាងស្ត្រី និងបុរសពី លើ ដល់ ក្រោម*** » ។

### ២. គណបក្សនយោបាយ

- គណបក្សនយោបាយឈ្នះឆ្នោត គួរដាក់បញ្ចូលបេក្ខជនស្ត្រីបម្រុងឱ្យបានជាប់ជាតំណាងរាស្ត្រសម្រាប់នីតិកាលទី៧នេះ នៅពេលដែលអ្នកជាប់ឆ្នោតជាបុរស-ស្ត្រីទៅកាន់តំណែងក្នុងរដ្ឋាភិបាល។
- គណបក្សនយោបាយទាំងអស់ ធានាបង្កើតគោលនយោបាយសមភាពយេនឌ័រនៅក្នុងគណបក្ស ហើយគោលនយោបាយនេះត្រូវអនុវត្តឱ្យបានល្អ ដើម្បីលើកកម្ពស់ការចូលរួមរបស់ស្ត្រីដោយស្មើភាពដោយគ្មានការរើសអើងនៅក្នុងគណបក្សនយោបាយរបស់ខ្លួន ដូចជា ស្ត្រីក្នុងដំណើរការបង្កើតគោលនយោបាយ ស្ត្រីនៅក្នុងការធ្វើសេចក្ដីសម្រេច ស្ត្រីក្នុងតួនាទីជាអ្នកដឹកនាំ ស្ត្រីជាបេក្ខជនឈរឈ្មោះ

បោះឆ្នោត តំណាងស្ត្រីជាប់ឆ្នោត និងបង្កើនសមភាពយេនឌ័រនៅគ្រប់ជាន់ថ្នាក់នៅក្នុងគណបក្សនយោបាយ ជាពិសេសដាក់បញ្ចូលប្រព័ន្ធឆ្លាស់គ្នាតាមលំដាប់លេខរៀងពី លើ ដល់ ក្រោម រវាងបេក្ខជនស្ត្រី និងបេក្ខជនបុរសនៅក្នុងបញ្ជីឈ្មោះរបស់គណបក្សនយោបាយ។

- គ្រប់គណបក្សនយោបាយដែលចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោត គួរផ្តល់ថវិកាឱ្យបេក្ខជនស្ត្រីសម្រាប់ប្រើប្រាស់ធ្វើយុទ្ធនាការឃោសនាបោះឆ្នោត និងដកលក្ខខណ្ឌថវិកាចំពោះស្ត្រីសម្រាប់ការឈរឈ្មោះជាបេក្ខជនបោះឆ្នោត។

## ៣. រាជរដ្ឋាភិបាលកម្ពុជា

- រាជរដ្ឋាភិបាលកម្ពុជា គួរបង្កើនចំនួនស្ត្រីជាថ្នាក់ដឹកនាំ និងក្នុងតួនាទីធ្វើសេចក្តីសម្រេចនៅក្នុងក្រសួងស្ថាប័ននីមួយៗយ៉ាងហោច **៣៥%** ដោយគិតចាប់ពីតួនាទីជាប្រធាននាយកដ្ឋាន រហូតដល់រដ្ឋមន្ត្រី និងឧបនាយករដ្ឋមន្ត្រី ប្រយោជន៍ស្ត្រីមានឱកាសចូលរួមពិភាក្សា ស្វែងរកដំណោះស្រាយ និងធ្វើសេចក្តីសម្រេចប្រកបដោយបរិយាបន្នស្របតាមអនុសញ្ញាស៊ី-ដរ (CEDAW) និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់កម្ពុជា (CSDG)។
- រាជរដ្ឋាភិបាលកម្ពុជា (ក្រសួងពាក់ព័ន្ធ) គួរបង្កើនការវិនិយោគ និងផ្តល់ការគាំទ្រគ្រប់បែបយ៉ាងជាលក្ខណៈប្រព័ន្ធដូចជា ថវិកា ធនធានសម្ភារ និងធនធានមនុស្សដល់អ្នកដឹកនាំស្ត្រី និងស្ត្រីជាប់ឆ្នោត ដើម្បីបង្កលក្ខណៈងាយស្រួល និងបង្កើនប្រសិទ្ធភាព និងគុណភាពនៃការចូលរួមនយោបាយ ការងារ និងភាពជាអ្នកដឹកនាំរបស់ស្ត្រី។

## ៤. អង្គការសង្គមស៊ីវិល វិទ្យាស្ថានអប់រំនិងការសិក្សា

- បង្កើនយន្តការគាំទ្រសម្រាប់អ្នកនយោបាយស្ត្រីដូចជា ការអភិវឌ្ឍសមត្ថភាព (ទំនុកចិត្តលើខ្លួនឯង និង ជំនាញដែលចាំបាច់ដើម្បីចូលរួមក្នុងនយោបាយ រួមមាន ការបង្កើតយុទ្ធសាស្ត្របញ្ចុះបញ្ចូល និងយុទ្ធនាការឃោសនាប្រកបដោយប្រសិទ្ធភាព) ការផ្តល់អំណាច និងមូនិធិនយោបាយពិសេសដល់ស្ត្រីក្នុងវិស័យនយោបាយ ។
- ប្រើប្រាស់ទាំងប្រព័ន្ធផ្សព្វផ្សាយសង្គម និងប្រព័ន្ធផ្សព្វផ្សាយដើម្បីធ្វើយុទ្ធនាការលើកកម្ពស់សិទ្ធិស្ត្រីដោយសង្កត់ធ្ងន់ទៅលើសារៈសំខាន់នៃការចូលរួមក្នុងនយោបាយ និងតួនាទីជាអ្នកដឹកនាំរបស់ស្ត្រីនិងពន្លឿនការលុបបំបាត់ការរើសអើងនិងអំពើហិង្សាគ្រប់ទម្រង់លើស្ត្រីនៅកម្រិតសាធារណៈ, នយោបាយ និងគ្រួសារ ។

## ៥. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប)

- បង្កើតគំនិតផ្តួចផ្តើម និងចូលរួមជម្រុញការធ្វើវិសោធនកម្មច្បាប់បោះឆ្នោតដើម្បីឆ្លើយតបនឹងយេនឌ័រដែលមានចែងពីវិធានការពិសេស ប្រយោជន៍ធានានូវសមភាពយេនឌ័រក្នុងការបោះឆ្នោត ជាពិសេស

គាំទ្រ និងរិះរកគ្រប់មធ្យោបាយដើម្បីជួយស្ត្រីឱ្យមានឱកាសបានឈរឈ្មោះជាបេក្ខជន និងបានជាប់ឆ្នោតច្រើន ។

- ធានាបង្កើតបទបញ្ញា និងនីតិវិធីដែលឆ្លើយតបនឹងយេនឌ័ររបស់គ.ជ.បសម្រាប់ការបោះឆ្នោត ដើម្បីបង្កើនសមភាពយេនឌ័រ និងផ្តល់ឱកាសស្មើភាពដល់បេក្ខជនស្ត្រីឈរឈ្មោះបោះឆ្នោត ដោយបន្ថែមលក្ខខណ្ឌនៃការដាក់ពាក្យចុះឈ្មោះបញ្ជីបេក្ខជននៃគណបក្សនយោបាយ ដែលតម្រូវឱ្យដាក់ឆ្លាស់គ្នារវាងបេក្ខជនស្ត្រី និងបុរសតាមលំដាប់លេខរៀងពីលើដល់ក្រោមនៅក្នុងបញ្ជីបេក្ខជនឈរឈ្មោះរបស់គណបក្សនយោបាយ។
- ត្រូវបង្កើនសកម្មភាពអប់រំ ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ (អ្នកបោះឆ្នោត)ឱ្យកាន់តែទូលំទូលាយ អំពីការទុកដាក់ឯកសារដោយត្រឹមត្រូវសម្រាប់បម្រើឱ្យការបោះឆ្នោត, គោលការណ៍សំខាន់ៗនៃការបោះឆ្នោត, សារៈសំខាន់នៃការប្រើប្រាស់សិទ្ធិរបស់ខ្លួន, បទបញ្ញា និងនីតិវិធីនៃការបោះឆ្នោត, ភាពឈ្លាសវៃរបស់អ្នកបោះឆ្នោតដើម្បីសុវត្ថិភាពពីការបំភិតបំភ័យពីព័ត៌មានក្លែងបន្លំ និងឧបាយកលនានាក្នុងអំឡុងពេលនៃការបោះឆ្នោត។
- ធានាសុវត្ថិភាព និងសន្តិសុខដល់បេក្ខជនស្ត្រីមកពីគណបក្សទាំងអស់ក្នុងអំឡុងពេលបោះឆ្នោតដោយមិនមានការរើសអើងនិន្នាការ ប្រយោជន៍បេក្ខជនស្ត្រីបានចាកផុតពីការគំរាមកំហែង, ការបៀតបៀន, ការឃាយីពីគណបក្ស ឬអ្នកគាំទ្រផ្សេងគ្នា និងបានធ្វើសកម្មភាពនយោបាយដោយពេញលេញ៕

៙៙៙ **ចប់** ៚៚៚

# ឧបសម្ព័ន្ធ ១

## The Number and Percentage of Women Candidates and Men Candidates by Capital-Province Constituencies

| Nº | Provinces/Capital | Candidates | Women | | Men | | Political Parties |
